# OMI0002

មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ អ៊ឹម ចែម ភេទស្រី អាយុ៧០ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ គណៈស្រុកព្រះនេត្រព្រះ**

**សព្វថ្ងៃរស់នៅភូមិអូរអង្រ្រែ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១២**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០២:៤១:១០**

**៦៩ទំព័រ..**

ដានី : ខ្ញុំឈ្មោះ ដានី ប៉ុន្មាន២នាក់ដែលគេទៅសម្ភាសន៍នឹងឈ្មោះ វណ្ណៈ ហើយនឹងឈ្មោះ សុវណ្ណ ។ ពួកខ្ញុំទាំង៣នាក់នឹងមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខាងមជ្ឈមណ្ឌលឯកសារកម្ពុជានឹង ត្រូវខាងក្រសួងអនុញ្ញាតិឲ្យពួកខ្ញុំចងក្រង និងសរសេរពីសៀវភៅមគ្គុទេសទេសចរណ៍នៅតំបន់អន្លង់វែង ។ ហើយការសរសេរសៀវភៅនេះ វាទាក់ទងទៅនឹងការសម្ភាសន៍បងប្អូនប្រជាជនយ៉េង នៅតាមស្រុកតាមភូមិ ដែលគាត់ជាអតីតអ្នកតស៊ូហើយក្រោយមកបន្ទាប់ពីសមាហរណកម្ម ហើយគាត់មកចាប់ផ្ដើមកសាងផ្ទះសម្បែង ភូមិស្រុកអីរស់នៅនេះអ៊ំ ។ ហើយចឹងខ្ញុំសុំសួរអ៊ំខ្លះៗទាក់ទងពីប្រវត្តិតស៊ូរបស់អ៊ំ ទាក់ទងពីការកសាងភូមិថ្មី ការរស់នៅរបស់អរហូតមកដល់សព្វថ្ងៃនេះ ។ ចឹងអ៊ំអនុញ្ញាតិឲ្យខ្ញុំសួរដែរអត់?

ចែម : មានអីសួរទៅ ។

ដានី : ចឹងអ៊ំដំបូង ខ្ញុំចង់ស្គាល់ឈ្មោះអ៊ំៗឈ្មោះអីដែរ?

ចែម : ខ្ញុំឈ្មោះ ដដែល អ៊ុម ចែម ។

ដានី : អ៊ុម ចែម?

ចែម : ចា៎!

ដានី : អ៊ំសព្វថ្ងៃអាយុប៉ុន្មានហើយ?

ចែម : ខ្ញុំចូលឆ្នាំថ្មីនេះ ៧០ហើយ ។

ដានី : ៧០ហើយឥឡូវឆ្នាំថ្មី?

ចែម : ចា៎!

ដានី ៖ អ៊ំស្រុកកំណើតកើតជាអ៊ំនៅភូមិឃុំស្រុកអីដែរ?

ថែម ៖ នៅភូមិក្បាលអូរ ឃុំដាំងទង ស្រុកត្រាំកក់ តាកែវ ។

ដានី ៖ ក្បាលអូរ ឃុំដាំងទង ត្រាំកក់ តាកែវ ។ គ្រួសារអ៊ំគាត់ឈ្មោះអីដែរ?

ថែម ៖ ឈ្មោះ ណុប ញ៉ែន ។

ដានី ៖ ណុប ញ៉ែន?

ថែម ៖ ចា៎!

ដានី ៖ គាត់អាយុប៉ុន្មានដែរ?

ថែម ៖ គាត់អាយុ៧០ហើយ ។

ដានី ៖ អាយុ៧០ អាយុស្មើអ៊ំដែរ?

ថែម ៖ បងខ្ញុំ៤ឆ្នាំ ៧៤ហើយ ។

ដានី ៖ ៧៤, ៤ឆ្នាំ?

ថែម ៖ ចា៎!

ដានី ៖ ចុះអ៊ំមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

ថែម ៖ ខ្ញុំមាន៨ ប៉ុនស្លាប់អស់៤នៅសល់៤ ។

ដានី ៖ ៨នាក់ ស្លាប់អស់៤?

ថែម ៖ ចា៎!

ដានី ៖ ៨នាក់នឹង ប្រុសប៉ុន្មាន ស្រីប៉ុន្មានទៅអ៊ំ?

ថែម ៖ ប្រុស៦ ស្រី២ ។

ដានី ៖ ប្រុស៦ ស្រី២?

ថែម ៖ ចា៎!

ដានី ៖ ចឹងអ៊ំស្លាប់អស់៤នាក់នឹង ស្លាប់ដោយសារមូលហេតុអីខ្លះទៅ?

ថែម ៖ ស្លាប់ដោយសារមូលហេតុ វាឈឺ ខ្ញុំនៅលើភ្នំ ។

ដានី ៖ ឈឺគាត់នៅលើភ្នំ?

ថែម ៖ ចា៎! ឈឺគ្រុនចាញ់អីចឹង ។

ដានី ៖ ឈឺគ្រុនចាញ់អីនឹង?

ថែម ៖ ចា៎!

ដានី ៖ កាលនឹងយើងអត់មានថ្នាំ មានពេទ្យអីគ្រប់គ្រាន់?

ថែម ៖ អត់ ។

ដានី ៖ ចឹង៤នាក់នឹង គាត់ស្លាប់នៅលើភ្នំទាំងអស់?

ថែម ៖ នៅឯស្រុកមួយ នឹងដែលខ្ញុំដើរតាមភូមិធ្វើការនឹង ។

ដានី ៖ បាទ! ដើរធ្វើការអត់សូវបានថែកូន?

ថែម ៖ អត់សូវបានថែទាំកូនស្លាប់ ។

ដានី ៖ មួយ ហើយនឹងលើភ្នំ៣នាក់?

ថែម ៖ និយាយរួមដែលប្រវត្តិម៉ែចិញ្ចឹមកូននឹងវាអត់គ្រប់គ្រាន់ ព្រោះអីខ្ញុំតស៊ូៗដើម្បីជាតិពូជសាសន៍របស់ខ្លួន ។

ដានី ៖ ចុះអ៊ីសព្វថ្ងៃនេះនៅភូមិឃុំស្រុកអីដែរសព្វថ្ងៃ?

ថែម ៖ នៅ ហើយខ្ញុំចិញ្ចឹមកូនមួយកូនកំព្រា ។

ដានី ៖ កូនចិញ្ចឹមមួយដែរ?

ថែម ៖ ចា៎!

ដានី ៖ អ៊ីសព្វថ្ងៃនេះនៅភូមិអីដែរ?

ថែម ៖ ភូមិអូរអង្រ្រែ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ។

ដានី ៖ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ?

ថែម ៖ ចា៎! ខេត្តឧត្តរមានជ័យ ។

ដានី ៖ ចុះអ៊ីសព្វថ្ងៃនេះ អ៊ីប្រកបមុខរបររកស៊ីធ្វើអីដែរ?

ថែម ៖ មុខរបររកស៊ីរបស់ខ្ញុំធ្វើស្រែចំការ ។

ដានី ៖ ធ្វើស្រែ?

ថែម ៖ ចា៎!

ដានី ៖ មានធ្វើអីទៀត?

ថែម ៖ ធ្វើការងារ ឈប់ហើយ ។

ដានី ៖ ហើយអ៊ីធ្វើជំទប់ទី១ ឥឡូវអ៊ីឈប់ហើយ?

ថែម ៖ ឈប់ហើយ ។

ដានី ៖ ឈប់ពីពេលណាទៅ?

ថែម ៖ ឈប់ដល់អណត្តិឈប់ ខែ៦ ខែ៧ បើគេបោះឆ្នោតហើយ ឈប់ ។

ដានី ៖ អាទឹងដាច់ហើយ?

ថែម ៖ ចា៎! ដាច់ហើយ ។

ដានី ៖ អ៊ីជំទប់ទី១ឃុំត្រពាំងតាវ ដាច់អណត្តិខែ៦ខាងមុខនេះ?

ថែម ៖ ចា៎ៗ ។

ដានី ៖ ខែ៦គេបោះឆ្នោតហើយ អ៊ំឈប់ហើយ លែងជាប់ធ្វើការអីក្នុងឃុំនេះទៀតហើយ?

ថែម ៖ ចា៎!

ដានី ៖ អ៊ំ ឪពុកអ៊ំគាត់ឈ្មោះអីដែរ?

ថែម ៖ ឈ្មោះ អ៊ុំវ ។

ដានី ៖ អ៊ុំវ ត្រកូលគាត់អីដែរ?

ថែម ៖ អ៊ាច អ៊ុំវ ។

ដានី ៖ គាត់ខូចយូរហើយ?

ថែម ៖ ទើបនឹងខូច២ឆ្នាំៗនេះ អាយុ៩២ហើយបានគាត់ខូច ។

ដានី ៖ អាយុបានវែង?

ថែម ៖ ចា៎!

ដានី ៖ គាត់ស្លាប់នៅណា នៅអន្លង់វែងនឹង ហើយក៏?

ថែម ៖ ស្លាប់នៅម៉ាឡៃ គាត់ទៅនៅជាមួយកូននៅម៉ាឡៃ ។

ដានី ៖ នៅជាមួយប្អូនអ៊ំនៅម៉ាឡៃ?

ថែម ៖ ចា៎!

ដានី ៖ ចុះម្តាយអ៊ំ?

ថែម ៖ ម្តាយខ្ញុំបង្កើតនោះ ស្លាប់តាំងពីខ្ញុំអាយុ១០ឆ្នាំ ។

ដានី ៖ ស្លាប់តាំងពីអ៊ំអាយុ១០ឆ្នាំ?

ថែម ៖ ចា៎!

ដានី ៖ គាត់ឈ្មោះអីដែរ?

ថែម ៖ ឈ្មោះ ត្រកូលបើដាក់ត្រឹមឪអានឹង ជុំ ។

ដានី ៖ ជុំ?

ថែម ៖ ចា៎! ជុំ ជឹម ។

ដានី ៖ ជុំ ជឹម ។ ឪពុកអ៊ំមានគ្រួសារក្រោយទៀត?

ថែម ៖ គាត់ដល់ខ្ញុំធំទៅ ក្រមុំហើយបានគាត់យកប្រពន្ធទៀត ម៉ែក្រោយ ។

ដានី ៖ គាត់ឈ្មោះអីដែរ?

ថែម ៖ ឈ្មោះ ពេជ គឿន ម៉ែក្រោយ ។ ចឹងម៉ែក្រោយគាត់ចិត្តល្អដែរ ខ្ញុំរក្សាគាត់ ទើបទៅធ្វើបុណ្យ គាត់ស្លាប់អស់ហើយ១០០ថ្ងៃទាំងថ្ងៃនឹង ។

ដានី ៖ អូ! គាត់ទើបនឹងស្លាប់ដែរ?

ថែម ៖ ចា៎! ទើបស្លាប់ឆ្នាំនឹង ។

ដានី ៖ ស្លាប់?

ថែម ៖ ខ្ញុំទៅធ្វើបុណ្យនៅនេះហើយ ខ្ញុំទៅធ្វើបុណ្យឲ្យគាត់១០០ថ្ងៃ ។

ដានី ៖ អ៊ំធ្វើបុណ្យបច្ច័យបួននេះហើយ បានទៅធ្វើបុណ្យឲ្យគាត់១០០ថ្ងៃឲ្យគាត់នៅម៉ាឡៃ?

ថែម ៖ ចា៎! នៅម៉ាឡៃ ជាមួយប្អូនៗខ្ញុំ ។

ដានី ៖ ចុះអ៊ំបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់ដែរ?

ថែម ៖ បងប្អូនបង្កើតរបស់ខ្ញុំទាំងអស់៨នាក់ដែរ ផ្ទះនេះស្លាប់មួយទើបនឹងស្លាប់ឆ្នាំនេះដែរ ។

ដានី ៖ ៨នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ថែម ៖ ស្រី៥ទាំងខ្ញុំ ។

ដានី ៖ ស្រី៥ទាំងអ៊ំ ហើយប្រុស?

ថែម ៖ ប្រុសតែ៣ ។

ដានី ៖ ស្លាប់អស់ប៉ុន្មាននាក់ហើយ បងប្អូនអ៊ំទាំង៨នាក់?

ថែម ៖ ប្អូនៗ?

ដានី ៖ ដូចថាបងប្អូនបង្កើតទាំង៨នាក់ គាត់នៅរស់ទាំង៨?

ថែម ៖ នៅរស់ទាំង៨នាក់ ប៉ុន្តែស្លាប់កាលជំនាន់យើងសង្គ្រាម២ ទាំងអស់វា១០នាក់នោះ ។

ដានី ៖ ១០នាក់ ស្លាប់ក្នុងសង្គ្រាម២ ស្រីប្រុសស្លាប់ក្នុងសង្គ្រាម២នាក់?

ថែម ៖ ប្រុសៗ ។

ដានី ៖ ចុះអ៊ំថាប្អូនទើបនឹងស្លាប់នៅមុខនេះ?

ថែម ៖ ហ្នឹងប្អូនបន្ទាប់ ។

ដានី ៖ ចឹងសព្វថ្ងៃនៅសល់ប៉ុន្មាននាក់?

ថែម ៖ សព្វថ្ងៃនេះនៅសល់៧ ។

ដានី ៖ សល់៧នាក់?

ថែម ៖ ចា៎!

ដានី ៖ ចឹងគាត់នៅផ្ទះមុខនេះ គឺប្អូនបន្ទាប់អ៊ំ?

ថែម ៖ ចា៎! បន្ទាប់ខ្ញុំស្លាប់ដែរ ។

ដានី ៖ ចឹងសព្វថ្ងៃសល់៧នាក់ទេ?

ថែម ៖ ៧នាក់ នៅម៉ាឡៃ៦ នៅមុខនេះមកមួយ ។

ដានី ៖ នៅតែម្នាក់អ៊ំ?

ថែម ៖ ចាំ! កាលនេះនៅ២ ដល់ឥឡូវស្លាប់មួយនៅសល់១ ។

ដានី ៖ ចឹងនៅម៉ាឡៃច្រើន៦នាក់?

ថែម ៖ ៦នាក់ ។

ដានី ៖ ចុះអ៊ំជាកូនទីប៉ុន្មាន?

ថែម ៖ ទី១ ។

ដានី ៖ បងគេបង្អស់?

ថែម ៖ ចាំ! បងគេបង្អស់ខ្ញុំ ។

ដានី ៖ អ៊ំកាលពីក្មេងៗ បានទៅសាលារៀនសូត្រអីដែរអត់?

ថែម ៖ បាន អាយុ៧ឆ្នាំ ខ្ញុំចូលសាលាវត្ត ។

ដានី ៖ អាយុ៧ឆ្នាំ អ៊ំចូលសាលាវត្ត?

ថែម ៖ ចាំ!

ដានី ៖ អ៊ំរៀនសូត្រអីបានដល់ថ្នាក់ណាដែរ?

ថែម ៖ ខ្ញុំរៀនបានដល់ថ្នាក់ទី១០ចាស់ ។

ដានី ៖ រៀនដល់ថ្នាក់ទី១០ចាស់ ។ កាលនឹងកាលពីក្មេងៗអ៊ំមានប្រាថ្នាថា អ៊ំរៀនសូត្រ ចង់ឲ្យរៀនដល់ណា ចង់ធ្វើអីដែរកាលពីក្មេង?

ថែម ៖ ចង់រៀនគេឲ្យបានច្រើនដែរ ប៉ុនដល់ម្តាយស្លាប់ក៏ឈប់ទៅ ហើយដែលខ្ញុំចេះនឹង ខ្ញុំរៀនរដ្ឋាភិបាលយើងបង្កើតអក្ខរកម្ម ។ ចឹងខ្ញុំរៀនបន្តក្នុងថ្នាក់ទី កាលនឹងយើងថ្នាក់ទី១២ហើយ ថ្នាក់ទី១០ចឹង ។ ខ្ញុំនៅរៀនបន្តទាល់ខ្ញុំចេះសរសេរ ចេះអាន ។

ដានី ៖ រៀនឆ្នាំណានឹង?

ថែម ៖ រៀនតាំងឆ្នាំ៦៣ ។

ដានី ៖ កាលនឹងអ៊ំរៀនទៅចេះសរសេរ ចេះអានស្ទាត់ទេ?

ថែម ៖ ចេះសរសេរ ចេះអាន ។

ដានី ៖ អានឹងកាលពេលរៀននៅសាលាវត្ត កាលនឹងអ៊ំអត់ទាន់ចេះសរសេរចេះអាន?

ថែម ៖ នៅទេ ចេះត្រឹមចប់ ក ខ ហើយបំបែកនមោ មុនដំបូងយើងចាប់ផ្តើម នមោ ក ខ ស្រះ ដល់ចប់ពានឹងទៅ បានបំបែក ។

ដានី ៖ ដល់ពេលអ៊ំរៀនអក្ខរកម្មទៅបានចេះ?

ថែម ៖ ចាំ!

ដានី : កាលនឹងអ៊ំគិតថា ការរៀនសូត្រវាមានសារៈសំខាន់អីដែរអត់ កាលពីអ៊ំនៅក្មេងៗ ហើយក៏រៀនក្រោយៗមកទៀត?

ថែម : ខ្ញុំគិតថា មានសារៈសំខាន់ចំពោះខ្លួន ដែលយល់ដឹងហើយគ្រប់បែបយ៉ាងទាំងអស់ ទាល់តែចេះអក្សរ ។

ដានី : ទាល់ចេះអក្សរ?

ថែម : ចា៎! បើយើងចេះអក្សរទៅ យើងមើលជាសៀវភៅ ជារឿង ជាកំណាព្យជាអីដឹងទាំងអស់ ។ កាលជំនាន់នោះ ខ្ញុំចេះអានសៀវភៅនឹង លោកតា ង៉ុយ ។

ដានី : លោកតា ក្រម ង៉ុយ?

ថែម : ចា៎! លោកតា ក្រម ង៉ុយ គាត់លើកកំណាព្យដើរថែកតាមភូមិ ហើយខ្ញុំបានយកមកមើលចាំទាំងអស់ ។ មើលចាំហើយក៏គេលក់រឿង ដូចរឿងចិន រឿងវៀតណាមអី ដែលគេតស៊ូជំនាន់មុនៗ យើងកើតសង្រ្គាមម៉េះ យកមកមើល ។ ដល់មើលចេះចឹង ដល់ឃើញដូចថាចាស់ៗអី ឃើញយើងមានចំណង់ចិត្តចំណូលខាងចេះដឹង គាត់ក៏ចេះតែគាំទ្រ អាណិតអាសូររហូតចាស់ៗចូលចិត្តនឹងខ្ញុំណាស់ ។

ដានី : ចុះអ៊ំដល់ពេលអ៊ំមានកូនមានចៅហើយ អ៊ំដែលដូចថាជំរុញកូនឲ្យរៀនសូត្រ ឬក៏ណែនាំកូនពីសារៈសំខាន់នៃការរៀនសូត្រដែរអត់?

ថែម : ជំរុញ ។

ដានី : ជំរុញដែរ?

ថែម : ចា៎! ខ្ញុំឆ្នាំ៨២ ៨៣ រហូតមកឲ្យកូនរៀនតាមព្រៃតាមផ្ទៃ ទោះបីនៅមួយខែពីរខែខ្ញុំរៀបចំមានគ្រូមានសិស្សរៀនដែរ ។ ហើយខ្ញុំទទួលប្រជាជននឹង មាន២-៣ភូមិចឹងទៅ ហើយនឹងប្រពន្ធទាហាន ទៅដល់ណាក៏ខ្ញុំបង្កើតសាលា ។ ចឹងកូនខ្ញុំបានរៀន កូនគេក៏បានរៀន កូនខ្ញុំក៏បានរៀន ។

ដានី : យើងម៉េច យើងបង្កើតជាសាលា?

ថែម : ចា៎! ធ្វើសាលា ហៅប្រជាជនប្រជុំឲ្យធ្វើសាលាប៉ុននឹងរៀន ។

ដានី : ហៅប្រជាជនឲ្យធ្វើសាលាចឹងទៅ យើងមានគ្រូមានអីដែរ?

ថែម : មាន អ្នកចេះ ។

ដានី : គ្រូមកពីខាងណា?

ថែម : គ្រូគាត់ត្រូវបងប្អូនដែរ ប៉ុនគាត់រៀនបានច្រើន ថ្នាក់ទី៧កាលពីសង្គមចាស់ ចឹងឲ្យគាត់ធ្វើតែគ្រូរហូត ។ ឥឡូវស្លាប់ៗធ្វើបុណ្យ១០០ថ្ងៃ១៥រោចនេះខ្ញុំទៅដែរ ព្រះវិហារ ។

ដានី : គាត់ឈ្មោះអី?

ប៉ែម : ឈ្មោះ ញៀន ។

ដានី : ឈ្មោះ ញៀន?

ប៉ែម : ចាំ!

ដានី : គាត់បង្រៀនកូនសិស្ស នៅពេលដែលយើងធ្វើសង្គ្រាម កាលនៅលើភ្នំពួកគាត់បានបង្រៀនដែរ?

ប៉ែម : ចាំ! បង្រៀន គាត់បង្រៀនតែសិស្សរហូតក្មេងៗនឹង បង្រៀនកូនគាត់នឹងដល់បែកគ្នា គាត់ទៅតាមឪគាត់នៅព្រះវិហារ ឲ្យតាបង្រៀន ។

ដានី : ឲ្យតាបង្រៀបម្តង?

ប៉ែម : ចាំ! តាគាត់ចេះបង្រៀន បន្ទាត់ចាស់ អឺ!ក្មេងៗវាធំៗ ។

ដានី : បង្រៀន គ្រាន់ឲ្យចេះសរសេរ ចេះអាន?

ប៉ែម : ចាំ! ឲ្យចេះអាន ចេះសរសេរទៅ ទម្រាំយេងមានកន្លែងនឹងនរ បាន តា ម៉ុក គាត់រៀបចំ ។ ហើយដល់ឃើញយើងរៀបចំបាន មានកូនសិស្ស មានសាលា មានអីចឹង គាត់ចូលចិត្តដែរ គាត់ជួយខបត្ថម្ភអីចេះចុះ ខោអាវ ។

ដានី : ចុះអ៊ំបន្ទាប់ពីអ៊ំឈប់រៀន កាលពីក្មេងៗ អ៊ំឈប់រៀនបានថ្នាក់ទី១០ បន្ទាប់ពីឈប់រៀនទៅអ៊ំធ្វើអីទៀតទៅ?

ប៉ែម : ខ្ញុំឈប់រៀនទៅ ខ្ញុំរកស៊ីចិញ្ចឹមប្អូនៗខ្ញុំដែលម៉ែខ្ញុំស្លាប់ទៅនឹង រហូតមកបានដល់ឪខ្ញុំគាត់មានប្រពន្ធទៀត គេចង់បានចូលនិយាយ ។ ខ្ញុំឈប់រៀន ក៏ខ្ញុំចេះអានចេះសរសេរ ។

ដានី : ដល់ពេលអ៊ំធំទៅ រកស៊ីចិញ្ចឹមប្អូនៗរហូត ដល់ពេលនេះបានអ៊ំរៀបការ?

ប៉ែម : ចាំ! ការ ។

ដានី : អ៊ំរៀបការឆ្នាំណា?

ប៉ែម : ខ្ញុំការគ្រួសារនឹង ឆ្នាំ៦៥ ។

ដានី : រៀបការជាមួយអ៊ំប្រុស?

ប៉ែម : ចាំ!

ដានី : អ៊ំប្រុសយ៉ាងម៉េច បានគាត់? កាលនឹងយ៉ាងម៉េចបានអ៊ំអាចរៀបរាប់ពីដំណើរដូចថាមុនរៀបការ គាត់ទាក់ទងអ៊ំម៉េចបានចូលស្តីដណ្តឹងអ៊ំ?

ថែម ៖ ខ្ញុំត្រូវជាបងប្អូនសាច់ឈាមដែរ ហើយចាស់ៗ ឪខ្ញុំត្រូវប្អូនពុកក្មេកនឹងជីដូនមួយ ដល់គាត់ឃើញខ្ញុំគាត់អាណិតៗ គាត់មកនិយាយនឹងឪខ្ញុំមក ដល់ឪខ្ញុំឲ្យទៅ ព្រោះគិតធ្វើផ្ទះធ្វើអី ពីដើមសុទ្ធតែធ្វើផ្ទះៗ

ដានី ៖ អានឹងពេលដែលដូចថា អ៊ំប្រុសពេលមកដណ្ដឹងអ៊ំ ទាល់តែគាត់ធ្វើផ្ទះធ្វើអី បានអាចការបាន?

ថែម ៖ ចា៎! បានការបានៗ ខ្ញុំម៉ែក្មេកខ្ញុំចូលស្ដីតាំងពីអាយុ១២ឆ្នាំ ខ្ញុំ១៩ឆ្នាំបានខ្ញុំការៗ

ដានី ៖ ១៩ឆ្នាំបានការ?

ថែម ៖ ចា៎!

ដានី ៖ កាលនឹងគាត់ធ្វើផ្ទះបានទេ?

ថែម ៖ ធ្វើបានៗ

ដានី ៖ គាត់ធ្វើបាន?

ថែម ៖ ចា៎!

ដានី ៖ ធ្វើផ្ទះហើយបានអ៊ំការ?

ថែម ៖ ចា៎!

ដានី ៖ អ៊ំការឆ្នាំ៦៥?

ថែម ៖ ចា៎! ៦៥ៗ

ដានី ៖ ដល់ពេលអ៊ំការហើយ អ៊ំប្រកបមុខរបររកស៊ីធ្វើអីទៀតទៅ?

ថែម ៖ ធ្វើស្រែធ្វើចំការៗ

ដានី ៖ នៅក្នុងភូមក្បាលអូរតែមួយ ឬក៏យើងបែក?

ថែម ៖ ខ្ញុំការបានមួយឆ្នាំ ខ្ញុំបែកចេញពីម៉ែក្មេក ព្រោះឪក្មេកខ្ញុំស្លាប់ទៅ បែកចេញទៅខ្ញុំទៅរកស៊ីនៅភ្នំខាងកំពង់ស្ពឺនោះៗ

ដានី ៖ គេហៅភ្នំអីនឹង?

ថែម ៖ ហៅភ្នំដាច់ ភ្នំកន្លែងឈ្មោះគេចាស់ ឈ្មោះ តាអ៊ាំៗ

ដានី ៖ ភ្នំតាអ៊ាំ?

ថែម ៖ ចា៎! ប៉ុន្តែភ្នំនឹងម៉ង គេហៅភ្នំដាច់ៗ

ដានី ៖ ហៅភ្នំដាច់?

ថែម ៖ ចា៎!

ដានី ៖ អ៊ំទៅរកស៊ីអីគេនឹង?

ថែម ៖ ទៅកាស់ដីធ្វើស្រែធ្វើចំការដែរ ។

ដានី ៖ យើងទៅកាប់ឆ្ការព្រៃ ធ្វើដីធ្វើ?

ថែម ៖ ចា៎!

ដានី ៖ កាលនឹងកាលជំនាន់ឆ្នាំ៦០ដាផងនឹង នៅខាងកំពង់ស្ពឺ ខាងភ្នំនឹង អត់ទាន់មានមនុស្សច្រើន នៅមានដីទំនេរអាចកាប់ឆ្ការ ធ្វើស្រែចំការ?

ថែម ៖ ចា៎! ភូមិតាអ៊ុំៗ ភូមិនឹងធំ ហើយខ្ញុំទៅនៅជិតនឹង ។ នៅជិតនឹងមានដីវាលធំៗ ។ នាំគ្នាទៅនៅនឹង១០គ្រួសារ ។ ប៉ុនឥឡូវគាត់ស្លាប់អស់ហើយ នៅតែខ្ញុំ ។

ដានី ៖ មកពីស្រុក ១០គ្រួសារនឹង អ្នកស្រុកអ្នកភូមិពីក្បាលអូរទៅ?

ថែម ៖ អ្នកស្រុកពីក្បាលអូរទៅទាំងអស់ ។

ដានី ៖ ទៅ១០គ្រួសារ ទៅធ្វើម៉េច យើងកាប់ចំការ?

ថែម ៖ ចា៎! កាប់ចំការ ។

ដានី ៖ ឆ្នាំណានឹង ឆ្នាំ?

ថែម ៖ ឆ្នាំ៦៥ដែរ អឺ!៦៦ ៦៧ ដល់៦៨យើងផ្ទុះអាវុធលើកទី១ ។

ដានី ៖ ចឹងអ៊ំពីឆ្នាំ៦៦ ដែលអ៊ំទៅនៅកន្លែងតាអ៊ុំ នៅកន្លែងភ្នំដាច់នឹង យើងទៅកាប់ចំការធម្មតាទេ?

ថែម ៖ ចា៎!

ដានី ៖ កាលនឹងអ៊ំមិនទាន់ចូលតស៊ូ ចូលបដិវត្តន៍អីទេ?

ថែម ៖ អត់ទេ ដូចថាដីធ្លីវាតិច ហើយចេះតែទៅរកធ្វើស្រែធ្វើចំការ ។

ដានី ៖ កាលនឹងទៅកាប់ចំការកាប់អី បានធ្វើស្រែធ្វើចំការអត់នៅខាងតា អ៊ុំ?

ថែម ៖ ធ្វើបាន បានហូបអត់អស់ នៅដំឡូង ចំការដំឡូង ចំការពោតអីហូបអត់អស់ទេ ។ អ្នកស្រុកនឹងគេមកទិញដូរស្រូវដូរអី បានមួយឆ្នាំ ។ ២ឆាំបានផ្ទុះអាវុធៗ ទៅជាកើតខ្មែរក្រហមនឹង ។

ដានី ៖ ផ្ទុះអាវុធនៅណា?

ថែម ៖ ផ្ទុះអាវុធ មុនដំបូងឮថានៅបាត់ដំបង ។

ដានី ៖ នៅសំឡូត?

ថែម ៖ ចា៎! ដល់រួចមកខ្ញុំនៅជិតស្រុកគេនឹងឃើញទាញ កាលនឹងទាហានមិនចេញគ្រប់កន្លែងទាំងអស់ ដើររកអ្នកតស៊ូខ្មែរក្រហម ។

ដានី ៖ អឺ! ទាហានគេដើររកចាប់?

ថែម ៖ ចា៎! ដើររកចាប់ៗ បានប្អូនខ្ញុំមួយដែរតើ ។

ដានី ៖ កាលនឹងឆ្នាំប៉ុន្មាន គេផ្ទុះអាវុធ ហើយគេចាប់ផ្ដើមចេញ?

ថែម ៖ ឆ្នាំ៦៨ ។

ដានី ៖ ឆ្នាំ៦៨?

ថែម ៖ ចា៎! ៦៨ចង់ដាច់ហើយចូល៦៩ ។

ដានី ៖ ដល់ពេលចឹងទៅ គេដើរចាប់គេដើរអីចឹងទៅ គេទៅចាប់ប្អូនអ៊ំនៅណាទៅ?

ថែម ៖ នៅអី គេហៅវាលលំហាចៗភ្នំណា៎ ។

ដានី ៖ ឯភ្នំដាច់នឹង?

ថែម ៖ ចា៎!

ដានី ៖ នៅក្នុងភូមិដែលអ៊ំទៅកាប់រានដីធ្វើចំការធ្វើស្រែនឹង?

ថែម ៖ អត់ទេ នែក!វាដូចថានាំឯកសារពីតាកែវទៅកំពង់ស្ពឺ ដល់ត្រឡប់មកវិញ កន្លែងដែលធ្លាប់នៅមិត្តយើងទៅនៅចឹង មានផ្ទះមានសម្បែង ផ្ទះស្នាក់ចូលមកស្នាក់ ។ ទាហានវាទៅចាំគេ ចុះមិត(រត់)អសទៅ ទាហានវាទៅចាំលើផ្ទះនឹង ដល់វាមកឡើងភ្លែត ចុះធ្លាប់ផ្ទះស្នាក់ ។

ដានី ៖ ផ្ទះយើងស្នាក់នៅ?

ថែម ៖ ហ្នឹងមកដល់ឡើងមកគេចាប់ជាប់ ។ ខ្ញុំមើលឃើញ ប៉ុនចេះតែឆ្ងល់ដែរ ឃើញគេបណ្ដើរច្រើន ដើរឆ្ងាយ ប៉ុនវាលៗមើលឃើញ ។ ដល់គ្រាន់យប់ប្រហែលម៉ោង៨, ២នាក់នោះរត់វាដើរក្រោយវារត់មកវិញ ក្មេងៗគេចាប់ប្អូនខ្ញុំធំជាងគេ ។

ដានី ៖ ចាប់ទៅប៉ុន្មាននាក់?

ថែម ៖ ចាប់តែម្នាក់ ចាប់តែប្អូនខ្ញុំមួយ ដល់ចាប់ទៅមានសំបុត្រនៅជើងអាវ យកទៅដាក់គុកនៅត្រពាំងក្រឡឹង បានមួយអាទិត្យ បានអ្នកជាប់គុកនឹងគេចេញមកគេប្រាប់ថា ប្អូនបងឯងគេយកសម្លាប់បាត់ហើយ គេចងនឹងដើមឈើ ហើយវះពោះទាំងរស់ ។

ដានី ៖ កាលនឹងទាហានខាងសម្ដេចនៅឡើយ?

ថែម ៖ ចា៎! ទាហាន លន់ នល់ ។

ដានី ៖ កាលនឹងប្អូនអ៊ំគាត់ឈ្មោះអីដែរ?

ថែម ៖ ប្អូនខ្ញុំនឹងឈ្មោះ អ៊ុ ឈ្មោះ អ៊ឹម អ៊ុ ។

ដានី ៖ អ៊ឹម អ៊ុ នឹងប្អូនបន្ទាប់អ៊ំ ហើយអ៊ំប្អូនយ៉ាងម៉េច?

ថែម ៖ ប្អូនបន្ទាប់ ប្អូនទី៣ ។

ដានី :	ចឹងប្អូនទី១ គាត់ទី២ ហើយប្អូនទី៣ ប្អូនប្រុស?

ថែម :	ចាំ! ទី៣ ។

ដានី :	កាលនឹងគាត់រត់សំបុត្រអីយ៉ាងម៉េច បានគេចាប់គាត់ចឹង?

ថែម :	សំបុត្រដូចថាគេទាក់ទងគ្នាជាខ្សែរយៈ ដូចយើងពីឃុំមួយទៅឃុំមួយចឹង ។

ដានី :	កាលនឹងគាត់នៅជាមួយពីណាគេ បានគាត់រត់សំបុត្រ ពីឃុំមួយទៅឃុំមួយ?

ថែម :	នៅជាមួយ តា ម៉ុក ។

ដានី :	គាត់នៅជាមួយ តា ម៉ុក?

ថែម :	ចាំ!

ដានី :	នៅផ្ទាល់ជាមួយ តា ម៉ុក ម៉ង?

ថែម :	ចាំ!

ដានី :	ចឹងដល់ពេលគាត់រត់ចឹងទៅ ទាហានម៉េចបានទាហានដឹង?

ថែម :	វាគិញនៅភូមិគេនឹង ។

ដានី :	គិញគេប្រាប់?

ថែម :	ហ្នឹង ។

ដានី :	កាលនឹងពេលដែល អានឹងក្នុងឆ្នាំ៦៨ ហើយក៏ឆ្នាំណា?

ថែម :	៦៨ ។

ដានី :	កាលនឹងអ៊ំចូលធ្វើការជាមួយ តា ម៉ុក ពេលនឹង?

ថែម :	ខ្ញុំគ្រាន់តែស្គាល់ទេ ។

ដានី :	គ្រាន់តែស្គាល់ទេ?

ថែម :	ចាំ!

ដានី :	អត់ទាន់ធ្វើការអីជាមួយគាត់ទេ?

ថែម :	អត់ទេ ប៉ុនគ្រាន់ប្អូនខ្ញុំគាត់ប្រើចឹង ដូចថាយើងឃើញមនុស្សល្អចឹង ចេះហៅប្រើនាំគេ ហៅនាំសារៗ ។

ដានី :	ចុះកាលនឹង តា ម៉ុក គាត់នៅម្តុំណា?

ថែម :	គាត់នៅក្នុងភូមិនឹងដែរ ប៉ុនដើរនៅតែពាស ប៉ុនគាត់ដើរនៅតែពាស នៅនេះតិចនោះតិច

ដានី :	គាត់នៅភូមិជាមួយអ៊ំដែរ?

ថែម :	ចាំ! គាត់ទៅនៅនឹងដែរ ប៉ុនគាត់មិនទៅអ្នកចេញមុខអីគាត់ ។

ដានី :	កាលនឹងអ៊ំអត់ទាន់ធ្វើការអីជាមួយគាត់ទេ?

ថែម : អត់ទេ ។

ដានី : ចុះអ៊ំបន្ទាប់ពីគេចាប់ប្អូនអ៊ំទៅត្រពាំងក្រឡឹង ហើយគេថាសម្លាប់គេវះពោះអីនឹង កាលនឹងគេចាប់សំបុត្របាន សំបុត្រនឹងសរសេរយ៉ាងម៉េចគេ?

ថែម : សរសេរដូចថាទាក់ទងជួបគ្នាអី មេៗ ។

ដានី : អឺ! ទាក់ទងជួបគ្នា ។ បន្ទាប់ពីគេសម្លាប់ប្អូនអ៊ំហើយ យ៉ាងម៉េចទៀតទៅអ៊ំ?

ថែម : ហ្នឹងរដ្ឋប្រហារ ដល់តែចូលឆ្នាំ៦៩នេះ ខ្ញុំមកស្រុកវិញ ត្រឡប់មកស្រុកវិញៗគេចាប់ទៀត ។

ដានី : គេចាប់ពីណាគេ?

ថែម : គេចាប់ខ្ញុំយកទៅដាក់ឃុំឃាំងនៅកន្លែងប៉ុស្តិ៍អន្តរកា ។

ដានី : ចាប់ដាក់ប៉ុស្តិ៍អន្តរកា កន្លែងនឹង កន្លែងទាហាន លន់ នល់?

ថែម : ចា៎! កន្លែងទាហានលន់ នល់ ។ គេថា ហើយខ្ញុំទៅតែឯងទេ តែកូន ប្តីខ្ញុំ ដល់ចឹងទៅដូចថាបែកមុខផ្ទុះ ។

ដានី : គេថាយើងម៉េច គេចោទយើងថាម៉េច?

ថែម : កាលនឹង គេថាយើងខ្មែរខទាម ចោរព្រៃ ។

ដានី : ចោរព្រៃ?

ថែម : ហ្នឹង ។

ដានី : ដោយសារកាលនឹងយើង តា ម៉ុក អីគាត់នៅជាមួយ?

ថែម : ចា៎! ប៉ុន្តែគេដាក់ឈ្មោះចឹងម៉ង គេថាយើងចោរព្រៃ ខ្មែរខទាម ដល់ក្រោយមកបានដាក់ឈ្មោះ ខ្មែរក្រហម ។

ដានី : ចុះអ៊ំពេលដែលគេចាប់ទៅអន្តរកា ចាប់ទៅ?

ថែម : ចាប់យកទៅឃុំឃាំង ក្រែងលរប្តីមកទាក់ទងអី យើងទាក់ទងជាមួយប្តី ។

ដានី : ចុះគេចាប់ឃុំឃាំង ប្តីអ៊ំគាត់មានទៅទាក់ទងទៅមានអីទៀតអត់?

ថែម : អត់ ។

ដានី : ឃុំឃាំងបានរយៈពេលប៉ុន្មានទៅ?

ថែម : ដល់តែឆ្នាំ៧០ ធ្វើរដ្ឋប្រហារ បានខ្ញុំឈប់នៅ ។

ដានី : ចេញពីកន្លែង?

ថែម : ចា៎! ចេញពីកន្លែងគេយកទៅដាក់ឃុំឃាំង ។

ដានី : ចឹងបានរយៈពេលប៉ុន្មានទៅ?

ថែម ៖ មួយឆ្នាំដែរនឹង ជាន់មួយឆ្នាំជាង ។

ដានី ៖ ជាប់មួយឆ្នាំដែរ?

ថែម ៖ ចា៎!

ដានី ៖ ពេលដែលជាប់មួយឆ្នាំនោះ គេមានធ្វើអីខ្លះ ដូចថាគេមានធ្វើទារុណកម្ម គេមានសួរចម្លើយ គេមានធ្វើម៉េចអីដែរ?

ថែម ៖ គេមកសួរ មានប្តីមកទាក់ទងទេ យើងឆ្លើយថាអត់ ។ ហើយដល់ក្រោយមក គា នឹងទៅម្តង ជាប់ គេនៅតែសួរចឹង ប៉ុនយើងថាអត់ៗដឹងវល់តែគេយកទៅនោះដែរ មិនបានទាក់ទង ។

ដានី ៖ ចឹងប្តីអីក៏ជាប់នៅនឹងដែរ?

ថែម ៖ ទៅព្រៃនៅព្រៃ ។

ដានី ៖ ទៅនៅក្នុងព្រៃបាត់ហើយ?

ថែម ៖ ហ្នឹងនៅក្នុងព្រៃបាត់ ។

ដានី ៖ ចឹងអីជាប់នៅនឹង គេអត់មានធ្វើបាប ធ្វើអីអីទេ?

ថែម ៖ គេគ្រាន់គំរាម ។

ដានី ៖ គេគ្រាន់គំរាមថាម៉េច?

ថែម ៖ គំរាម សួររកប្តីនឹង យើងថាអត់ដឹង ។ ហើយថាបាច់កុហកគេទេ ហើយថាឲ្យស្បថៗខ្ញុំហ៊ានស្បថ ។

ដានី ៖ ហ៊ានស្បថ?

ថែម ៖ ហ្នឹងគេទៅអង្គតាសោមទៅ ទៅពីកន្លែងស្រុកនឹង ។

ដានី ៖ ទាហានគេទៅពីអង្គតាសោម ពីស្រុកទៅ?

ថែម ៖ ចា៎ៗ ទៅសំឡុតដែរនឹង ។ ដល់ហើយគេសំឡុតទៅ គេនិយាយលួងលោមថា បងឥឡូវបងឯងរកស៊ីអីចិញ្ចឹមកូនទាំងពីរបាន? ខ្ញុំថា ខ្ញុំរកស៊ីអីបើលោកយកខ្ញុំមកទុកចឹង បើលោកឲ្យខ្ញុំទៅផ្ទះវិញ ទៅរកស៊ីចិញ្ចឹមកូនខ្ញុំ អានឹងបានៗ បើលោកយកខ្ញុំមកទុកចឹងៗមានលោកចិញ្ចឹមខ្ញុំវិញ ។ ខ្ញុំចេះតស៊ូខាងពាក្យសម្តីដែរ ។

ដានី ៖ ដល់ពេលថាចឹង គេថាម៉េច?

ថែម ៖ ដល់វាថាចឹង ខ្ញុំមានរោងល្ខោន រោងមួយសម្រាប់ឲ្យបងឯងគ្រប់គ្នានឹង ទៅឈរលក់ផ្កាទៅរាំឲ្យពួកខ្ញុំរាំគេឲ្យលុយ យកមកចិញ្ចឹមកូន ។ ខ្ញុំថាអត់ទេ ខ្ញុំអត់ចេះរាំចេះអី ខ្ញុំមិនចេះបើឲ្យខ្ញុំទៅផ្ទះទៅរកស៊ីធ្វើស្រែធ្វើចំការ ចិញ្ចឹមកូនខ្ញុំអានឹងខ្ញុំចេះ បើឲ្យខ្ញុំទៅធ្វើចឹងៗ ខ្ញុំ

អត់ចេះទេៗ ថាអឺ! ចឹងបើមិនចេះរាំទេ គ្រាន់ទៅឈរលក់ផ្កាក៏បានដែរ ចាំឲ្យពួកគេមកវិញ ទាហានៗនឹង ចាំឲ្យពួកទាហាននឹងមកវិញៗ ដល់ខ្ញុំថាអត់ទេៗ គ្រាន់ឈរលក់ៗ ខ្ញុំថាឈរអីក៏ខ្ញុំមិនឈរដែរ ហៅខ្ញុំទៅសួរនៅផ្ទះមេឃុំៗ ដល់ម៉េចក៏ខ្ញុំមិនព្រមៗ វាទៅវិញទៅៗ ទៅវិញមេឃុំហៅប្រាប់ថា បងៗឯងថ្ងៃក្រោយកុំ បើវាហៅវាទៅអី បងឯងស្រវ៉ារត់មកផ្ទះខ្ញុំ កុំឲ្យវាស្តីវាគំរាមយើង អាអស់នឹងវានៅក្រោមបន្ទាប់ខ្ញុំដែរទេ ហើយឃើញគេមកផ្ទះវែកដួង វែកអីបន្ទែយកទៅឲ្យទាហាននឹង គាត់ថាបើមានកុំឲ្យពួកនឹងស៊ី ហើយមេឃុំនឹងយើងទុកនៅ ទើបនឹងស្លាប់ៗ

ដានី : មេឃុំឈ្មោះអី?

ថែម : ឈ្មោះ ដឹមៗ

ដានី : ឈ្មោះ ដឹម?

ថែម : ចា៎!

ដានី : គាត់មេឃុំខាងលន់ នល់ ខាងសម្តេច?

ថែម : កាលជំនាន់នោះ មេឃុំខាងសម្តេចៗ

ដានី : ខាងសម្តេច គាត់ជួយអីដែរ?

ថែម : គាត់ជួយយើងច្រើនដែរ ព្រោះភូមិជិតគ្នាផង ប៉ុនឃុំនឹងគាត់ជួយទាំងអស់ៗ

ដានី : គាត់មេឃុំអី?

ថែម : មេឃុំជាងទងនឹងៗ

ដានី : មេឃុំជាងទងនឹងដែរ?

ថែម : ចា៎!

ដានី : ហ្នឹងគាត់ជួយអីដែរ?

ថែម : ចា៎! ជួយៗ

ដានី : កាលនឹងអ៊ំមានកូន២នាក់?

ថែម : ២នាក់ៗ

ដានី : កូនស្រី កូនប្រុសកាលនឹង២នាក់?

ថែម : នេះមួយបងគេនឹង ហើយអាមួយស្លាប់ទៅៗ

ដានី : ចុះកាលនឹង កូនអ៊ំ២នាក់នឹង អ៊ំទុកនៅណាទៅ បើអ៊ំកន្លែងជាប់គុក ហើយអ៊ំប្រុសគាត់នៅក្នុងព្រៃ?

ថែម ៖ ទុកនៅជាមួយយាយ មីងខ្ញុំបង្កើតនៅផ្ទះ នៅស្រុក ទុកនៅខ្ញុំមកដល់២-៣ថ្ងៃ ខ្ញុំសុំគេទៅយកកូនទៅ ហើយទុកមួយយកមកមួយចឹង ។ អស់អង្ករអស់អីចេះតែសុំគេ យើងយកអង្ករមកចំនួន២-៣ថ្ងៃ ដល់អស់អង្ករសុំគេៗទៅបានជួបកូន ។ ចឹងប្រវត្តិរបស់ខ្ញុំជូរចត់ដែរ ។

ដានី ៖ ចឹងអ៊ីជាប់នៅកន្លែងគេ អង្ករកានីងរហូតដល់រដ្ឋប្រហារឆ្នាំ៧០ម៉ង?

ថែម ៖ ចា៎! ដល់ឆ្នាំ៧០នឹង គេធ្វើរដ្ឋប្រហារខ្ញុំតស៊ូជាមួយ គេហៅគិញៗផ្សារ ។ ខ្ញុំមុនដំបូងទៅសុំគេៗអត់ឲ្យមកៗខ្ញុំថាអត់ទេ ឥឡូវកូនខ្ញុំនៅផ្ទះអត់មានអីស៊ី ហើយគេឈប់មើល គង់ពួងឯងមិនឲ្យខ្ញុំទៅក៏ខ្ញុំទៅដែរពេលនេះ ។ ដល់គាត់ដឹងថាម៉េច គាត់អឺ!ក្មួយឯងកុំខឹងនឹងពូ ។ ខ្ញុំថាខ្ញុំអត់ខឹងអីទេ ប៉ុនឥឡូវឲ្យខ្ញុំទៅផ្ទះ ព្រោះកូនខ្ញុំនៅផ្ទះ អង្ករក៏អត់អីក៏អត់ ។ ដល់គាត់ឲ្យមកៗខ្ញុំលែងទៅរហូត ។ លែងទៅក៏រដ្ឋប្រហារនឹងបណ្តោយ ។

ដានី ៖ មុនរដ្ឋប្រហារទៀត ចឹងមកផ្ទះមុនរដ្ឋប្រហារ?

ថែម ៖ មុនៗប្រហែលកន្លះខែ ។

ដានី ៖ ហើយម៉េចទៀតទៅ ដល់ពេលយើងមកដល់ផ្ទះ?

ថែម ៖ យើងមកដល់ផ្ទះរកស៊ីធម្មតា ដូចគេដូចឯងធ្វើស្រែធ្វើចំការ គេធ្វើអីយើងធ្វើនឹង ដើម្បីចិញ្ចឹមកូន២នាក់បងប្អូន រហូតមកឆ្នាំ៧១ ដែលឆ្នាំ៧០អ្នកទៅព្រៃត្រឡប់មកវិញ ចេះចូលមកស្ងាត់ៗ ។ ស្គាល់ដូចថាម៉ាភូមិចឹង ស្គាល់ខ្ញុំចឹង គាត់ចូលមកទាក់ទង ឲ្យយើងតស៊ូអីចេះចុះ ប៉ុន តា ខ្ញុំអត់មានមកស្រុកទេ នៅខាងកំពង់ស្ពឺ ។ ដល់ឆ្នាំ៧២ តា ម៉ុក គាត់សុំឲ្យទៅជួបនៅតាកែវ ។

ដានី ៖ សុំអ៊ីឲ្យទៅជួប?

ថែម ៖ ចា៎!

ដានី ៖ ចុះឆ្នាំ៧១នឹង យ៉ាងម៉េចដែរ?

ថែម ៖ ឆ្នាំ៧១នឹង ខ្ញុំគេឲ្យធ្វើសមាគមន៍ប្រវាស់ដៃអីដឹកនាំប្រជាជននៅក្នុងភូមិនឹង យើញខ្ញុំចេះតស៊ូ ទាមទារ ដូចថាដឹងខុសដឹងត្រូវ ។ ចឹងខ្ញុំចេះមានជាក្រុមសមាគមន៍ជួយគ្នា ធ្វើស្រែប្រវាស់ដៃ ចេះលើកគ្នាប្រវាស់ដៃមួយថ្ងៃៗម្នាក់ចឹងទៅ ។ ហើយដល់ចង់ចេះប្រជុំ ។

ដានី ៖ ចេះប្រជុំ?

ថែម ៖ (សើច) ចេះប្រជុំ ក៏ចាស់ៗគាត់ចូលចិត្ត ហើយដល់ពេលធ្វើបុណ្យទានអីដើររៃអង្គាស់ឲ្យគេប្រមូលគ្នាជួយដូចថាមានអង្ករ មានបន្លែ អំបិលប្រហុកអីជួយគ្នា យើងចេះសាមគ្គី ។

ដានី ៖ កាលនឹងចាប់ផ្ដើមសមាគមន៍ប្រវាស់ដៃនឹង នៅក្នុងភូមិក្បាលអូរនឹង ហើយក៏ក្នុងឃុំដាងទង មង?

ថែម ៖ ក្នុងភូមិក្បាលអូរមួយមុនដំបូង ។

ដានី ៖ មុនដំបូងភូមិក្បាលអរ?

ថែម ៖ ចា៎! ដល់គេរៀបចំ៧១នេះ ចូលឆ្នាំ៧១នឹង ខ្ញុំរៀបចំឃុំដាងទងហើយ តាមភូមិទាំងអស់ ហើយក៏មានកើតជាអង្គការ ឲ្យខ្ញុំទៅនៅអង្គភាព ដឹកនាំនារី ។

ដានី ៖ ចឹងដល់ពេលឆ្នាំ៧០ប៉ុន្មានដែលអ៊ំទៅកន្លែងអងការដឹកនាំអង្គភាពនារី?

ថែម ៖ ៧២ ។

ដានី ៖ ចុះអ៊ំមានប្រសាសន៍មិញថា ឆ្នាំ៧២ តា ម៉ុក គាត់សុំអ៊ំឲ្យទៅជួប?

ថែម ៖ ហ្នឹងតានោះទេ មិនមែនខ្ញុំទេ។ សុំតា ញ៉ើន គាត់គ្រួសារខ្ញុំ គាត់ចេញពីព្រៃមកឆ្នាំ៧០ គេគ្រប់គ្នាគេមករកគ្រួសារស្រុក គាត់អត់ទេ គាត់ឲ្យទៅនៅកំពង់ស្ពឺ ខ្ញុំនៅតាកែវ គាត់នៅកំពង់ស្ពឺ ។ ដល់៧២ បានឃើញគាត់ ។

ដានី ៖ គាត់មកស្រុក?

ថែម ៖ ចា៎!

ដានី ៖ គាត់សុំ តា ម៉ុក មក?

ថែម ៖ តា ម៉ុក គាត់ទៅយក ។

ដានី ៖ តា ម៉ុក ទៅយកខ្លួនឯង?

ថែម ៖ ទៅយកខ្លួនឯង ។

ដានី ៖ តា ម៉ុក ទៅយកគាត់មកឲ្យជួបអ៊ំ?

ថែម ៖ ហ្នឹង ។

ដានី ៖ កាលនឹងម៉េចបានគាត់អត់ព្រមមកស្រុក?

ថែម ៖ គាត់គោរពការចាត់តាំង អង្គការគេខាងនោះ ហើយ តា ម៉ុក គាត់ថា ខ្ញុំសុំឲ្យទៅជួបគ្រួសារ ។ ដល់មកលែងឲ្យទៅវិញ ។

ដានី ៖ គាត់នៅជាមួយអ៊ំទៅ?

ថែម ៖ ចា៎!

ដានី ៖ ចឹងប៉ុនដល់ឆ្នាំ៧២ ដែលអ៊ំទៅនៅជាមួយអង្គភាពទៅនៅជាមួយប្រធាននារីនឹង កាលនឹងគ្រួសារ ប្ដីអ៊ំគាត់ទៅជាមួយដែរ?

ប៉ែម : អត់ទេ គាត់នៅកន្លែងយុវជន នៅដូចថាគេបាននាំយុវជនពីមុខមក យើងចេះមានចលនាតស៊ូជាមួយទាហាន លន់ នល់ រ៉ៃគ្នាតាមបន្ទាយតាមអីពីខាងនេះទៅចូលទៅក្នុង។ ដល់ចឹងឲ្យគាត់ក្តាប់យុវជន នៅអប់រំខាងក្រោយនឹង។ ហើយខ្ញុំចេះនៅតាមភូមិតាមអីចឹងទៅ

ដានី : ចុះអំពេលដែលយើងទៅនៅកន្លែងអគ្គភាពនារី កាលនឹងនៅណានៅក្នុងភូមិដដែល ឬក៏យើងអត់នៅក្នុងភូមិទេ?

ប៉ែម : អត់ទេ នឹងខ្ញុំចេញហើយ ចេញទៅនៅអគ្គភាពនារី។

ដានី : នារីនឹងនៅណាទៅ?

ប៉ែម : នារី មុនដំបូងនារីកាត់ដេរ ដល់ក្រោយមកបានចូលអគ្គភាពនារី ដែលមាននារីគេជម្រៀសពីមុនមកយកមកទុកក្រោយ ខ្ញុំទៅអប់រំៗ មានចេះនិយាយអី ចេះនិយាយតែពីរឿងសាមគ្គីគ្នា កុំបែកបាក់ កុំឈ្លោះគ្នា ដូចយើងអប់រំកូនចឹង។

ដានី : អត់ឥឡូវ?

ប៉ែម : ទេ! អត់ទេ។

ដានី : ឥឡូវអ៊ំពូកែនិយាយ កាលនឹងអត់សូវទាន់ពូកែនិយាយដូចឥឡូវ?

ប៉ែម : នៅទេ ប៉ុននិយាយទៅគេចេះតែស្តាប់បាន យើងចាស់ គេក្មេង។

ដានី : ប៉ុន្តែនៅកន្លែងណានៅអគ្គភាពនឹង?

ប៉ែម : នៅភ្នំវីរមាល។

ដានី : នៅលើភ្នំនឹងម៉ង?

ប៉ែម : នៅជើងភ្នំ។

ដានី : ប៉ុនអត់មាននៅក្នុងភូមិទេកាលនឹង?

ប៉ែម : អត់ទេ។

ដានី : នារីច្រើនកាលនឹង?

ប៉ែម : នារីម្តងមាន៤០០នាក់ គ្រាន់អប់រំគេឲ្យល្អ កុំឲ្យគេរត់គេអី។ ហើយខាងយុវជនអប់រំយុវជន នារីអប់រំនារី។ ហើយមែន អត់មានអ្នកខូចអ្នកខិលទាក់ទងអត់រលីង។

ដានី : នារី៣០០-៤០០នាក់នឹង មកពីដូចថាយើងប្រមូលគាតមកពីភូមិតាមភូមិតាមស្រុក?

ប៉ែម : ទ័ពរ៉ៃទៅចូលភូមិចឹងទៅ ម៉ែឪគាត់នៅតាមភូមិនឹង គាត់ចេះប្រគល់កូននឹងឲ្យមកៗ ឃើញទ័ពយើងស្រឡាញ់ ឃើញកូនទុកដូចកូនគាត់ចឹង។ ចឹងគាត់មានកូនស្រីកូនប្រុសអីគាត់ចេះប្រគល់ឲ្យមកតាមនឹងមក យកមកឲ្យអ្នកក្រោយ។

ដានី : បាទ! មកឲ្យយើងអ្នកណែនាំ?

ថែម ៖ ចា៎!

ដានី ៖ ដូចជាអ៊ំខាងនារីទៅ ខាងបុរសទៅខាង?

ថែម ៖ ទៅខាងបុរសទៅ ។

ដានី ៖ ខាងបុរស ប៉ុន្តែកាលនឹងគ្រួសារអ៊ំគាត់អ្នកទទួលខាងបុរស?

ថែម ៖ ចា៎!

ដានី ៖ គាត់អប់រំចឹងដែរ?

ថែម ៖ អប់រំចឹងដែរ ដល់ពេល ។

ដានី ៖ អប់រំនឹងសរសេរ ដូចថាមុននឹងយើងនិយាយ យើងមានព្រៀងអ៊ីទុកថា យើងត្រូវនិយាយម៉េចជាមួយនារី បុរសអ៊ី មាននិយាយ ហើយក៏យើងចេះនឹកឃើញនិយាយខ្លួនឯង?

ថែម ៖ យើងមានធ្វើកម្មវិធីអីខ្លះ ខទី១ទី២អីខ្លះដែរ ប៉ុនមើលហើយក៏ចេះនិយាយបែកខ្លួនឯងធ្វើម៉េចឲ្យតែល្អ ។ ម្យ៉ាងកាលនោះយើងធ្វើបុណ្យស្តាប់លោក ស្តាប់អីលោកក៏ទេសថាឲ្យចេះសាមគ្គីគ្នា ។

ដានី ៖ កាលនឹងអ៊ំធ្លាប់ស្តាប់លោកទេសដែរ កាលពីជំនាន់ឆ្នាំ?

ថែម ៖ ចា៎! ខ្ញុំចូលចិត្តតាំងពីតូចមកទៅវត្តទៅអី ព្រោះយាយខ្ញុំនៅវត្ត ។

ដានី ៖ ចឹងប៉ុន្តែដល់ពេលសង្គ្រាមឆ្នាំ៦៨ ៦៩ ៧០ ៧១ ៧២ ហើយកាលនឹងអ៊ំនៅតែធ្លាប់បានស្តាប់លោកទេស ធ្លាប់បានទៅវត្ត ឬក៏ធ្លាប់បានធ្វើអីចឹងដែរ ហើយក៏អត់ទេ?

ថែម ៖ ធ្លាប់ ទៅវត្តជួប តា នៅ គាត់ធ្វើសង្ឃរាជ នៅវត្តត្រពាំងធំ គាត់ទទួលមួយស្រុកត្រាំកក់នឹង ។

ដានី ៖ តា នៅ យើង?

ថែម ៖ តា នៅ យើងចាស់ ។

ដានី ៖ ឥឡូវគាត់នៅស្រះឈូក?

ថែម ៖ នៅត្រង់ផ្សារចាស់នេះ ។

ដានី ៖ ផ្សារចាស់ កន្លែងណា កន្លែងអូរជីកនឹង?

ថែម ៖ កន្លែងអូរជីក ខាងជើងអូរជីក ។

ដានី ៖ ខ្ញុំធ្លាប់ទៅវត្តនឹងដែរតើ ។

ថែម ៖ វត្តត្រពាំងធំ?

ដានី ៖ បាទ! ទៅវត្តត្រពាំងធំ ។

ថែម :	គាត់ហ្នឹងធ្វើសង្គ្រាជ គាត់បួសរៀនបានជ្រៅជ្រះ ។

ដានី :	កាលពេលកាលជំនាន់នឹង គាត់ធ្វើទទួលគណៈស្រុកនៅត្រាកក់?

ថែម :	ចា៎! ខាងសង្ឃ ។

ដានី :	ខាងសង្ឃ?

ថែម :	ហ្នឹង! ហើយខ្ញុំ ។

ដានី :	ធ្លាប់ទៅវត្តគាត់ដែរ?

ថែម :	ចា៎!ខ្ញុំតែដូចថាទៅប្រជុំទៅធ្វើមេទិញ ប្រមូលប្រជាជនមកចឹង ខ្ញុំទៅអង្គុយជាមួយចាស់ៗម៉្លេះហើយគាត់ចូលចិត្តណាស់ គាត់សួរទាក់ទងចឹងទៅ ។

ដានី :	ចុះអ៊ំនៅកន្លែងនារីនឹងបានយូរទេ?

ថែម :	យូរដែរ ២ឆ្នាំ បានខ្ញុំចេញទៅធ្វើការតាម មើលពីឆ្នាំ៧២ ៧៣ ៧៤ខ្ញុំទៅអង្គរជ័យ ។ ទៅនៅអង្គរជ័យបាន២ឆ្នាំ បានខ្ញុំទៅកោះអណ្តែត ។

ដានី :	កាលនឹងឆ្នាំ៧៤ យ៉េងអត់ទាន់បែក មិនទាន់បាន?

ថែម :	នៅទេ! ហ្នឹងកំពុងតែវ៉ៃគ្នា ។

ដានី :	កំពុងតែវ៉ៃខាំងនៅភ្នំពេញនៅអី ជិតចូលភ្នំពេញ?

ថែម :	ជិតៗហើយជិតចូល ។

ដានី :	ប៉ុន្តែនៅខាងអង្គរជ័យអីយើងខាងខ្មែរក្រហមគេរំដោះបានហើយនោះ?

ថែម :	ចា៎!

ដានី :	គេរំដោះបានអស់ហើយ?

ថែម :	ចា៎!

ដានី :	ដល់ពេលចឹងអ៊ំក៏ផ្លាស់ចេញអង្គភាពនារីមកអង្គរជ័យវិញ?

ថែម :	ចា៎! ហ្នឹងហើយនារីៗ យើងរៀបចំឲ្យគេទៅទ័ព ធ្វើទាហានអស់ ។

ដានី :	នារីៗធ្វើទាហាន ទៅ?

ថែម :	ចា៎!

ដានី :	ចុះគ្រួសារអ៊ំគាត់មកអង្គរជ័យដែរ?

ថែម :	គាត់មកដែរ ។

ដានី :	មកទាំងពីរនាក់ អត់បែកគ្នា?

ថែម :	អត់ទេ ។

ដានី : ចុះដល់ពេលមកអន្លង់វែង មានជួបឧបសគ្គ មានពិបាកអីយ៉ាងម៉េចដែរ កាលនឹងមកនៅអន្លង់វែង?

ថែម : មកអន្លង់វែងមានលំបាក ហើយនឹងស្រួលនឹង បើយើងមានកម្លាំង ប្រជាជនគាំទ្រច្រើន ចឹងទៅម៉ាស្រួល ។ ប៉ុន្តែ ពេលដែលថាលំបាក ក៏ប្រជាជនគាត់ខ្វះខាត ហើយយើងដោះស្រាយឲ្យគាត់ធ្វើចំការ ធ្វើស្រែធ្វើដី ចេះតែឲ្យធ្វើហើយ អត់មានដី ប្រើដីគឺមីដូចយើងឥឡូវអីប្រើដីលេខ១-២ ដីកំប៉ុស ។ ធ្វើអូ! ខ្ញុំធ្វើបានថាស្រូវម៉ាហិចតា៣តោននោះ គឺ ៣តោនមែន ។

ដានី : បាន៣តោន មែន?

ថែម : ហ្នឹង ៣តោន ៤តោន អាដីលេខ១ ដីលេខ២ ។

ដានី : ដីលេខមួយដីអីគេ?

ថែម : ដីលាមកយើងនឹង ។

ដានី : ដីលេខ២?

ថែម : ដីលេខ២ យើងធ្វើពីកន្ទ្រនខែត្រ ពីដីដំបូក ពីអីនឹងយើងលាយគ្នាហើយកប់ទុក ។

ដានី : អានឹងគេហៅដីលេខ២?

ថែម : ចា៎! ដីលេខ១យកលាកមយើងសុទ្ធម៎ង ផ្ទះណាក៏បង្គន់ៗ អត់មានចោលអារត់អាវាយទេ ហើយដល់យើងដាក់ផែនការចឹង អំណោយផលដែលយើងធ្វើបាន ដាំដំណាំអី ។

ដានី : អ៊ំដូចថា ដូចជាមុននឹងយើងទៅនឹង ដូចអ៊ំទៅមកអន្លង់វែងនឹង អ៊ំមកខ្លួនឯង ឬក៏ តាម៉ុក គាត់អ្នករៀបចំចាត់ចែងឲ្យយើងមក?

ថែម : គាត់ឲ្យខ្ញុំទៅទទួលជួយមើលប្រជាជននៅស្រុកនឹង ។

ដានី : កាលនឹងយើងទៅក្រុមត្រៀមប៉ុន្មាននាក់ទៅ យើងទៅមើលប្រជាជននឹង?

ថែម : តែខ្ញុំទៅជួយរៀបចំអ្នកស្រុកនឹងម៎ង ។

ដានី : តែអ៊ំម្នាក់ទេ?

ថែម : ចា៎!

ដានី : ចុះអ៊ំប្រុស?

ថែម : តា គាត់ទៅដែរ ប៉ុនគាត់មិនសូវដើរ មិនសូវអីដូចខ្ញុំទេ?

ដានី : អត់មានពីណាផ្សេង ជួយអ៊ំជាជំនួយ?

ថែម : មានតាមឃុំតាមអី ។

ដានី : មានតាមឃុំតាមអី ជួយ?

ថែម ៈ ចាស៎!

ដានី ៈ ចុះអ៊ំដូចថារបៀបធ្វើស្រែ របៀបដាក់ជី របៀបអីនឹង អ៊ំជាអ្នកច្នៃប្រឌិតធ្វើខ្លួនឯង ឬក៏ខាងណាគេមកបង្រៀនរបៀបធ្វើកសិកម្ម ដូចថាជីលេខ១ ជីលេខ២ ជីកំប៉ុស អីយើងធ្វើដើម្បីដាក់ស្រែបានផលស្រូវច្រើន?

ថែម ៈ ធ្វើយើងមុនដំបូងសាកសួរប្រជាជន ដែលចេះបច្ចេកទេស ខាងដាំដុះ ខាងស្រែមកពីទន្លេ

ដានី ៈ មកពីទន្លេណា?

ថែម ៈ ពីក្រោម នៅពីកោះអណ្តែតពីអីគេអ្នកចំការ ចំការលើវ៉ាន់ៗ ដល់ចឹងយើងឲ្យគាត់ធ្វើប្រធានៗ

ដានី ៈ ឲ្យធ្វើប្រធាន?

ថែម ៈ ហ្នឹង គាត់នាំទៅកាប់ទន្រ្ទានខែត្រមានក្រុមគាត់ នាំយើងរៀបចំជាក្រុមៗ ។

ដានី ៈ (ភ្លៀងធ្លាក់ខ្លាំង)ចុះអ៊ំមិញមកកន្លែងកោះអណ្តែត ដែលយើងចាប់ធ្វើស្រូវធ្វើស្រែ កាលនឹងអ៊ំមានប្រសាសន៍ថា បាន៣តោនក្នុងមួយហិចតា ចឹងស្រូវល្អយើងធ្វើបាន៣តោន?

ថែម ៈ ហ្នឹងក្នុងស្រុកអង្គរជ័យ កែប្រែបានមែន ព្រោះអីយើងដាក់ជីច្រើនណាស់ៗ

ដានី ៈ ដាក់ជីច្រើន?

ថែម ៈ ចាស៎! ដាក់ជីច្រើន ហើយភូមិណាក៏មានជង្រុកជីស្ពុក ៣-៤ គ្រាន់ជង្រុកអាជីលេខ១ លេខ២នឹងៗ ដាំដំណាំ ក៏បានច្រើន ដល់ឃើញខ្ញុំដឹកនាំបានរីកចំរើនចឹង ក៏ផ្លាស់ឲ្យមកនៅកោះអណ្តែតៗ

ដានី ៈ ចឹងកាលនឹងគេមានផែនការថា យើងធ្វើស្រែធ្វើម៉េចឲ្យបានទិន្នផលមួយហិចតាឲ្យបាន៣តោន មានផែនការនៅកាលជំនាន់មុន៧៥?

ថែម ៈ មានហើយៗ

ដានី ៈ មានហើយ?

ថែម ៈ ចាស៎! ៧៤ ៧៥មានហើយៗ

ដានី ៈ មានចេញពីខាងណាដែរ ផែនការមួយហិចតាឲ្យបាន៣តោន?

ថែម ៈ ចេញពី តា ប៉ុល ពតៗ

ដានី ៈ តា ប៉ុល ពត? ប៉ុន្តែរបៀបបច្ចេកទេសធ្វើស្រែ ហៅយធ្វើម៉េចឲ្យបានទិន្នផលច្រើននឹងយើងស្រេចលើបច្ចេកទេសរៀងៗខ្លួន ឬក៏មានគេបង្រៀនយើងថា ឲ្យយើងធ្វើរបៀបចេះៗ មានណែនាំអីពីលើមក?

ចែម ៖ ពីលើមកគ្រាន់ដាក់ផែនការឲ្យ ថាឥឡូវឆ្នាំនេះ ធ្វើម៉េចឲ្យបានដី ឲ្យយើងឆ្លើយ បានដីក្នុងស្រុកមួយប៉ុន្មានតោន ប៉ុន្មានរយតោន ហើយធ្វើស្រែនឹង គេមើលតាមដីដែលយើងធ្វើ ដីឲ្យដូចថាមានដីប៉ុន្មានរយហិចតា ហើយក្នុងមួយហិចតា ដាក់ដីប៉ុន្មានតោន ដីលេខ១-២ គិតតាមនឹង។ ហើយខ្ញុំៗធ្វើបាន។

ដានី ៖ ធ្វើបាន?

ចែម ៖ ចាំ!

ដានី ៖ ដល់ពេលផលស្រូវដែលយើងបាន យើងយកសម្រាប់ផ្គត់ផ្គង់អីខ្លះទៅ?

ចែម ៖ ជួយទៅកងទ័ព ដឹកទៅកងទ័ពនៅកំពង់សោម ហើយប្រជាជនជម្លៀសចេញដល់៧៥ យើងរំដោះ។ ចឹងដល់ខ្ញុំក៏ផ្លាស់ទៀត។

ដានី ៖ ចឹងផលស្រូវនឹង យើងដឹកជួយកងទ័ពពេលប្រជាជនជម្លៀសមកឆ្នាំ៧៥មក យើងនៅជួយកងទ័ពទៀត ហើយអត់ទេ?

ចែម ៖ ជួយ ហើយកងទ័ពដល់ចប់សង្គ្រាមទៅ គាត់ធ្វើខ្លួនឯងផង ហើយគាត់ការពារ នឹងគាត់ដោះស្រាយតាមអង្គភាពរបស់គាត់បាន។

ដានី ៖ ដល់ពេលចឹង ស្រូវដែលយើងផលិតបាន យើងជួយទៅខាងណាវិញ បើកងទ័ពដោះស្រាយបាន?

ចែម ៖ ឲ្យតែប្រជាជនដែលជម្លៀសចេញពីក្រុង ពីខេត្តទូទាំងប្រទេស។

ដានី ៖ យើងអត់មានជួយទៅខាងតំបន់ ទៅខាងមជ្ឈិមអីទៀតទេ?

ចែម ៖ បើគាត់ត្រូវការយើងឲ្យដូចថា ឥឡូវក្នុងស្រុកមួយសុំស្រូវ១០០តោន យើងឲ្យ។

ដានី ៖ យើងឲ្យទៅ?

ចែម ៖ ចាំ!

ដានី ៖ ចឹងកាលនឹងមានគេសុំប៉ុន្មានតោនដែរ មួយឆ្នាំៗ?

ចែម ៖ ខ្ញុំដឹងថា ស្រុករបស់ខ្ញុំនឹងចេញជួយកងទ័ព១០០តោនៗចឹង ខ្ញុំដឹកចេញទៅអស់។

ដានី ៖ តែអឹអត់បាននាំដឹកស្រូវនឹងផ្ទាល់ទៅ?

ចែម ៖ អត់ទេ អង្គភាពគេមកដឹកយកទៅ ចឹងយើងចែក។

ដានី ៖ ចឹងអឹដល់ពេលស្រូវសល់ យើងបែងចែកដូចថាទុកឲ្យប្រជាជននឹងហូបចុកអីយ៉ាងម៉េច អឹមានរៀបចំថាប្រជាជនហូបចុកប៉ុន្មាន ក្នុងម្នាក់ប៉ុន្មានអី អឹមានបែងចែក?

ចែម ៖ បែងចែក ក្នុងមួយម្នាក់វា១៥ថាំងចឹង ក្នុង១៥ថាំង ហើយផ្ទះនឹងមានប៉ុន្មាននាក់ យើងគិតតាមនឹង។ ដល់ក្រោយមកបានគេប្រមូលដាក់ជង្រុកតែមួយ។

ដានី ៖ ដាក់ជង្រុកតែមួយ?

ថែម ៖ ចាំ! ដូចថាគេធ្វើជង្រុកប៉ុនៗនឹង ។

ដានី ៖ កាលនឹងយើងបែងចែកចឹង យើងគិតថា ទុកឲ្យប្រជាជនគាត់ហូបក្នុងមួយថ្ងៃហូបប៉ុន្មានពេលដែរ?

ថែម ៖ គាត់ហូប៣ពេលស្រេចគាត់ ដូចយើងធម្មតារាល់ថ្ងៃ ។ ហើយយើងធ្វើការ ដូចខ្ញុំអីធ្វើការខ្ញុំអត់រើសអើងការងារពលកម្ម ខ្ញុំធ្វើស្រូវហូបតើ ។ ខ្ញុំមានជង្រុកស្រូវរបស់ខ្ញុំ ។

ដានី ៖ កាលនឹងអ៊ំនៅអន្លង់វែង?

ថែម ៖ ចាំ! នៅអន្លង់វែង ។

ដានី ៖ កាលនៅអន្លង់វែង ដូចថាប្រជាជនដូចថា យើងដាក់ផែនការឲ្យគាត់ធ្វើការចាប់ពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន ពីសម្រាកប៉ុន្មានម៉ោង ហើយម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន ហើយគាត់ធ្វើការ ក្រៅពីការធ្វើស្រែធ្វើចំការ គាត់ធ្វើការងារអីទៀត?

ថែម ៖ ដាក់ ព្រោះអីផែនការ គេកំណត់ថាក្នុងមួយថ្ងៃធ្វើពីម៉ោង៧ចុះ ដល់ម៉ោង១១ឡើង ខ្ញុំដាក់ផែនការធ្វើតាមផ្ទះនឹង ពីម៉ោង១២ទៅម៉ោង១ ២ម៉ោង ។

ដានី ៖ ធ្វើអីគេអានឹង?

ថែម ៖ ដាំអីដាំទៅជុំវិញផ្ទះកុំឲ្យទំនេរសម្រាប់កូន សម្រាប់ខ្លួនយើងហូប ។ ខ្ញុំទម្លាប់ខ្លួនឯងក៏ធ្វើមិនឈប់ ក៏ត្រូវការក្នុងមួយថ្ងៃដាំដំឡូង បើថាកូន៥នាក់ ធ្វើម៉េចក្នុង២ម៉ោងនេះដាំឲ្យបាន៥គុម្ព ព្រោះហូបទៅវិញម្នាក់មួយគុម្ព ហូបអត់អស់ទេ ។ ចឹងកន្លែងដែលខ្ញុំនៅអត់មានទៅដាច់បាយស្លាប់ដូចគេទេ ។

ដានី ៖ ដាក់ផែនការចឹង ដល់ពេលផុតពីម៉ោងផ្ទះចឹង ដល់ម៉ោងប៉ុន្មានយើងចាប់ផ្ដើមចុះទៅធ្វើស្រែ?

ថែម ៖ ម៉ោង២ៗ ដល់ម៉ោង៥ ។

ដានី ៖ ម៉ោង២ ដល់ម៉ោង៥?

ថែម ៖ ចាំ!

ដានី ៖ ដល់ពេលចប់មកវិញ?

ថែម ៖ ចប់មកវិញ មកផ្ទះរៀងខ្លួន កូនចៅអីដាំបាយដាំទឹកអីហូបធម្មតាចឹងទៅ ។ ហើយដល់ពេលរៀបចំសហករណ៍មួយឆ្នាំ ទៅស្រុកព្រះនេត្រព្រះក៏គេបំផុសធ្វើចឹង ។ កាលមុនគេនៅមុនខ្ញុំគេអត់ធ្វើចឹងទេ ។

ដានី ៖ ចុះអ៊ំកាលនៅទៅដល់អន្លង់វែងកាលនឹងយើងហូបតាមផ្ទះ ឬក៏ហូបតាមសហករណ៍?

បែម : ហូបតាមផ្ទះម៎ង់ ។

ដានី : នៅអន្គរជ័យយើងហូបតាមផ្ទះនៅឡើយ?

បែម : ចា៎!

ដានី : កាលនឹងប្រជាជនគាត់ធ្វើតែស្រែទេ អត់មានធ្វើអីផ្សេងទៀតទេ?

បែម : គាត់ធ្វើតែស្រែ ហើយចំការបែកគ្នា កម្លាំងម៉ាផ្នែកគាត់ចាស់ៗហើយ ឲ្យគាត់ដាំដំណាំខ្លះ វេញខ្សែពួរខ្លះអីទៅតាមការងារ ។

ដានី : អ៊ំចេះ តាមរដ្ឋបាលក្នុងស្រុក ខ្ញុំអត់ដឹងថាកាលពីជំនាន់អ៊ំគ្រប់គ្រងនឹងវាយ៉ាងម៉េចទេ ប៉ុន្តែដូចថាក្នុងឥឡូវនឹងក្នុងស្រុកមួយ វាប្រជាជនដូចថារដ្ឋបាលស្រុក វាមានផ្នែកខាងកសិកម្ម ផ្នែកខាងសុខាភិបាល ផ្នែកខាងសន្តិសុខ ផ្នែកខាងអី កាលនឹងកាលជំនាន់អ៊ំគ្រប់គ្រងវាមានចឹងដែរអត់ទេ?

បែម : វាមាន ។

ដានី : មានចឹងដែរ មានប៉ុន្មានផ្នែក កាលនឹងក្នុងស្រុក?

បែម : មានគ្រប់ផ្នែកទាំងអស់ ប៉ុន្តខ្ញុំតែនៅជាមួយប្រជាជនតែខាងសេដ្ឋកិច្ចរហូត ។

ដានី : ខាងសេដ្ឋកិច្ចទេ?

បែម : ដាំដុះចិញ្ចឹមៗនឹងហូរហែល មានពិសោធន៍ក្នុងការដោះស្រាយប្រជាជននឹង ខ្ញុំដើររកពូជតាំងពីគៀនស្វាយ តាំងពីអី ខ្ញុំទៅនៅព្រះនេត្រព្រះនឹង ខ្ញុំដើររកពូជពីតាកែវមកគ្រប់ស្រុក ដឹកឡានយកទៅចែកឲ្យប្រជាជនធ្វើ ។ រហូតដល់ ខ្ញុំអត់អួតទេ ខ្ញុំនិយាយជាក់ស្តែង រហូតដល់ប្រជាជនស្រែកថា អូ! ប៉ុននេះហើយ មានពន្លឺបដិវត្តហើយ ។ ហើយគេមុនៗនឹង ចឹងបានខ្ញុំទៅនៅក្រោយគេជាប់អាគេធ្វើមុនវាអត់ល្អ ។

ដានី : ចុះអ៊ំខ្ញុំបន្តពីមុនតិច ពីចប់អន្គរជ័យមកៗកោះអណ្តែត អ៊ំមកឆ្នាំណា?

បែម : ខ្ញុំមកឆ្នាំ៧៦ ។

ដានី : ៧៦?

បែម : ចា៎!

ដានី : ចុះកាលនឹងម៉េចបានគេ ដូចថាខាងលើគេចាត់ឲ្យអ៊ំ ឲ្យមកពីអន្គរជ័យមកកោះអណ្តែតវិញ?

បែម : ខ្ញុំធ្វើអីក៏សម្រេចតាមផែនការ ។

ដានី : អូ! ធ្វើបានសម្រេច?

បែម : នឹង ។

ដានី ៖ ចឹងពីណាគេអ្នកចាត់អ៊ីឲ្យមកពីអន្លុងវែងមក?

វែម ៖ តា ម៉ុក តា ប៉ុល ពត ។

ដានី ៖ តា ម៉ុក ហើយ តា ប៉ុល ពត?

វែម ៖ ចាំ!

ដានី ៖ ហើយកាលនឹងនៅកោះអណ្តែតយ៉ាងម៉េច បានគេចាត់អ៊ីឲ្យមកកោះអណ្តែតវិញ ហើយអ្នកគ្រប់គ្រងកោះអណ្តែតពីមុនយ៉ាងម៉េច បានគេដក?

វែម ៖ អ្នកគ្រប់គ្រងខាងកោះអណ្តែតនឹងវាទំនាស់គ្នាផង ហើយធ្វើការងាររអត់ឯកភាពគ្នា ។ ដល់ខ្ញុំទៅនៅទៅ ដកប្រធាននឹងទៅគិរីវង់ ។

ដានី ៖ ចឹងកាលនៅកោះអណ្តែតពីណាគេ?

វែម ៖ សៀង ។

ដានី ៖ ឈ្មោះ សៀង?

វែម ៖ ចាំ!

ដានី ៖ ឈ្មោះ សៀង គាត់ដកទៅគិរីវង់?

វែម ៖ ចាំ!ហើយដល់ខ្ញុំនៅនឹង ៣នាក់ គាមួយធ្វើសមាជិក ហើយអនុខ្ញុំនឹងមានប្អូនថ្លៃ តា ម៉ុក

ដានី ៖ ពីណាគេ?

វែម ៖ តា សាន ប្អូនថ្លៃ តា ម៉ុក ។

ដានី ៖ ចឹងកាលអ៊ីទៅកោះអណ្តែតមានអ៊ី មាន តា សាន មាន?

វែម ៖ មាន តា ចាន់ៗគាត់ចាស់ហើយ ។

ដានី ៖ ឥឡូវគាត់នៅ?

វែម ៖ ស្លាប់បាត់យូរហើយ ។

ដានី ៖ តា សាន ប្អូនថ្លៃ តា ម៉ុក?

វែម ៖ ដឹងស្លាប់ហើយនៅៗសំឡូតនោះឥឡូវ ។

ដានី ៖ អូ! គាត់នៅសំឡូត?

វែម ៖ ចាំ! កាលនេះគាត់មកលេងម្តង ។

ដានី ៖ គាត់ឈ្មោះ តា សាន?

វែម ៖ ចាំ!

ដានី ៖ ប្រពន្ធគាត់ឈ្មោះអី?

វែម ៖ ឈ្មោះ គឿន ។

ដានី ៖ គឿន នឹងប្អូន តា ម៉ុក បង្កើត?

ថែម ៖ ប្អូន តា ម៉ុក បង្កើត ។

ដានី ៖ ចឹងកាលនឹងប្តីអ៊ំទៅនៅជាមួយ ក្រុមគ្រួសារទៅនៅកោះអណ្តែតទាំងអស់គ្នា?

ថែម ៖ ហ្នឹងគាត់អត់ទៅទេ គាត់នៅអន្លង់វែង ។ ដល់ខ្ញុំតាគាត់ឲ្យមកនៅកោះអណ្តែតបានមួយឆ្នាំ គាត់ឲ្យមករៀបចំនៅក្រុង ខេត្តតាកែវ នៅនឹងក្រុងម៉ង់ ។

ដានី ៖ ពីណាគេ ហ្នឹងប្តីអ៊ំ?

ថែម ៖ ទាំងអស់គ្នា តាខ្ញុំនៅអន្លង់វែងនៅឡើយ មានផ្ទះនៅ ។

ដានី ៖ នៅអន្លង់វែង គាត់គ្រប់គ្រងជំនួសអ៊ំ ហើយអត់ទេ?

ថែម ៖ ហ៎ង គាត់ធ្វើការតិចតួច ។

ដានី ៖ គាត់ធ្វើការតិចតួច?

ថែម ៖ ចា៎!

ដានី ៖ ចឹងអ្នកដែលគេគ្រប់គ្រងនៅកោះអណ្តែតពីមុនអ៊ំនឹង គាត់ផ្លាស់ទៅខាងគីរីវង់វិញ?

ថែម ៖ ចា៎!

ដានី ៖ កាលនឹងគេផ្លាស់ទៅទាំងអស់ហើយក៏យ៉ាងម៉េចទៅគីរីវង់?

ថែម ៖ ផ្លាស់តែគាត់នឹងមួយ តែខ្ញុំទៅនៅនឹងបានមួយឆ្នាំ ។

ដានី ៖ គាត់ឈ្មោះ តា សៀង?

ថែម ៖ ចា៎! តា សៀង ឮថាស្លាប់យូរហើយ ។

ដានី ៖ តា សៀង គាត់ទៅនៅគីរីវង់ ទៅនៅជាមួយពីណា?

ថែម ៖ ទៅនៅជាមួយពីណាខ្លះទេ ខ្ញុំភ្លេចហើយ យូរហើយ ផ្លាស់ទៅកាលនឹង ។

ដានី ៖ គាត់ទៅជាអ្នកធ្វើជាប្រធាន ឬក៏ធ្វើជា?

ថែម ៖ គាត់នៅធ្វើប្រធាននឹងដែរ ប៉ុនផ្លាស់កន្លែង ។ ដល់ខ្ញុំចូលទៅនៅស្រុកកោះអណ្តែតនឹង រៀបចំបាយរួមហើយ ។

ដានី ៖ គេរៀបចំបាយរួម?

ថែម ៖ ចា៎!

ដានី ៖ ដល់ពេលគេរៀបចំបាយរួមហើយយ៉ាងម៉េចទៅអ៊ំ គេរៀបចំគោលការណ៍ ការងារអី យ៉ាងម៉េច?

ថែម : គោលការណ៍យើងរៀបចំ ទី១ធ្វើចន្ក្រានបាយ ធ្វើជង្រុកស្រូវធំៗ ប៉ុន្តែខ្ញុំនៅនឹងដូចអត់ពិបាកអីដែរ ព្រោះបែកការងារគ្នាដាច់ ខ្ញុំនៅខាងក្រោយ ខ្ញុំគិតតែដឹកនាំប្រជាជនធ្វើស្រែវស្សាទៅ ហើយពូសាន អនុខ្ញុំ នៅខាងជាប់ខាងយួន ស្រុកបឹង ។

ដានី : គាត់ធ្វើអី?

ថែម : គាត់គិតតែធ្វើស្រែប្រាំង ។

ដានី : គិតតែធ្វើស្រែប្រាំង?

ថែម : ហ្នឹងដល់បែកការងារគ្នាដាច់ចឹង ដូចអត់មានទំនាស់អី បានមួយអាទិត្យឡើងមកជួបគ្នាម្តងៗ ។

ដានី : កាលនឹងយើងធ្វើការចឹង មានការណែនាំអីពី តា ពីអីដូចថាយើងត្រូវរៀបចំការងារអី?

ថែម : មានដែរ គាត់ហៅមកជួបអីទៅ ។

ដានី : កាលនឹងយើងបានធ្វើស្រែ យើងបានដូចថាបានផលច្រើនហួសពីការហូបចុកនឹង យើងត្រូវផ្គត់ផ្គង់ទៅខាងណាវិញទៅ?

ថែម : ហ្នឹងទៅជួយទ័ពដែរ ។

ដានី : ទៅជួយទ័ពវិញដែរ?

ថែម : ចាំ! ព្រោះទ័ពទើបនឹងឈប់សង្គ្រាមចឹង ធ្វើអត់ទាន់បានហូប ហើយនឹងប្រជាជនដែលជម្លៀសទៅពីភ្នំពេញច្រើនចឹង បែកគ្នាដាក់តាមស្រុកវិញ ។ មានការលំបាក ប៉ុន្តែស្រួលម្យ៉ាងត្រង់ថា កម្លាំងយើងរៀបចំត្រូវគេអត់ទំនាស់ជាមួយយើង ។

ដានី : គេអត់ទំនាស់?

ថែម : អត់ ។

ដានី : បើយើងចេះរៀបចំ?

ថែម : ចាំ!

ដានី : បើរៀបចអត់ត្រូវទំនាស់?

ថែម : អត់ត្រូវទំនាស់ហើយ ចេះតែថាប្រឆាំង ថាក្បត់ថាអី ប៉ុន្តែខ្ញុំអត់ទេ ប្រជាជនចូលចិត្តម៉ង ព្រោះខ្ញុំធ្វើ ដូចខ្ញុំនិយាយមិញចឹង ម៉ោងណាក៏ធ្វើដែរ អាកំណត់ម៉ោងដែលធ្វើឯកជននឹងទៅនៅកន្លែងណាក៏ខ្ញុំឲ្យធ្វើចឹង ។

ដានី : គេហៅម៉ោងអី ម៉ោងយើងធ្វើក្រៅ?

ថែម : ម៉ោងក្រៅនឹង ម៉ោងធ្វើឯកជន ។

ដានី : ម៉ោងធ្វើឯកជន?

ថែម :	ហ្នឹង ។

ដានី :	អានឹងអ៊ំអ្នកបង្កើតខ្លួនឯង ឬក៏ខាងតាៗ គាត់ប្រាប់ឲ្យធ្វើចឹង?

ថែម :	បង្កើតខ្លួនឯង កុំឲ្យប្រជាជនខ្វះហូប ។

ដានី :	យើងធ្វើចឹងដើម្បីជំនួយ?

ថែម :	ជំនួយអារួម ហូបមិនគ្រប់គាត់មានរបស់គាត់នៅផ្ទះ ។

ដានី :	អាយើងដូចថាម៉ោងឯកជន យើងដាំនៅផ្ទះ យើងសម្រាប់ហូបក្នុងគ្រួសារយើង ឬក៏យើងយកអានឹងទៅដាក់ក្នុងរួមដើម្បីដាក់ហូបភ្លាមៗ?

ថែម :	អត់ទេ ផ្ទះណាដាំបានប៉ុន្មានហូបប៉ុននឹង ហើយយើងដែលរកបានពីក្រៅ ឬក៏ពូជធារអីចែកមកឲ្យគាត់ថែមទៀត ។ តែចឹងកូនចៅគាត់អាបងគេទៅក៏ចេះធ្វើចេះចំអិន ។ ខ្ញុំថាស្រួលម៉ង់ប្រជាជនមិនបាច់ដោះស្រាយទេ ។ ហើយដំឡូងជ្វា ដំឡូងមីខែណាក៏មានដែរ ។

ដានី :	ចុះអ៊ំនៅកោះអណ្តែតនឹងនៅបានរយៈពេលប៉ុន្មានទៅ?

ថែម :	ខ្ញុំនៅបានមួយឆ្នាំ គ្រាន់តែប្រួតហើយ ខ្ញុំតាហៅមកតាកែវ ។

ដានី :	មកតាកែវវិញ?

ថែម :	មកនៅតាកែវបានមិនដល់កន្លះឆ្នាំផង គាត់ឲ្យមកស្រុកព្រះនេត្រព្រះ ។

ដានី :	ចុះអ៊ំនៅតាកែវ អ៊ំនៅកន្លែងណាទៅ?

ថែម :	ខ្ញុំនៅត្រង់ខាងត្បូងរោងតម្បាញគេ ។

ដានី :	ពីព្រោះផ្ទះ តា ម៉ុក គាត់នៅក្នុងបឹង(ភ្លៀងខ្លាំងណាស់)?

ថែម :	ចា៎!

ដានី :	ហើយ?

ថែម :	ខ្ញុំនៅអាផ្លូវមកពីអង្គតាសោមមក ចូលដង្កោលខ្ញុំនៅនឹង នៅផ្ទះចិន ។

ដានី :	ប៉ុន្តែកាលនៅតាកែវនឹង អ៊ំនៅក្នុងកន្លែងតំបន់ ឬក៏នៅកន្លែងអីគេ?

ថែម :	ខ្ញុំនៅស្រុកដែរ ខាងស្រុកគេមកទាក់ទង ហៅទៅប្រជុំអីចឹង ទល់ខ្ញុំចេញ ។

ដានី :	កាលនឹងនៅស្រុកអីគេ ពេលអ៊ំផ្លាស់មកតាកែវនេះ?

ថែម :	នៅស្រុកកោះអណ្តែត នៅក្នុងស្រុកកោះអណ្តែត ។

ដានី :	ចឹងមកតាកែវនឹង មកពីស្រុកកោះអណ្តែត ប៉ុន្តែចេញពីសាលាស្រុកមក?

ថែម :	ចា៎!

ដានី :	ចឹងអ៊ំ កាលនឹងអ៊ំមកតាកែវនឹង ប៉ុន្តែអ៊ំនៅធ្វើការងារស្រុកកោះ អណ្តែតដដែល?

ថែម :	ចា៎! នៅអត់ទាន់ដាច់ ។

ដានី ៖ ប៉ុន្តែអានឹងអ៊ំមិនមែនមកតំបន់ណា?

ថែម ៖ អត់ទេ ។

ដានី ៖ កាលនឹងតំបន់ប៉ុន្មាន តំបន់១៣?

ថែម ៖ តំបន់១៣ ។

ដានី ៖ ប៉ុន្តែអ៊ំមិនមែនមកធ្វើការងារតំបន់១៣ទេ?

ថែម ៖ អត់ទេ ខ្ញុំធ្វើជំនួសប្រធានខ្ញុំនឹង គ្រាន់ចូលសមាជិកទេណា ។

ដានី ៖ សមាជិកតំបន់?

ថែម ៖ ចា៎!

ដានី ៖ កាលនឹងប្រធានតំបន់ពីណាគេ?

ថែម ៖ គាត់ស្លាប់បាត់ហើយ ឈ្មោះ សោមៗ ។

ដានី ៖ ឈ្មោះសោម?

ថែម ៖ ចា៎! គាត់ដែលនៅព្រៃវែងនោះ គាត់ទៅធ្វើការនឹងដូចថាចំណោះវិជ្ជាគាត់ខ្ពង់ខ្ពស់ដែរ ។

ដានី ៖ ចុះអនុគាត់ពីណា?

ថែម ៖ អនុគាត់ តា មុត នឹង ។

ដានី ៖ តា មុត គាត់ធ្វើនៅកំពង់សោម ផង ធ្វើនៅតាកែវផង?

ថែម ៖ តាកែវ គាត់ដាច់ពីការងារនៅខេត្តតាកែវនឹងទៅ ហើយប្រធានខ្ញុំ ពូសោម គាត់ឈឺទៅបានគេតំឡើងខ្ញុំប្រគល់ឲ្យខ្ញុំធ្វើ ។ ប៉ុនខ្ញុំធ្វើនឹងតិចដែរ មួយឆ្នាំអីនឹង តា គាត់ដកឲ្យមកនៅបាត់ដំបង ។

ដានី ៖ បានមកនៅព្រះនេត្រព្រះ?

ថែម ៖ ចា៎! នៅព្រះនេត្រព្រះ ។

ដានី ៖ កាលហ្នឹងនៅតាកែវមានប៉ុន្មានស្រុក?

ថែម ៖ មាន៥ស្រុក ស្រុកកោះអណ្តែត អឺ!១ស្រុកកោះអណ្តែត ២ស្រុកត្រាំកក់ ៣ស្រុកទ្រាំង ៤គីរីវង់ ៥អង្គរជ័យ ។

ដានី ៖ ................(ស្តាប់មិនបាន) ?

ថែម ៖ ទ្រាំងគេផ្សេង ។

ដានី ៖ ................(ស្តាប់មិនបាន) ?

ថែម ៖ កាលខ្ញុំមិនទាន់មកព្រះនេត្រព្រះនេះ តា នឹង គាត់ចងកខ្លួនឯងស្លាប់ទៅ ។

ដានី ៖ គាត់ឈ្មោះអី?

ប៉ែម ៖ តា គៀត ។

ដានី ៖ តា គៀត?

ប៉ែម ៖ ចា៎!

ដានី ៖ ……………..(ស្តាប់មិនបាន) ?

ប៉ែម ៖ មិនដឹងម៉េច គាត់មានកំហុស ទាក់ទងស្រីញីអីនឹងយ៉ាង បានគាត់ទៅចឹង ខ្ញុំទៅស្លាប់ ។

ដានី ៖ គៀត?

ប៉ែម ៖ អូ! តា គៀត១ តា វ៉ែន១ នេះចង់កខ្លួនឯង ។

ដានី ៖ …………(ស្តាប់មិនបាន) ?

ប៉ែម ៖ ស្រុកទ្រាំង អឹ! ខាងព្រៃសណ្តែក ។

ដានី ៖ ចុះខាងត្រាំកក់ពីណាគេដែរ?

ប៉ែម ៖ ត្រាំកក់ ក៏ស្លាប់បាត់ដែរ តា គៀវ ។

ដានី ៖ តាអីគេ?

ប៉ែម ៖ តា គៀវ ។

ដានី ៖ តា គៀវ?

ប៉ែម ៖ ចា៎!

ដានី ៖ ចុះគីរីវង់?

ប៉ែម ៖ គីរីវង់ មុនផ្លាស់មកកោះអណ្តែតមាន តា សៀង ហ្នឹង និងឈ្មោះ យាយ ប៉ែន ប៉ុន គាត់ស្លាប់បាត់ហើយ ។

ដានី ៖ ចុះតាទិត (ស្តាប់មិនបាន) ?

ប៉ែម ៖ តាទិត គាត់ទៅនៅតិចដែរ ដល់ហើយគាត់ផ្លាស់ទៅសំឡូតវិញ ។

ដានី ៖ ………(ស្តាប់មិនបាន) ?

ប៉ែម ៖ តិច ប៉ុនកាលនៅគីរីវង់គាត់មិនធ្វើប្រធានទេ ធ្វើអនុគេដែរ ប៉ុនដល់ក្រោយមកដឹងម៉េចទេ បានគាត់ផ្លាស់មកសំឡូតមក ។

ដានី ៖ មានកោះអណ្តែត មានគីរីវង់ អង្គរជ័យពីណាគេ?

ប៉ែម ៖ អង្គរជ័យប្អូនថ្លៃ តា ម៉ុក ដែរ ឈ្មោះ នត ប៉ុនគាត់ស្លាប់បាត់ហើយ ។

ដានី ៖ នត?

ប៉ែម ៖ ចា៎!

ដានី ៖ ចុះ តា សាន ប្អូនថ្លៃគាត់?

ថែម ៖ ហ្នឹង......(ស្តាប់មិនបាន) គាត់ទៅសំឡូតដែរ ។

ដានី ៖ គាត់ទៅនៅសំឡូតដែរ?

ថែម ៖ ចាំ!

ដានី ៖ គាត់មកជាមួយតា?

ថែម ៖ តាទិត ។

ដានី ៖ ចឹងអ៊ំនៅតាកែវ បានតែមួយរយៈទេ?

ថែម ៖ ហ្នឹងខ្ញុំនៅបានប៉ុន្មានខែ តិចដែរ ។

ដានី ៖ ចឹងអ៊ំផ្លាស់មកព្រះនេត្រព្រះឆ្នាំណា?

ថែម ៖ ចុងឆ្នាំ៧៨ហើយ ទៅដល់នេះខែ១២ ចូល៧៩ ធ្វើស្រែវស្សាស្រូវទុំ រត់ឡើងភ្នំទៅ ។ ចឹងខ្ញុំបានមកទទួលស្រុកនឹងលំបាកមហាលំបាកហើយ ។

ដានី ៖ ................(ស្តាប់មិនបាន) ?

ថែម ៖ អូ! ក្តួយហើយ ក្រែងលខ្ញុំនិយាយថាខ្ញុំកុហក ខ្ញុំអត់កុហកទេ ខ្ញុំមកប្រជាជនវេទនាមហាវេទនា ។ ហើយឈឺគ្រប់ផ្ទះ ដូចខ្ញុំធ្លាប់និយាយថា នឹងខ្ញុំនិយាយប្រាប់ជាមួយលោកខេមរ៉ា ថាបញ្ជីចាស់គេប្រគល់ឲ្យខ្ញុំវាម៉ាសែន ដល់ខ្ញុំធ្វើថ្មី អស់ម៉ាម៉ឺនហើយ នៅដល់៩ម៉ឺនទេ ។

ដានី ៖ បញ្ជីប្រជាជន?

ថែម ៖ បញ្ជីប្រជាជន ព្រោះអីទូទាំងប្រទេសគេម្ជៀសទៅនៅស្រុកនឹងទាំងអស់ ។

ដានី ៖ ចឹង?

ថែម ៖ ហ្នឹង! ព្រោះដីវាធំ ហើយប្រជាជនវាតិច ប្រជាជនចាស់ ។ ប្រជាជនចាស់តែ១ម៉ឺនតើឃើញទេ ផ្ទះមានតែ កំពោរ ភ្នំលៀប ហើយព្រះនេត្រព្រះនឹង ទានកាំ រហាលទឹកជោរ តែប៉ុននឹងទេ ៥ឃុំដែរ ។

ដានី ៖ ចឹង៥ឃុំ មាន ព្រះនេត្រព្រះ កំពោរ ទានកាំ...?

ថែម ៖ ប៉ុន្តែប្រជាជនគាត់រស់នៅស្រុកកំណើតនឹងវាតិច ។

ដានី ៖ មានព្រះនេត្រព្រះ មានកំពោរ មានទានកាំ?

ថែម ៖ អត់ទេ ព្រះនេត្រព្រះ១ រហាល ទានកាំ និងភ្នំលៀប ទឹកជោរ ។

ដានី ៖ មានតែ៥ឃុំ?

ថែម ៖ ៥យ អូ!មួយទៀត ឃុំប្រាសាទ ។

ដានី ៖ មានឃុំប្រាសាទមួយទៀត?

ថែម :	ចាំ! ឃុំប្រាសាទ ។

ដានី :	៦ចឹង អុំ?

ថែម :	ចាំ! មាន៦ឃុំនឹង ។

ដានី :	ចុះអុំ និយាយកាលនុង អុំទៅគ្រប់គ្រង់មានតែម្នាក់ឯងទេ អត់មានអនុ អត់មានសមាជិកអីទេ?

ថែម :	តា គាត់ឲ្យទៅ២រទេះភ្លើង ។

ដានី :	ឲ្យមនុស្ស២រទេះភ្លើងមកគ្រប់គ្រង?

ថែម :	ចាំ! ទៅជាមួយខ្ញុំ ព្រោះអីកាលពេលដែលទៅនឹង គាត់សួរអ្នកដឹកនាំខេត្តតាកែវទាំងអស់ គេអត់ព្រមមក ព្រោះឃើញការលំបាកខ្លាំងពេក អ្នកនៅនឹងធ្វើបាបប្រជាជន ហើយវាស្អុកស្អាញ ស្រូវពិតមែនតែពីមុនល្បីថាបាត់ដំបងនឹងមិនដែលអត់ទេ នាំចេញលក់ដូរអីមន្តលបូរីអីនឹង ។ ដល់យើងសម័យដែលដឹកនាំ ដែលចប់សង្គ្រាម៧៥ ៧៦នឹង វាអត់មហាអត់ ព្រោះជម្លៀសប្រជាជនទៅនៅជាន់កលើគ្នា ផ្ទះប៉ុននេះមាន៥-៦គ្រួ(សារ) ។

ដានី :	កាលនឹង តា ម៉ុក គាត់ឲ្យទៅនឹង ឲ្យអុំទៅនឹង ពីណាគេជំនួយការផ្សារជាអនុ ជាសមាជិក?

ថែម :	ខ្ញុំទៅដល់នៅស្រុកគេនឹង អ្នកចាស់នឹងនៅ២ ។

ដានី :	ពីណាគេ?

ថែម :	ឈ្មោះ អាត មួយ គាត់ស្លាប់ហើយ ។

ដានី :	ឈ្មោះ អាត?

ថែម :	ចាំ! ហើយមួយឈ្មោះ ខូ រាល់ថ្ងៃនៅព្រំប្រទល់ថៃនោះ ។

ដានី :	ព្រំប្រទល់នៅណាទៅ ខ នឹង?

ថែម :	នៅអី ខ្ញុំមិនស្គាល់ផង ប៉ុនគេឲ្យលេខទូរស័ព្ទជួបគ្នាម្តងដែរ ។

ដានី :	គាត់នៅណាភូមិអី?

ថែម :	នៅជាប់ថៃ នៅខាងស្អីទៅហួសម៉ាឡៃទៀត ។

ដានី :	ខាងសាស្ត្រា?

ថែម :	ចាំ! ទៅ ។

ដានី :	សំពៅលូន?

ថែម :	ហ្នឹងហើយ ទៅនឹង ឃើញគេមក ។

ដានី :	ប្រពន្ធគាត់ឈ្មោះអី?

ប៉ែម ៖ ប្រពន្ធគាត់ប្រពន្ធមុនស្លាប់ហើយ នៅប្រពន្ធក្រោយ ។

ដានី ៖ ប្រពន្ធក្រោយគាត់ឈ្មោះអី?

ប៉ែម ៖ អត់ស្គាល់គាត់ ប្រពន្ធមុននោះនៅស្រុកក្រឡាញ់ រត់ជាមួយគ្នា ។

ដានី ៖ ឈ្មោះ ខ គាត់នៅសាស្ត្រចឹង?

ប៉ែម ៖ មិនទេ មិនសាស្ត្រាទេ ។

ដានី ៖ គាត់នៅសំពៅលូន?

ប៉ែម ៖ ពិបាកប្រាប់ ។

ដានី ៖ ខ្ញុំស្គាល់ច្រើនដែរតើ ម៉ាចំនៀរខាងនឹង ។

ប៉ែម ៖ ចឹង! អូ!គាត់ចាស់ដែរហើយ ឈ្មោះ តា ខៗ ភ្នំលៀបស្រុកព្រះនេត្រព្រះ គេស្គាល់ ។

ដានី ៖ នៅម៉ាដួរខាងសំពៅលូនចឹង?

ប៉ែម ៖ ខ្ញុំមិនសូវបានដើរ មិនសូវស្គាល់ ។

ដានី ៖ ចឹងកាលអ៊ំទៅនឹង មានអ្នកគេចាស់គេជួយការងារអីអីដែរ?

ប៉ែម ៖ ជួយបាន២-៣ខែដែរ ហើយអ្នកប្រធានគេនឹង ខ្ញុំទៅខ្ញុំធ្វើល្អ ទៅទំនាក់ទំនងជាមួយគាត់ៗប្រគល់បញ្ជី ប្រគល់អីឲ្យប្រជុំជាមួយគ្នាបានម្តង ។ ដល់ហើយក៏បាត់គាត់ទៅ ។

ដានី ៖ បាត់ពីណាគេ?

ប៉ែម ៖ បាត់ប្រធានស្រុកនឹងឈ្មោះ មោង ។

ដានី ៖ មោង បាត់ទៅ?

ប៉ែម ៖ បាត់ទៅ ។

ដានី ៖ ហើយចុះ អាត?

ប៉ែម ៖ អាត នឹងនៅ ទាល់ធ្វើការជាមួយគ្នាបានមួយឆ្នាំ បានបាត់ពួអាតនឹងទៀតទៅ យកពីបូព៌ាយកទៅដាក់ធ្វើអនុ ។

ដានី ៖ ពីណាគេ?

ប៉ែម ៖ ឈ្មោះ ខុន ប៉ុននឹងក៏ស្លាប់ដែរ ។

ដានី ៖ ចុះឈ្មោះ ឃ នឹង គាត់នៅធ្វើជាប្រធាន ហើយអនុ ហើយក៏សមាជិក?

ប៉ែម ៖ គាត់កាលខ្ញុំទៅនៅស្រុកនឹង គាត់ធ្វើសមាជិក ហើយកាលគេនៅមុនក៏ធ្វើសមាជិក ។

ដានី ៖ ចឹងគាត់ធ្វើសមាជិករហូតទៅ?

ប៉ែម ៖ ចា៎! ធ្វើសមាជិក គាត់ក្តាប់តែយុវជននៅខាងស្រែប្រាំង ។

ដានី :	ចុះ ខ នឹង គាត់រាប់អានជិតស្និត ជាមួយអីដែរ?

ថែម :	ចា៎! គាត់ទុកអូ! និយាយពីគ្រង់មហាគ្រង់ ហើយគ្រាន់សំបុត្រគេឲ្យចាប់២-៣ខ្ញុំលាក់ ។

ដានី :	ចាប់ពូ ខ នឹង?

ថែម :	ហ្នឹង ។

ដានី :	អូ! អីជួយគាត់ដែរ?

ថែម :	ចា៎! ខ្ញុំជួយគាត់ចឹងបានគាត់រស់រហូតទល់ឥឡូវ ។

ដានី :	ចឹងបើខ្ញុំទៅសួរគាត់អី គាត់ប្រាកដជានិយាយពីអឹ?

ថែម :	និយាយហើយហ្នឹង ខ្ញុំជួយគាត់ច្រើន ។

ដានី :	អឹមានលេខទូរស័ព្ទ គាត់ដែរ?

ថែម :	ខ្ញុំនោះ ទៅកន្លែងខ្ញុំធ្វើការនៅភ្នំលៀបនឹង ហើយពូនឹង ក្រុមប្រឹក្សាឃុំ គាត់មានលេខ ។

ដានី :	ក្រុមប្រឹក្សានៅភ្នំលៀប?

ថែម :	ចា៎! គាត់មានលេខទូរស័ព្ទ ហើយគេទៅជួបខ្ញុំនិយាយច្រើនដែរ ប៉ុនគាត់ចាស់ហើយ ឥឡូវ ។ មនុស្សល្អ ហើយខ្លាចស្លាប់ គ្រង់ ។

ដានី :	គ្រង់ចឹង អឹជួយគាត់ទៅ?

ថែម :	ជយគាត់លាក់ដូចថា គាត់នេះខសយុវជនធ្វើបាតុកម្ម ខ្ញុំយកសំបុត្រនឹងមកលាក់អត់ឲ្យ គាត់មើលទេ ហៅគាត់ណែនាំ ។ ដល់នេះ ខ្ញុំរំសាយយុវជនដែលគាត់ក្តាប់នឹង រំសាយឲ្យ ទៅរកស៊ីតាមផ្លូវមាត់ស៊ឹង មាត់អីរកត្រីរកអីធ្វើស្រែធ្វើចំការហូប ។

ដានី :	អឺខ្ញុំឆ្ងល់ចេះទៀត ខាងណាគេដែលគេមកចង់ចាប់គាត់នឹង?

ថែម :	ចាប់អ្នកណា?

ដានី :	ចាប់ ខ នឹង?

ថែម :	អូ! ខាងតាញឹមភូមិភាគ ។

ដានី :	ចឹងកាលអឹទៅ តាញឹម អីគាត់នៅទេ?

ថែម :	នៅទាំងអស់ តាញឹម កូនគាត់ឈ្មោះ ជៀល ។

ដានី :	ជៀល នឹង គាត់ធ្វើអីគេ?

ថែម :	ធ្វើខេត្តនៅស្វាយស៊ីសាផុន ។

ដានី :	តំបន់?

ថែម :	ហ្នឹង តំបន់ ។

ដានី :	ចឹងកាលអឹទៅនឹង ជៀលនឹងនៅគណៈតំបន់?

ថែម ៖ នៅគណៈតំបន់ ហើយអ្នកមុនបាត់ឈ្មោះអស់ ។

ដានី ៖ អ៊ំអត់ចាំទៅឈ្មោះ ហីស្ស?

ថែម ៖ ព្រឹឈ្មោះ ខ្ញុំទៅដល់ព្រឹឈ្មោះ ប៉ុនគេដកចេញហើយ ដែលធ្វើនៅត្រពាំងថ្ម តាវ៉ាល់ ។

ដានី ៖ អ៊ំចាំ តា វ៉ាល់ដែរ?

ថែម ៖ ខ្ញុំអត់បានឃើញទេ ប៉ុនគ្រាន់ទៅដឹងថា តា វ៉ាល់ៗ ដឹកនាំធ្វើទំនប់ ។

ដានី ៖ ទំនប់ត្រពាំងថ្មនឹង ពេល តា វ៉ាល់ ធ្វើបានធ្វើចប់សព្វគ្រប់?

ថែម ៖ ចប់ ។

ដានី ៖ ពេលអ៊ំទៅមានធ្វើតទៀតដែរ?

ថែម ៖ ខ្ញុំអត់ធ្វើ ព្រោះអីខ្ញុំនៅខាងព្រះនេត្រព្រះនឹង គ្រាន់ឲ្យកម្លាំងទៅធ្វើស្រែ ។

ដានី ៖ ទៅធ្វើស្រែនៅនឹង?

ថែម ៖ ហ្នឹងធ្វើស្រែប្រាំង ធ្វើអីនៅក្រោម ប៉ុន្តែទៅមើល ។

ដានី ៖ ទៅមើល?

ថែម ៖ ចា៎!

ដានី ៖ ប៉ុន្តែទំនប់នឹង អត់មានធ្វើតទៀតទេ?

ថែម ៖ អត់ គាត់ធ្វើ ។

ដានី ៖ ចប់?

ថែម ៖ ធ្វើចប់ ។ ខ្ញុំធ្វើប្រឡាយនៅខាងក្រោម ដែលចេញពីស៊ីងស្ពានស្រែងមក គេជីកប្រឡាយពីទំនប់ត្រពាំងថ្មមក ចូលទំនប់មួយទៀតគេហៅត្រពាំងទាប ។ ចេញពីនឹងមក ខ្ញុំជីកត្រង់ទ្វារទឹកគេមកកាត់មកខាងកើតភ្នំលៀបមក អាប្រឡាយធំ មាត់ធ៣០ ។ នៅរាល់ថ្ងៃនឹង ជិះឡានតាមផ្លូវនឹង ចាំគនមើល ។

ដានី ៖ គេហៅប្រឡាយអីគេនឹង?

ថែម ៖ គេយកឈ្មោះខ្ញុំប្រើម៉ង ។

ដានី ៖ គេហៅប្រឡាយ?

ថែម ៖ ប្រឡាយយាយ ថែមៗ ។

ដានី ៖ ចឹងនៅស្រុកនឹង បើសិនជាទៅសួរថាប្រឡាយមួយណាប្រឡាយយាយ ថែម គេស្គាល់ដែរ?

ថែម ៖ គេស្គាល់ ។ ប៉ុនក្រែងអ្នកអត់ដែលនៅស្រុកនឹង បើថានៅស្រុកនឹងទាំងក្មេងគេហៅប្រឡាយ ព្រោះខ្ញុំដឹកនាំធ្វើប្រឡាយនឹង អំណោយផលប្រជាជនបានច្រើនណាស់ ចាប់ពី

ទឹកពីស្ពានស្រែងដែលធ្លាប់ពេញមក វា ហើយនឹង ទន្លេសាប ដែលមកបាក់ព្រាមកស្ទឹង មង្គលបូរី វាធ្លាយមកខាងលិចឃុំប្រាសាទចេះ ឃុំព្រះនេត្រព្រះចេះ ម៉ាវាលនឹងរហូតសុទ្ធទឹក ។

ដានី : ចុះទៅតាមឃុំ គតពីអឹមានរៀបរាប់មិញ ឃុំប្រាសាទ ឃុំភ្នំលៀប ខានកាំអីនឹង ឃុំនឹង ដូចថាមនុស្សទាំងអស់ អឹអ្នកចាត់ចែងរៀបចំទៅតាមឃុំមួយៗ ឬក៏ តា គាត់អ្នករៀបចំឲ្យទៀត?

ថែម : ខ្ញុំអ្នករៀបចំ ប៉ុនគ្រាន់មកឲ្យខ្ញុំរើសខ្លួនឯង ។

ដានី : ឲ្យអឹមើលថាមនុស្សណាល្អ មនុស្សណាអីត្រឹមត្រូវឲ្យរៀបចំខ្លួនឯង?

ថែម : ចា៎! ឲ្យដើររើស ។

ដានី : ចុះនៅភ្នំលៀបពីណាគេ?

ថែម : ភ្នំលៀប នៅត្រពាំងធំនឹង គេទៅនោះវិញហើយ ។

ដានី : ទៅណា?

ថែម : ទៅស្រុកវិញ ។

ដានី : ទៅណាវិញ?

ថែម : ទៅស្រុកត្រាំកក់វិញ ។

ដានី : ទៅខាងត្រពាំងធំវិញ?

ថែម : ចា៎ៗ ។

ដានី : គាត់ឈ្មោះអីដែរ?

ថែម : ឈ្មោះ កាន់ ។

ដានី : កាន សព្វថ្ងៃគាត់នៅណាដែរ?

ថែម : គាត់នៅខាងត្រពាំងធំនឹង ដឹងនៅត្រង់ណាអីត្រង់ណា ។

ដានី : ប្រពន្ធគាត់ឈ្មោះអី?

ថែម : ប្រពន្ធគាត់ប្រពន្ធមុនឈ្មោះអី ក្រោយនេះ គាត់យកប្រពន្ធក្រោយមួយទៀត ។

ដានី : ប្រពន្ធក្រោយគាត់ឈ្មោះអី?

ថែម : អត់ដឹងគេ ។

ដានី : ខ្ញុំចង់សួរចេះ គ្រាន់ចង់ដឹងថា ឧបមាថាគាត់ដឹងពីអឹៗ ធ្វើម៉េចល្អសួរចឹងៗទៅ ថ្ងៃក្រោយយើងទៅសួរគាត់ បើសិនជាមានឱកាសអី ។

ថែម : នោះកូនគាត់ កូនប្រសារឈ្មោះ តា សុង ៗ នៅផ្សារ អាដូវឡើងទៅ ។

ដានី ៖ កូនប្រសារគាត់នៅផ្សារ?

ថែម ៖ ហ្នឹងហើយ សុផ, មិ ។

ដានី ៖ ប្ដីឈ្មោះ សុផ?

ថែម ៖ ហ្នឹងហើយ ប្ដីឈ្មោះ សុផ ធ្វើពេទ្យ ។

ដានី ៖ ប្រពន្ធឈ្មោះអី?

ថែម ៖ មិ ។

ដានី ៖ ប្រពន្ធឈ្មោះ មិ នឹងកូនរបស់ តា កាន់?

ថែម ៖ កូន តា កាន់ កូនប្រពន្ធដើម ប៉ុនណាថាមិនស្រួលថាខ្ញុំរាយការណ៍អី អត់ទេ ។

ដានី ៖ មិនបាច់ទេអ៊ំ ។ ប៉ុន្តែ តា កាន នឹង គាត់ទៅនៅត្រពាំងធំវិញ?

ថែម ៖ ហ្នឹងទៅនៅត្រពាំងធំវិញ ។

ដានី ៖ ប៉ុនអត់ដឹងប្រពន្ធគាត់?

ថែម ៖ ប្រពន្ធក្រោយដឹងឈ្មោះអី ខ្ញុំអត់បានសួរ ។

ដានី ៖ ចុះខាងគាត់នៅភ្នំលៀប?

ថែម ៖ ចា៎!

ដានី ៖ ចុះខាងប្រាសាទ?

ថែម ៖ ខាងត្រពាំងប្រាសាទក៏មកពីត្រពាំងធំ ។

ដានី ៖ គាត់ឈ្មោះអីដែរ?

ថែម ៖ ឈ្មោះ ហ៊ៅ ។

ដានី ៖ ហ៊ៅ?

ថែម ៖ ប៉ុនស្លាប់ហើយ ។

ដានី ៖ គាត់ស្លាប់?

ថែម ៖ ចា៎!

ដានី ៖ ខាងទានកាំ?

ថែម ៖ ទៅពីនេះទៅ ។ ទានកាំ តា រស់ មួយប៉ុនឈឺឆ្កែងឆ្កាង ផាប់ដៃផាប់ជើងអស់ហើយធ្វើអីលែងកើតហើយ ។

ដានី ៖ នៅណា?

ថែម ៖ នៅឃុំថ្នាត ។

ដានី ៖ ឃុំថ្នាត ឈ្មោះ តា រស់?

ថែម :	ហ្នឹង ។

ដានី :	ប្រពន្ធគាត់ឈ្មោះអី?

ថែម :	ប្រពន្ធគាត់ឈ្មោះ យាយ គុច ។

ដានី :	យាយ គុច?

ថែម :	ទៅធ្វើអាចារ្យនៅវត្តថ្នាត ទាល់ឥឡូវនឹងគាត់និយាយអីអត់ដឹងអីដែរ នៅលក់ៗ ហ្នឹងនៅទានកាំ ។

ដានី :	ឃុំទានកាំ?

ថែម :	ហ្នឹង ។

ដានី :	ចុះឃុំរហាល?

ថែម :	ឃុំរហាល ស្រី ប៉ុនបែកបាក់គ្នាអស់ ដឹងទៅណាមកណា ។

ដានី :	គាត់ឈ្មោះអីគេ?

ថែម :	រហាល កាលនឹង អ្នកស្រុកគេនឹងខ្លះ ហើយមួយទៀតឈ្មោះ ខា ។

ដានី :	ឈ្មោះអីគេ?

ថែម :	ខា នារី ។

ដានី :	នារី ខា?

ថែម :	ហ្នឹង ។

ដានី :	ដឹងគាត់នៅណា?

ថែម :	ទៅបាត់ដំណឹងយូរហើយ ។

ដានី :	ចុះឃុំព្រះនេត្រព្រះ?

ថែម :	ព្រះនេត្រព្រះ អ្នកស្រុកគេនឹង ឈ្មោះ តា ក្រក។ ត្រូវបងប្អូន តា ញឹម ។

ដានី :	ប៉ុន្តែក្រែងមានអ្នកថ្មីជំនួស តា ក្រក ដែរ?

ថែម :	អ្នកថ្មីនារីម្នាក់ ។

ដានី :	ឈ្មោះអីគេ?

ថែម :	ឈ្មោះ ខារ នៅចុងភូមិដើង ប៉ុនក្រែងលរគេខ្លាចម៉េច ។

ដានី :	នៅចុងភូមិអូរអន្ទ្រែនឹងដែរ?

ថែម :	ហ្នឹង ។

ដានី :	អត់ទេ ខ្ញុំអត់ទៅជួបទេ គ្រាន់ចង់ដឹង កុំឲ្យគាត់ខ្លាច ។

ថែម :	ចាំ! ហ្នឹងគ្រាន់ដឹង ។

ដានី :　　កាលនឹងអ៊ំអ្នកតែងតាំងគាត់តើ?

បែម :　　ចា៎! ខ្ញុំទៅរៀបចំ ព្រោះអ្នកចាស់នោះ ព្រោះគាត់ណែនាំពីភ្នំពេញទៅឲ្យទៅរៀបចំមើល ទៅវាលំបាក ហ៊ាយដូចនៅក្នុងបន្ទារ ។ យប់ឡើងមនុស្សដូចចាត់តាំងអ្នក ទៅស៊ើប អង្កេត អ្នកមកថ្មីនឹង រសេវរសាវអូ!គ្មានអ្នកណាហ៊ានដេកទេ ប៉ុនបានអ្នកស្រុកនឹង ឃើញយើងល្អ គេយាមឲ្យ ។ ខ្ញុំអីគាត់ប្រាប់ថាឲ្យដេក អឹឯងបេះសម្រាន្តទៅ ចាំខ្ញុំ អ្នកយាម ។

ដានី :　　ខារ ប្ដីគាត់ឈ្មោះអ៎ដែរ?

បែម :　　ផល ។

ដានី :　　គាត់ឪពុកធ្វើការអី?

បែម :　　អត់ ។

ដានី :　　ផល កាលនឹងកាលពីគាត់នៅព្រះនេត្រព្រះ គាត់មានប្ដីនៅ?

បែម :　　មានហើយ ប្ដីគាត់ ប៉ុនអត់បាននៅជាមួយគ្នាទេ ទើបចេញមកបែកបាក់គ្នានេះ បានៗ នៅ ។

ដានី :　　ចុះមួយទៀត ដែលចំណាំគេ ខ្ញុំនៅនេះព័ត៌មានអី គុកភ្នំត្រយោង យ៉ាងម៉េច អ៊ី បាន ដឹង?

បែម :　　អត់ ខ្ញុំអត់ដឹង ។

ដានី :　　អត់ស្គាល់?

បែម :　　ចា៎!ខ្ញុំនិយាយនែក អ្នកប្ដីងប្ដល់នឹង ខ្ញុំមិនដែលស្គាល់មុខ ហើយអ្នកនឹងក៏មិនស្គាល់ខ្ញុំទៀត តាមមើលផង ព្រោះខ្ញុំអត់បានទៅរៀបចំនៅកន្លែងនឹង អត់ទាល់តែសោះ ។

ដានី :　　អត់ទាល់តែសោះម៉ង?

បែម :　　អត់នឹង ។ ខ្ញុំមនុស្សអ្នកត្រង់ ហើយត្រង់ណាដែលខ្ញុំមិនដែល ខ្ញុំមិនប្រព្រឹត្ត ខ្ញុំប្រកែក ដាច់ខាត ខ្ញុំអត់ទទួលស្គាល់ ។

ដានី :　　ប៉ុន្តែគុកភ្នំត្រយោង មានមែន ហើយក៏អត់ទេ?

បែម :　　ពីមុនមក ឮតែថា ភ្នំត្រយោងៗ ប៉ុនខ្ញុំមិនដឹងថាគេរៀបចំយ៉ាងម៉េចៗ ខ្ញុំមិនដឹងដែរ ព្រោះខ្ញុំទៅនៅរយៈខ្លីដែរ ហើយខ្ញុំទៅៗគិតតែទៅដោះស្រាយប្រជាជនអប់រំអីចឹង មួយ ឆ្នាំមានដឹងរឿងអីគេមិនទាន់អស់មន្ទីរក្រសួងអីនឹងណា ។ ភ្នំត្រយោងនឹង បែបខាងដូចថា ខេត្តអីគេរៀបចំផ្ទាល់ ។

ដានី :　　ប៉ុន្តែអ៊ំស្គាល់ទីតាំងគុកភ្នំត្រយោង?

ថែម :	អត់ ។

ដានី :	អត់ដែលបានទាក់ទងទេ?

ថែម :	អត់ គេអន្តរភាពគេនៅអន្តរភាពគេទៅ ហើយខ្ញុំក៏អត់បានរៀបចំអីដែរ ខ្ញុំគិតតែប្រជាជន ដូចមន្ទីរនៅចឹង នៅស្រុកឃុំចឹង វាដាច់ពីគា ។

ដានី :	ដាច់ពីគ្នា?

ថែម :	ចា៎! អត់ទេ ។

ដានី :	ឆ្ងាយពីកន្លែងអ៊ំ?

ថែម :	ប្រហែល២០០ម៉ែត្រ ប៉ុនវាបាំងភ្នំ បាំងស្ពានគេ២-៣មកខាងនេះមក ខ្ញុំនៅចុងកើត ។

ដានី :	ប្រហែល២០០-៣០០ម៉ែត្រទេ?

ថែម :	ចា៎!

ដានី :	ចឹងមើលគ្នាឃើញ?

ថែម :	ហ្នឹង មិនឃើញទេ ហេ៎! ប្រហែលមួយគីឡូចុះ ជាមួយគីឡូ ។

ដានី :	ជាមួយគីឡូ?

ថែម :	អាផ្លូវចេះចូលទៅភូមិគេចុះ ហើយមានភ្នំគេមួយចុងភ្នំលៀប អានឹងគេហៅភ្នំត្រយោង ។

ដានី :	ភ្នំត្រយោង?

ថែម :	ហើយខ្ញុំនៅអាចុងភ្នំលៀបអាភ្នំខ្ពស់នៅពីខាងកើតភ្នំ ចុងខាងកើត ។

ដានី :	ចុះកាលនឹងកាលអ៊ំដើរធ្វើការ អ៊ំជិះអីដើរធ្វើការ?

ថែម :	ខ្ញុំមុនដំបូង ខ្ញុំដើរៗមិនដែលនៅផ្ទះទេ ដល់ក្រោយមកគេបើកកង់ឲ្យ២ ។

ដានី :	បើកកង់?

ថែម :	ហ្នឹង បើកកង់ឲ្យ២ ខ្ញុំនៅដើរ ដល់តាៗនៅភ្នំពេញ គាត់ចេះសាកសួរ គាត់ដឹកក្រណាត់ ដឹកខោអាវអីយកឲ្យចែកប្រជាជន ក៏គេបើកម៉ូតូឲ្យមួយ ។

ដានី :	កាលនឹងអ៊ំមានម៉ូតូជិះ ចេះជិះម៉ូតូអត់?

ថែម :	ចេះតែឌុប អត់ចេះជិះ ។

ដានី :	មានគេឌុប?

ថែម :	ចា៎!

ដានី :	អ៊ំអត់ចេះជិះខ្លួនឯង?

ថែម :	អត់ ។

ដានី :	គេហៅម៉ូតូម៉ាក់អីកាលនឹង?

ថែម :	ម៉ូតូស្អាតដែរ ។

ដានី :	កាលនឹងមានហុងដា មានសេអ៊ិល?

ថែម :	អឺ! ហុងដានឹង ។

ដានី :	ហើយពណ៌អីទៅម៉ូតូនឹង?

ថែម :	ពណ៌វៀងស្រគាំ ។

ដានី :	ពណ៌អីបៃតង?

ថែម :	ហ្នឹងស្អាត ។

ដានី :	ពណ៌បៃតង?

ថែម :	ចាំ! ខ្ញុំយកមកចោលនៅព្រៃ ។

ដានី :	កាលនឹងអ៊ំអត់ចេះជិះខ្លួនឯងទេ?

ថែម :	អត់ ។

ដានី :	ចុះពីណាទៅឌុបអ៊ំ ដល់ពេលនេះ?

ថែម :	ក្មួយនៅជាមួយ ។

ដានី :	ក្មួយអ៊ំបង្កើត?

ថែម :	មិនទេ ក្មួយជីដូនមួយ ។

ដានី :	ក្មួយជីដូនមួយ គាត់ឌុបអ៊ំ?

ថែម :	ចាំ!

ដានី :	ចុះគ្រួសារអ៊ំគាត់ចេះជិះទេ?

ថែម :	អត់ៗ ចេះរហូតទល់ឥឡូវ ។

ដានី :	គាត់អត់ដែលឌុបអ៊ំអីទៅធ្វើការអី?

ថែម :	អត់ ។

ដានី :	បឺងក្មួយទេ អ្នកជិកទៅធ្វើការ?

ថែម :	ចាំ! បើចោរវាចូលមកប្លន់ផ្ទះខ្ញុំ បានក្មេងៗវាជួយ ហើយប្រជាជន ។

ដានី :	ចោរប្លន់ណា ពីអន្លក់?

ថែម :	ខ្ញុំនៅភ្នំលៀបនឹង ។

ដានី :	នៅភ្នំលៀបមានចោរប្លន់ដែរ កាលជំនាន់នឹង?

ថែម :	មាន ចូលៗចង្រ្កានពីក្រោយចូល ។

ដានី :	កាលនឹងអ៊ំជាគណៈស្រុកនឹង មានចោរមកប្លន់ដែរ?

ថែម ៖ ចាំ! វាចូលរក មិនដឹងរកអី យប់ម៉ោង១ ។

ដានី ៖ ម៉េចទៅចឹង?

ថែម ៖ អឺ! ច្របូកច្របល់ ថាច្របូកច្របល់មែន ចោរក៏យើងមិនសន្និដ្ឋានថាចោរពិតប្រាកដដែរ ។

ដានី ៖ ហើយម៉េចចោរនឹងហ៊ានម៉េច បានមកផ្ទះដូចថាអ៊ី...?

ថែម ៖ គេចោទខ្ញុំថាខ្ញុំនឹង ជជេស ប្រឆាំងអី គណៈភូមិភាគ តា ញឹម ។

ដានី ៖ តា ញឹម?

ថែម ៖ ហ្នឹងគាត់ធ្វើបាបខ្ញុំណាស់ គ្រាន់កាំភ្លើងខ្លីដែលខ្ញុំធ្វើប្រឡាយនឹង ខ្ញុំសួរមតិប្រជាជន ខ្ញុំធ្វើតែ៣ខែហើយ ១០គីឡូ ។ ប្រជាជនយល់ព្រមធ្វើៗទៅដោះស្រាយទឹកខែវស្សា អត់មានលិចផ្ទះគាត់រលីង ២ឃុំ៣ឃុំ ហើយត្រីសប្ចូរនោះសំបូរ ។

ដានី ៖ ចុះអ៊ីដល់ពេល បន្ទាប់ពីក្រោយមក តា ញឹម គាត់បាត់ទៅ ពីណាគេមកជំនួសវិញ?

ថែម ៖ ដល់នេះ ផ្លាស់ តា ម៉ុក ពីនិរតីទៅ ។

ដានី ៖ តា ម៉ុក គាត់មកនេះ?

ថែម ៖ ចាំ! ទៅគ្រប់គ្រងនៅពាយ័ព្យ ។

ដានី ៖ មកគ្រប់គ្រងនៅពាយ័ព្យ ប៉ុន្តែពីណាគេជំនួយការបន្ទាប់ពី តា ម៉ុក?

ថែម ៖ ខ្ញុំអត់សូវដឹងដែរ តែ៧៩រត់ទៅ បែកគ្នាអស់ ។

ដានី ៖ ចុះអ៊ីពេលដែល៧៩ អ៊ីខ្ញុំចង់ឲ្យអ៊ីរៀបរាប់ក្រោយលំអិតពី៧៩មក ពេលយួនរត់មកធ្វើម៉េចទៅយើងរត់អី យើងរត់អី គេចខ្លួនម៉េចទៅ?

ថែម ៖ ខ្ញុំ កាល៧៩នឹង ឧបស័គ្គខ្លាំងដែរ ផ្ទាល់ខ្លួនខ្ញុំកូនង៉ែត ថ្ងៃចេញកូនង៉ែតអាមិញ ។

ដានី ៖ កាលនោះ បើអ៊ីរៀបរាប់តិចមើល កន្លែងយ៉ាងម៉េច?

ថែម ៖ អឺ!ឈឺពោះបណ្តើរប្រាប់គេបណ្តើរ ឈឺពោះបណ្តើរ ដើរប្រាប់គេបណ្តើរឲ្យចេញ ហើយព្ទសូរកាំភ្លើងនៅក្រឡាញ់ វៃគ្នានៅក្រឡាញ់ ។ ដល់ខ្ញុំកើតហើយម៉ោង១២យប់ ដុតភ្លើងបានម៉ាតិចដល់ម៉ោង៥ភ្លឺ ខ្ញុំចេញ ។

ដានី ៖ ចឹងអ៊ីកើតកូនអ៊ីមិញបងប្រុសមិញនឹង កើតម៉ោង១២យប់ ដល់ពេលយ៉េងអាំងភ្លើងបានត្រឹមម៉ោង៥ភ្លឺអចេញ?

ថែម ៖ ចាំ! ចេញ ។

ដានី ៖ កាលនឹងយ៉ាងម៉េចទៅ អ៊ីសរសៃខ្ចី?

ថែម : ដល់ ព្រោះពួសូរកាំភ្លើងនៅក្រឡាញ់ខ្លាំងពេក ដល់នេះ ប៉ុនប្រជាជនអីនៅភូមិនឹង គាត់ចេញអស់ ឲ្យចេញទៅអស់នៅដល់២-៣នាក់ ហើយនឹងយាយឆ្មបក៏ឲ្យទៅដែរ ទៅស្ងាត់អស់ហើយ ។ ដល់ម៉ោង៩ កាំភ្លើងបាញ់គ្នាដូចព្យុះ ដល់ខ្ញុំប្រើអ្នកនៅជាមួយថា មិត្តរាន់ទៅមើលពួសូរគេបាញ់គ្នាពីក្រឡាញ់អីខ្លាំងម៉េច ខ្ញុំប្រើចឹង ហើយខ្ញុំចុះពីលើគ្រែៗដែលដេកឆ្អើលភ្លើងនឹង ចុះមកៗខ្ញុំឈរមើលកូន ហើយខ្ញុំមកឈរឯមាត់ទ្វារ ឈរមើលដៃមើលជើងខ្ញុំ អត់អី នៅឈាមខ្ញុំក្រហមដដែល ហើយអត់មានអី ធម្មតា ។ ដល់នេះក៏ប្រហែល ដូចមិនបាន៥នាទីផង ម៉ូតូងឹងមក ថាអ៊ំអើយទៅៗគេបាញ់គ្នា យួនដល់នឹងហើយ ចុះឡានគេសុទ្ធតែទង់នោះ មកក្អួយអើយព្រោងប្រៀប ដល់នេះ ខ្ញុំនិយាយត្រង់គ្រាន់តែលើកកូនបីហើយ ឡើងម៉ូតូទៅវឹងៗ ទៅដល់ទំនប់ត្រពាំងថ្មនឹង ប៉ុនមិនចំទំនប់នឹងចុងខាងលិចកើត នឹងខ្ញុំដើរផ្លូវនឹង ផ្លូវគោកសៀម ។ ដល់នឹងឈប់ៗនង់ អត់អីធម្មតា ។

ដានី : ចុះកាលនឹងអ៊ំជិះម៉ូតូមក ចុះកូនៗអ៊ំ ប្តីអ៊ំគាត់ទៅណាហើយ?

ថែម : តានឹង គាត់ជាប់នៅផ្លូវជាតិលេខ៦ គាត់នែក! កាន់ឈ្លប ។

ដានី : គាត់កាន់ឈ្លប?

ថែម : ហ្នឹងដឹកនាំឈ្លបនឹង ជាប់ផ្លូវ ។

ដានី : ចុះកូនៗ?

ថែម : កូនៗទៅតាមខ្ញុំ ប៉ុនខ្ញុំមានឡានមួយគេដឹកអីវ៉ាន់ ឆ្នាំងចានអីកូនចៅគេជិះលើនឹង ខ្លះក៏នៅផ្សេងគ្នា សន្យាគ្នាបងប្អូនអីទៅជួបនៅភ្នំកូនខ្វែងទាំងអស់ ។

ដានី : កាលនឹង អ្នកដែលទៅជាមួយអ៊ំគ្នាច្រើនទេកាលនឹង?

ថែម : ជិត៤០០០នាក់ ។

ដានី : ជិត៤០០០នាក់?

ថែម : ហ្នឹង ស្រុកព្រះនេត្រព្រះទៅសឹងតែពាក់កណ្តាល ។

ដានី : ដូចថាអ្នកធ្វើការ ឃុំ ភូមិ ស្រុកជាមួយអ៊ំ ទៅជាមួយគ្នាទាំងអស់?

ថែម : ទៅទាំងអស់ ហើយចូលស្រុកក្រឡាញ់មួយទៀត ។

ដានី : ស្រុកក្រឡាញ់មួយទៀត?

ថែម : ហ្នឹង ។

ដានី : កាលជំនាន់នឹង តា ខូ អី គាត់មកជាមួយអ៊ំដែរអត់?

ថែម : ប្រពន្ធទៅជាមួយខ្ញុំ ប៉េគាត់ធ្វើឈ្លប ។

ដានី : តា ខូ គាត់ធ្វើឈ្លប?

ថែម :  ចា៎!

ដានី :  គាត់មកនៅជាមួយគ្រួសារអ៊ំវិញ?

ថែម :  ហ្នឹង ដល់ចុះម៉ូតូទៅជិះទៅគាត់អាចបំណាស់ គាត់ផ្សេងអីអត់អីធម្មតា ចឹងបានខ្ញុំមានជំនឿ រឿងបុណ្យទាន ខ្ញុំនឹកឃើញម៉ែឪយាយតាអីទៅណា យើងចេះនឹកឃើញអ្នកមានគុណ ជួយស្រង់អាយុជីវិត ហើយឪខ្ញុំយកតាមរហូតម៉ែឪយកតាមរហូត ។

ដានី :  កាលអ៊ំនៅព្រះនេត្រព្រះ មាយឪពុកអ៊ំគាត់នៅជាមួយដែរ?

ថែម :  ចា! ទៅ ប៉ុនគាត់នៅផ្ទះផ្សេង កន្លែងផ្សេង នៅស្វាយស៊ីសាផុននេះ ប៉ុនដល់ហើយគាត់ ទៅជួបគ្នានៅត្រង់នឹង ។

ដានី :  ចឹងកាលពីអ៊ំនៅព្រះនេត្រព្រះ ឪពុកម្ដាយអ៊ំនៅស្វាយចឹង?

ថែម :  ចា៎!

ដានី :  ហើយចុះបងប្អូនបង្កើតអ៊ំ?

ថែម :  បងប្អូនបង្កើតខ្ញុំ ដល់ឡើងដល់លើភ្នំនៅជាមួយរហូត ។

ដានី :  ប៉ុន្តែកាលជនាន់អ៊ំនៅព្រះនេត្រព្រះ គាត់នៅណាវិញចឹង?

ថែម :  គាត់នៅឯស្វាយស៊ីសាផុន ។

ដានី :  ចុះម៉េចអ៊ំមកយកឪពុកម្ដាយមកនៅស្វាយស៊ីសាផុន?

ថែម :  នែ! កាលនេះ តាគាត់ឲ្យ តា ញ៉ែន គាត់ទៅនៅនឹង ។ ដល់នេះគេឲ្យ តា ញឹម គេឲ្យនៅនឹងផ្សារ ។ នឹងហើយ ដល់ក្រោយមកបានខ្ញុំយកហៅបងប្អូនខ្ញុំ នៅតាមជាប់រហូត

ដានី :  ចឹងបានន័យថា ដល់ពេលក្រោយមក តា ម៉ុក គាត់ឲ្យគ្រួសារអ៊ំនឹងមកកាន់នៅនឹង?

ថែម :  ស្វាយស៊ីសាផុន ។

ដានី :  មកស្វាយស៊ីសាផុន អានឹងគេហៅអីគេ ស្រុកហើយក៏តំបន់?

ថែម :  ខេត្តគេ តំបន់ ។

ដានី :  ចឹងគាត់មកធ្វើជាគណៈតំបន់នៅស្វាយស៊ីសាផុន ។

ថែម :  អត់ៗ ធ្វើគណៈតំបន់ទេ គេមានរបស់គ្រប់ ។

ដានី :  ពីណាគេគណៈតំបន់កាលនឹង?

ថែម :  តា ជៀល កូន តា ញឹម ។

ដានី :  ប៉ុន្តែ?

ថែម :  តា នេះឲ្យអប់រំប្រជាជននៅខាងទឹកថ្លា ខាងសំរោង ។

ដានី :  ប៉ុន្តែនៅក្នុងជួរគណៈតំបន់នឹងដែរ?

ថែម : ចាំ! នៅ ប៉ុនលំបាកណាស់ រត់ទាំងកណ្ដាលថ្ងៃត្រង់ៗ

ដានី : ចឹងគ្រួសារអ៊ំធ្វើធំជាងអ៊ំទៀត កាលជំនាន់នឹង?

ថែម : អត់ទេ អត់ធំទេ ប៉ុនគ្រាន់ថា ដូចថាដឹកនាំតិចតួចនឹងៗ

ដានី : ចុះបន្ទាប់ពី តា ជៀល, តា ញឹម, បាត់ទៅ ពីណាមកជំនួសវិញ?

ថែម : ហ្នឹង ៧៩ហើយ បែកបាក់គ្នាអស់ៗ

ដានី : អត់មានពីណាមកជំនួសទេចឹង?

ថែម : អត់ខ្ញុំអត់ដឹងដែរ មានតែគេជំនាន់នេះៗ

ដានី : ចុះបន្ទាប់ពី ដល់ពេលមកកន្លែងកូនខ្វែងឪពុកម្ដាយ បងប្អូន មកជួបគ្នាទាំងអស់?

ថែម : ជួបគ្នាទាំងអស់ៗ

ដានី : ហើយយើងធ្វើម៉េចទៀតទៅ តមកយ៉ាងម៉េចទៀតទៅ រត់បន្ត?

ថែម : ដល់នេះយើងចេះតែទៅ យើងរត់ទៅសំដៅភ្នំដងរែកទៅ ទៅរកព្រៃរកអីៗ

ដានី : ទៅទាំងអស់គ្នាចឹងទៅ?

ថែម : ទៅទាំងអស់ទៅៗ

ដានី : ចុះអ៊ំកាលនឹងនៅសរសៃខ្ទីដងនឹង?

ថែម : នឹង ជិះរទេះ ដល់លែងចោលម៉ូតូ ចោលឡានអស់ទៅ ជិះរទេះៗ

ដានី : ជិះរទេះ?

ថែម : ម៉ាគ្រួសារឲ្យរករទេះមួយ គោមួយនឹមៗ យើងនៅត្រឹមកូនខ្វែងនឹងឲ្យបក នែក!ប្ដីៗមករកចាប់គោ កាលនឹងខ្វះអីរទេះគោៗ យកទៅបរដឹកកូនដឹកចៅទៅ ដល់ឆ្លងផ្លូវបន្ទាយឆ្មារនឹងចោលរទេះទៀតៗ ចោលរទេះនឹង ប្រាប់ថាយកតែកូន ចោលអីចោលចុះឲ្យតែបានកូន ចឹងកុំចោលកូនៗ

ដានី : ចឹងអ៊ំពេលនឹងយើងបានអីហូបទៅ ពេលយើងធ្វើដំណើរតាមផ្លូវនឹង?

ថែម : អត់ទឹក មហាអត់ យើងអត់ដឹងភូមិសាស្រ្ត ម៉ាថ្ងៃម៉ាយប់ ម្នាក់ៗស្ងួតអស់ហើយដឹកកូនតូចម៉ែនោមឲ្យដឹកៗ ដល់គ្រាន់ម៉ោង៣ថ្ងៃរសៀលភ្លៀងដូចមិញចឹងៗ

ដានី : អូ!

ថែម : ហ្នឹង ភ្លើងនោះភ្លៀង ខែជល្លុនគិតមើល ភ្លៀង ដើរគិតព្រៃអាខ្វះត្រង់កន្លែងចឹង ពូតដាក់កំសៀវ ដាក់ឆ្នាំងៗ ហើយភ្លៀងដល់កាត់ទឹកហូរចឹង ថាដូចស្អីជួយស្រង់អាយុជីវិត ក៏រកទាំងអស់គ្នា ដល់ទៅៗ ចុះអន្ដរដាក់ម្នាក់មួយទៃនឹងហូបតាមផ្លូវៗ ដល់ទៅជួបកងទ័ពភ្នំដងរែកនឹង១០យប់ បានដល់ៗ

ដានី ៖ ១០យប់?

ថែម ៖ ហ្នឹងបានដល់ៗ កង់ទ័ពគេហៅ គេមកជួបៗហើយថៃ គាត់ហៅយកស្រូវយកអីគេបុក ទាំងយប់ គ្មានដេកទេ បានអង្ករស៊ីរស់ចេះតែដោះស្រាយចឹងៗ ហើយយួនទៅពីក្រោម មកទៅវ៉ៃនៅស្រុកអំពិលនឹង យើងគេចោលចឹងដែរ គេរត់មុនយើង គេចោលពេញដី ទាំងអស់ ពេញភូមិរំដួលនឹងៗ ប្រជាជនចុះមកយកអាខ្លះបានដំឡូល ខ្លះបានគោ បានចាន បានឆ្នាំង មួយប្រដាប់ប្រើប្រាស់ បានកន្លែងនឹងទាំងអស់ គេចោលគេរត់ចោល ខ្លះគេ ទៅថៃ ខ្លះគេទៅអីៗ បានរស់រកស៊ី បានធ្វើស្រែបានមួយឆ្នាំ នៅស្រុកអំពិលនឹង បាន ១ឆ្នាំ២ឆ្នាំ បានគេវ៉ៃគ្នាដល់នឹងរត់ឡើងលើភ្នំ ទៅទៀតហើយៗ ភ្នំដងរែកពួកខ្ញុំពាសារ ខែណាក៏រុះនិងធ្វើផ្ទះដែរៗ

ដានី ៖ កាលនឹងអ៊ំជួបជុំទាំងប្ដី កូនចៅ ឪពុកម្ដាយបងប្អូន នៅជុំគ្នាទាំងអស់?

ថែម ៖ ជុំគ្នាទាំងអស់ម៉ែឪខ្ញុំនឹងៗ

ដានី ៖ ពេលមកដល់ភ្នំដងរែកនឹង នៅកន្លែងណា ភូមិថៃ?

ថែម ៖ តាំងពី ឡើងតាំងពីចុងភ្នំដងរែកដុតនឹង គេហៅភូមិធ្លកៗ ៗ

ដានី ៖ នៅខាងស្រុកអីគេ?

ថែម ៖ ស្រុកអំពិលៗ

ដានី ៖ ស្រុកបន្ទាយអំពិល?

ថែម ៖ ចាំ! ស្រុកបន្ទាយអំពិល ខ្ញុំទៅនៅនឹងម៉ាឆ្នាំ ភូមិគេនឹងៗ

ដានី ៖ ហ្នឹងខាងអីគេនឹង ១០០៣ ហើយក៏១០០១?

ថែម ៖ អត់ទេ លែងនេះហើយ ដឹងតែប្រជាជនហើយនឹងទ័ព អង្គភាពវិញៗ

ដានី ៖ កាលនឹងអ៊ំនៅប្រជាជន?

ថែម ៖ ហ្នឹង ប៉ុនខ្ញុំគ្គាប់ប្រជាជនខ្ញុំតាំងពីស្រុកព្រះនេត្រព្រះទៅៗ ដល់អ្នកទៅអត់បានប្រពន្ធទៅ ឲ្យមកវិញៗ ប្រជុំសួរចឹងថា ចុះពូឯងមកតែឯង? បាទ! ខ្ញុំមកតែឯងៗ ចឹងពូឯងទៅ វិញស្គាល់ផ្លូវទេ? ថាស្គាល់អីៗ ហៅខ្ញុំសុទ្ធអីៗ ទៅរកឃើញអត់? ថាឃើញ ដើរ តាមផ្លូវរទេះនឹងទៅៗ ហើយស្រុកគាត់នឹងធ្លាប់ចុះឡើងថៃៗ ឲ្យមករហូតទាល់អស់ នៅ តែអ្នកមានប្ដីមានប្រពន្ធអីកូនទៅតាមៗ រហូតដល់ដើរយប់ឲ្យខ្ញុំបីកូននៅកណ្ដាលចឹងទៅ ដូចយើងហែលធ្វើបុណ្យឡើងសាលា គេរៀបកងៗគេ ម៉ាឃុំម៉ាកងវាមាន៦ឃុំនឹង ខាង នេះ៣ឃុំៗ ឲ្យខ្ញុំដើរកណ្ដាល ចុះខ្លាចយួនៗបន្ទាយឆ្មារៗ អឺ! និយាយទៅវែងណាស់ៗ

ដានី ៖ ចឹងមកដល់ស្រុកបន្ទាយអំពិលនឹង អ៊ំនៅនឹងម៉ាឆ្នាំ កន្លែងភូមិធ្លកនឹង?

ប៉ែម : ចា៎! ខ្ញុំនៅនឹងមួយឆ្នាំ ធ្វើស្រែធ្វើចំការ នៅគេហៅទឹកចេញៗ ជិតភូមិអំពិលនឹងម៉ង ។

ដានី : ប៉ុន្តែនៅម៉ាក្រុមប្រជាជនរបស់អ៊ំ ហើយក៏មានខាងប្រជាជនផ្សេងទៀត គេមកនៅជាមួយដែរ?

ប៉ែម : ដល់ខ្ញុំឡើងមកនៅប្រាច់នេះ ។

ដានី : នៅប្រាច់?

ប៉ែម : ហ្នឹងបានដឹក តា គាត់ឲ្យដឹកមកពី បារាំងធ្លាក់ ពីសំឡូត ពីអីមក ។

ដានី : កាលនឹងចាំមើលអ៊ំធ្វើដំណើរមកដលកន្លែងប្រាច់នឹង កាលនឹងមានមនុស្សច្រើន?

ប៉ែម : មនុស្សច្រើនណាស់ កាលនឹងជួបអន្តភាពមកពីភ្នំពេញ ចេញពីភ្នំពេញមកមួយធំ កាលនឹងគេទំនាស់គ្នា អ្នកដឹកនាំៗ ។ តា គាត់ហៅខ្ញុំមកពីនឹងមក ។

ដានី : កាលនឹងគេទំនាស់គ្នាយ៉ាងម៉េច អ៊ំអាចរៀបរាប់?

ប៉ែម : ទំនាស់គ្នា អ្នកធ្វើការជាមួយគ្នានឹង រវល់តែទាស់គ្នាមុខមាត់ ប្រធាន អនុប្រធាន ។

ដានី : ពីណាគេ កាលនឹងអ៊ំអាចប្រាប់?

ប៉ែម : ឥឡូវគាត់ឈប់ហើយ ។

ដានី : ពីណាគេ?

ប៉ែម : នោះ តា ជៀម ហើយ តា ជឹមនៅ ។

ដានី : តា ជៀម?

ប៉ែម : តា ជៀម យើង នៅម៉ាឡៃ ។

ដានី : អូ! តា ជៀម នៅម៉ាឡៃ ខ្ញុំស្គាល់គាត់តើ ។

ប៉ែម : ស្គាល់ដែរ?

ដានី : ស្គាល់តើ តា ជៀម គាត់នៅ ។

ប៉ែម : ហើយនឹងតា ជឹម គាត់ទៅនៅមុនខ្ញុំ ។ តា ជៀម គាត់ជនជាតិ ។ តា ជឹម នៅត្រពាំងប្រាសាទនេះ និងប្តីយាយ ណេង ។

ដានី : តា ជឹម ប្តីយាយ ណេង ។ គាត់ធ្វើអីបានគាត់ទំនាស់គ្នា?

ប៉ែម : គាត់ទៅគ្រប់គ្រងកន្លែងអន្តភាពកម្មករ ១០០៣ ។ អឺ! ៨០៨ ។

ដានី : ៨០៨?

ប៉ែម : ហ្នឹងហើយ ។

ដានី : តា ជឹម គាត់មកពីខាងណាមក?

ប៉ែម : តា ជឹម គាត់មកពីតាកែវដែរ ។

ដានី ៖ ប៉ុន្តែកាលពេលមុនរត់ គាត់នៅណា មុនរត់ មុនយួនចូល?

ថែម ៖ ទេ! តា ជឹម មិនដឹងមកពីណាវិញ គាត់មកនៅប្រាប់នឹង មុនខ្ញុំ៧០ ៧នឹង ។

ដានី ៖ ចុះ តា ជៀម?

ថែម ៖ តា ជៀម ក៏មកជាមួយ តា ប៉ុល ពត នេះ ។

ដានី ៖ គាត់មកជាមួយ តា ប៉ុល ពត នេះ?

ថែម ៖ ហ្នឹង! ហើយដល់ទំនាស់គ្នា ឈ្លោះគ្នា ទ័ពក៏បែកបាក់ ។

ដានី ៖ ចុះម៉េចកាលនឹង តា ជឹម ហើយ តា ជៀម នឹង ពីណាខុសពីណាត្រូវបានគាត់ទាស់គ្នានឹង?

ថែម ៖ ធម្មតា តែមានអារម្មណ៍ចេះចុះលើសខ្វះអីតិចតួច ចេះប្រកាន់គ្នាហើយ ។ ដល់ តា គាត់ហៅខ្ញុំមកពីនឹងទៅ ពីស្រុកអំពិល មកឡើងភ្នំ ។

ដានី ៖ កាលនឹងពីណាធ្វើប្រធាន តា ជឹម ហើយ តាជៀម?

ថែម ៖ តាំ មើលដូចតា ជឹម ប្រធាន មុនខ្ញុំមកនឹង ។ ដល់ខ្ញុំមក ខ្ញុំធ្វើប្រធានម្តង តា ជៀម ធ្វើអនុ, តាជឹម ធ្វើសមាជិក(សើច) ។

ដានី ៖ ដល់ពេលអ៊ំមកពីអំពិល អ៊ំធ្វើប្រធានម្តង?

ថែម ៖ ចាំ! ខ្ញុំធ្វើប្រធានម្តង ។

ដានី ៖ ចុះ តា ជៀម យ៉ាងម៉េចទៅ ដល់ពេលអ៊ំធ្វើប្រធាន?

ថែម ៖ អត់អី ។

ដានី ៖ គាត់អត់អី?

ថែម ៖ ហ្នឹង ខ្ញុំគាត់កំពុងខឹងយ៉ាងម៉េចក៏ដោយ តែខ្ញុំនិយាយទៅគាត់ស្តាប់ ហើយទៅមកដូះខ្ញុំអីមិនដែលបង់ក្រមាទទេរទេ វេចស្អុរ វេច ។

ដានី ៖ ចឹងតា ជៀម?

ថែម ៖ ហ្នឹង តា ជៀម គាត់ចិត្តល្អណាស់ កាលនឹង រាប់គ្នារហូតរាល់ថ្ងៃនៅកូនទៀត ។

ដានី ៖ ឥឡូវអ៊ំនៅសាល់គាត់ដែរ?

ថែម ៖ ចាំ!

ដានី ៖ អ៊ំមានដែលទាក់ទងគាត់ទេឥឡូវ?

ថែម ៖ ទាក់ទងរហូត ទៅម៉ាខ្សែម្តងៗជួបគ្នានិយាយអត់ចេញរួចទេ ។

ដានី ៖ ខ្ញុំមានលេខទូរស័ព្ទគាត់ ខាងខ្ញុំធ្លាប់អញ្ជើញគាត់ទៅភ្នំពេញ ទៅកាលនឹងអញ្ជើញគាត់ទៅតើ ។

ថែម :	ចាំ! មានអី ឥឡូវគាត់ រីត្រែ ។

ដានី :	ហើយចុះ តា ជឹម គាត់នៅណា? នៅត្រពាំងប្រាសាទ?

ថែម :	ចាំ!

ដានី :	ប្រពន្ធគាត់ឈ្មោះអី មិញខ្ញុំភ្លេច?

ថែម :	ណេង ។

ដានី :	ចាំថ្ងៃណាខ្ញុំមានឱកាសទៅត្រពាំងប្រាសាទ ទៅសួររឿងដែរ ។

ថែម :	(សើច)កុំអីកុំសួរ ។

ដានី :	ចុះគាត់កាលនៅជាមួយអ៊ំ ជាមួយ តា ជៀម អីយ៉ាងម៉េចដែរ ។

ថែម :	តែមិនស្រួលគាត់មិននិយាយទេ ។

ដានី :	ចះអ៊ំ ដល់ហើយទៅ តា ម៉ុក ទៅហៅអ៊ំពីស្រុកអំពិល ពីនឹងមកទៅនៅណាវិញ?

ថែម :	ខ្ញុំទទួលប្រជាជនផង ទទួលប្រពន្ធទាហានផង ម៉ាមុខនេះនឹងម៉ាមុខប្រាប់ ។

ដានី :	ប្រាប់នឹង?

ថែម :	ចាំ!

ដានី :	អ៊ំនៅទទួលនឹងយូរទេ?

ថែម :	យូរ គ្រាន់ប្រពន្ធទាហានមួយកងពល៥០០ ។

ដានី :	ពីឆ្នាំណាដល់ឆ្នាំណា?

ថែម :	កាលនឹងឆ្នាំ៨០ ៨១ ៨២ រហូត ។

ដានី :	៨០ ៨១ ៨២ រហូតដល់ពេលណា ទទួលធ្វើ?

ថែម :	ខ្ញុំទទួលប្រជាជននឹងរហូតដល់ធ្វើ ឆ្នាំ៩៨ ៩៩ ចុះមកអន្លង់វែង កាល៩៣អ៊ុនតាក់នេះ

ដានី :	ក៏អ៊ំនៅទទួលប្រជាជនដែរ?

ថែម :	ចាំ! ខ្ញុំមកទទួលតែប្រជាជន ខ្ញុំទទួលប្រជាជនរហូត ។

ដានី :	ទទួលប្រជាជនម៉ាស្រុកអន្លង់វែងនឹង?

ថែម :	ហ្នឹង ។

ដានី :	កាលនឹងអ៊ំធ្វើធំដែរ?

ថែម :	(សើច) តា គាត់ចេះប្រគល់ ។

ដានី :	ចុះអ៊ំកាលនឹងយើងទទួលប្រជាជន ទាំងប្រពន្ធទាហានប្រជាជនកាលនឹង យើងទទួលដូចថា យើងរៀបចំពួកគាត់យ៉ាងម៉េច ហើយណែនាំពួកគាត់យ៉ាងម៉េច ហើយហូបចុកអីយ៉ាងម៉េចដែរកាលនឹង?

ថែម : មានអី ដូចថាមួយខែ តា គាត់បើកឲ្យម្តង ក្នុងម្នាក់អង្ករមួយប៉ោតចឹង ។ ចឹង៥នាក់ យើងធ្វើបញ្ជីឲ្យ៥នាក់ ៥ប៉ោតមួយខែនឹង ។

ដានី : ១ខែ ៥ប៉ោតអីចឹង?

ថែម : ចាំ! ដល់យើងហូបមួយអស់ អត់អស់ យើងដូរជាមួយថៃខ្លះ ។ ហើយអត់ដែល ព្រោះ តា គាត់បានជំនួយចិន ជួយ ។

ដានី : កាលនឹង ជំនួយរបស់ចិនជយយរហូត?

ថែម : ចាំ! ដឹកតាមផ្លូវថៃ ហើយប្រជាជនចំរុះសឹងទូទាំងប្រទេស មកមុខនឹងទាំងអស់ ។

ដានី : ហើយចុះពេលប្រជាជនចំណុះមកពីគ្រប់ទិសអីចឹង មានទំនាស់គ្នាដែរអត់?

ថែម : អត់ ។

ដានី : អត់ទេ?

ថែម : ហ្នឹង នឹកឃើញ ខ្ញុំប្រកាន់ចិត្តភារកិច្ចដែលអង្គការប្រគល់ឲ្យអត់មានរើសអើងថា ប្រជាជន មកពីនេះពីនោះអីរបស់គេរបស់ឯងគិតតែមួយ ឡើងមកពីក្នុងទៅក៏ដោះស្រាយ អត់ រាយការណ៍ឲ្យ តា ។ ចឹង តា គាត់ឲ្យគេដឹកឲ្យ ។ ហើយកាលនឹងបារាំង ជំនួយអង្គពិភពលោក គាត់ស្គាល់ខ្ញុំ ។ មានប្អូនមួយបកប្រែ ចេះភាសាបារាំង និយាយពីអត់ខ្វះ ទោះបីគេយាមប៉ុន្មានដាន់ក៏នៅតែចាំដល់គេបើកឲ្យមកនឹង ។ ហើយគាត់បើកឲ្យ ។

ដានី : ចុះអ៊ំពេលដែលអ៊ំនៅខាងប្រាប់អីនឹង កាលនឹងយើងពេលបុណ្យទានយើងអី ធ្វើបុណ្យអី ជាមួយព្រះសង្ឃទៅវត្តទៅវ៉ាអីមានដែរអត់ កាលនោះកាលយើងនៅតស៊ូ ហើយបើក អង្ករបើកអី?

ថែម : អត់មានព្រះសង្ឃទេ មានតែតា ។ ដែលគាត់ធ្លាប់បួស ហើយយើងយកមកគាត់សូត្រធម៌ សូត្រអីធម្មតា ។ ប៉ុនគ្រាន់អត់មានព្រះសង្ឃ សូត្រធម៌ដូចរាល់ថ្ងៃ ខែរដូវចូលឆ្នាំ ភ្ជុំអី ។

ដានី : ចុះអ៊ំខ្ញុំឆ្ងល់មួយទៀត អ៊ំកាលពីជំនាន់យើង៣ឆ្នាំ ម៉េចបានយើងអត់រៀបចំជាព្រះសង្ឃ ជាវត្តជាលោកអី ដឹងទេ?

ថែម : អានឹងខ្ញុំអត់ដឹងដែរ ប៉ុន្តែ ស្រាប់តែអស់លោកសឹកអស់រលីង ចូលទ័ពទាំងអស់ ទាំងសក់ខ្លី អត់មានចាំដល់វែងទេ ។

ដានី : ប៉ុន្តែដល់ពេលយើងបានឯករាជ្យ យើងទទួលបានជ័យជំនះ យើងរៀបចំរស់នៅតាមភូមិភាគ តាមសហករណ៍ ម៉េចបានយើងអត់មានរៀបចំជាមានវត្តមានលោក ដើម្បីឲ្យយើងបានធ្វើបុណ្យធ្វើទានអី ពីព្រោះដូចអ៊ំអីធ្លាប់ទៅវត្តទៅវ៉ា អ្នកជឿលើព្រះពុទ្ធសាសនា?

ថែម : ចាំ!

ដានី ៖ អ៊ំមានកាលនឹងមានជឹងមានអីដែរ?

ចែម ៖ នឹងតែដូចខ្ញុំនិយាយ យកតែចាស់ៗដែលគាត់ធ្លាប់បួស ចេះធម៌ចេះអាចារ្យយកមករៀបចំសូត្រ ដូចមានសង្ឃរាជមាននេន មានយាយតាចឹងដូចគ្នា ប៉ុន្តែគ្រាន់អត់បួសៗ ហើយវត្តយើងយកវត្តទៅជាមន្ទីរធ្វើការងារវិញទៅៗ អានឹងមិនដូចថាត្រូវតែចឹងម៉ង តែតាមមើលៗ

ដានី ៖ អ៊ំអត់ដឹងពីគោលនយោបាយពីលើមក?

ចែម ៖ អត់ ស្រាប់តែចេញចឹងៗ ហើយដល់ចេះធ្វើតែចឹង យើងអត់ឈប់ ព្រោះយើងអ្នកដឹងបុណ្យដឹងបាបអីចឹង ខែរដូវនៅធ្វើមិនភ្លេចទេ ដូចចាមគេមានសង្ឃរាជគេសម្រាប់ធ្វើបុណ្យចឹង យើងក៏ចឹងកាលជំនាន់នឹងៗ

ដានី ៖ ចុះអ៊ំពេលដែល អ៊ំមានប្រសាសន៍មិញថា អ៊ំយើងចុះពីលើភ្នំមករស់នៅអន្លង់វែងនេះចុះមកឆ្នាំណាទៅ?

ចែម ៖ តាំងពី៩៣ម្ល៉ង ជំនាន់អ៊ុនតាក់ៗ ខ្ញុំមកនៅអន្លង់វែងនេះ ខ្ញុំធ្វើផ្ទះធ្វើអីនេះបានស្អាតជាងនឹងទៅទៀត ដល់រត់ទៅម៉ាសារទៅ នឹងគេដុតហើយៗ

ដានី ៖ ចុះអ៊ំពេលដែលដំបូង យើងចុះមកនៅដំបូងកាលនឹងយ៉ាងម៉េចបានយើងចុះមក ហើយកាលនឹងមានផ្លូវមានអីចុះមកអត់?

ចែម ៖ មាន តា គាត់មានអាត្រាក់ មានឡានអី គាត់ធ្វើផ្លូវមកភ្លឹង អាផ្លូវរាល់ថ្ងៃនឹង តាំងពីតា មកៗ

ដានី ៖ ចឹង តា ម៉ុក គាត់អ្នកធ្វើទៀត ផ្លូវនឹង?

ចែម ៖ ចា៎!

ដានី ៖ ធ្វើពីត្រង់ណាមក?

ចែម ៖ ធ្វើមកតាមអាផ្លូវរាល់ថ្ងៃនឹង ចុងភ្នំ២០០០នឹងៗ

ដានី ៖ ពីចុងភ្នំគេហៅជាំនឹង?

ចែម ៖ ចា៎!

ដានី ៖ ហើយចុះមក រហូតគាត់ធ្វើផ្លូវដល់ណា?

ចែម ៖ លើរហូតទៅព្រៃស្អាក ទៅហួសព្រៃស្អាក ស្រែណាយ បាយគាប់អីណាៗ

ដានី ៖ កាលនឹងគាត់ធ្វើផ្លូវចុះមក បានមានប្រជាជនចុះ ហើយក៏ប្រជាជនចុះមកហើយ បានគាត់ធ្វើផ្លូវ?

ចែម ៖ ធ្វើផ្លូវហើយបានប្រជាជនចុះៗ

ដានី : ផ្លើផ្លូវហើយបានប្រជាជនចុះមក?

ថែម : ចា៎! កាលនេះប្រជាជននៅជិរ។

ដានី : ចុះអ៊ំម៉េចបានគាត់មានយ៉ាងម៉េចបានឲ្យប្រជាជនចុះមកនៅនឹង?

ថែម : យើងមានគោលដៅមួយ នែក!កាលចប់នេះ អ្នកមេៗគេចូលទៅទាក់ទងជាមួយមេខាងក្នុងនឹង រួច តា នួន នៅដែល គាត់មានបងប្អូនគាត់ មាស សុភា បងប្អូនគាត់។

ដានី : នួន នៅ នឹង បងប្អូន មាស សុភា?

ថែម : ចា៎!

ដានី : បងប្អូន យ៉ាងម៉េច?

ថែម : បងប្អូនគាត់ជិតដែរនឹង បងប្អូនជីដូនមួយម៉េចទេ។

ដានី : ជីដូនមួយ?

ថែម : ចា៎! ដល់ហើយចេះតែទាក់ទងគ្នាបានចឹងទៅ គេចេះចូលទាក់ទង ហើយ ហ៊ុន សែន សម្រេចឲ្យមក។ ចឹងយើងមក។ ហើយអ្នកនៅនេះមុននឹង យើង២ផ្នែក មួយផ្នែកឡើងភ្នំ ម៉ាផ្នែកទៅបាយតាប់ ស្រែណាយខាងគេ។

ដានី : ពេលយើង ពេលដែលចុះមកដំបូងចឹង កាលនឹងអ៊ំមកចាប់ មករស់នៅកន្លែងណាផ្ទះដំបូង?

ថែម : នៅត្រង់ ឡើងពីអូរជីកមកពីស្ពាននឹងមក ដែលមានដើមស្វាយដើមមានអី ផ្ទះខ្ញុំភូមិខ្ញុំ។

ដានី : កន្លែងមានមន្ទីរពេទ្យនឹង ជិតមន្ទីរពេទ្យ?

ថែម : ចា៎! ខាងជើងមន្ទីរពេទ្យនឹង ហ្នឹងភូមិខ្ញុំហើយ។

ដានី : គេហៅភូមិអី?

ថែម : ភូមិអូរជីកនឹងម៉ង។

ដានី : គេដាក់ឈ្មោះភូមិអូរជីក ឬក៏ដាក់ឈ្មោះភូមិអី ភូមិយាយថែម។

ថែម : គេហៅតែឈ្មោះខ្ញុំ។

ដានី : គេហៅឈ្មោះអ៊ំ ភូមិយាយថែមចឹង?

ថែម : ចា៎!

ដានី : ចឹង អ៊ំមកនៅនឹង កន្លែងនឹងដំបូងគេ?

ថែម : ចា៎!

ដានី : ចុះអ៊ំពេលដែលមកនៅនឹងបានប៉ុន្មានឆ្នាំទៅ បានមានការឈ្លោះទាស់ទែងគ្នា ហើយយើងត្រូវរត់ម៉ាសារទៀត?

ថែម : ខ្ញុំមកដល់នេះហើយ ។

ដាន់ : ប៉ុន្តែកាលអ៊ំនៅអន្លង់វែង?

ថែម : នឹងឡើងភ្នំទៅគេដុតផ្ទះម៉ាសារ ។

ដានី : កាលនឹងម៉េចបានគេដុតផ្ទះនឹង យ៉ាងម៉េច?

ថែម : វ៉ៃគ្នា ខាងក្នុងហើយនឹងយើងទ័ពមកពីលើភ្នំ ។

ដានី : វ៉ៃគ្នាយ៉ាងម៉េចទៅ អ៊ំ?

ថែម : ដល់នេះយើងរត់ឡើងលើភ្នំធ្វើជំរំធ្វើអី នៅដល់ក្រោយមកឆ្នាំ៩៩នឹង បានគេត្រូវគ្នា ហើយដាក់ខសន្យាថា ឲ្យតែអ្នកនៅលើភ្នំទាំងអស់នឹង ចុះមកចូលគ្នា ដីអ្នកណា គេឲ្យវិញ ដីណាគេឲ្យវិញ ។ ដល់មកភូមិខ្ញុំនឹងគេនៅពេញ ។

ដានី : ពីណាទៅ?

ថែម : អ្នកមកថ្មីនឹង ហើយទាហានអីគេយកគេថាគេរំដោះពី តា ម៉ុក ដល់ខ្ញុំក៏ចេញមកនេះ មក ។

ដានី : ចុះអ៊ំអត់តវ៉ាអីគេយកវិញ?

ថែម : អត់ តវ៉ាដែរ កាលនង ព្រំ សាម៉េន មកដោះស្រាយ ប៉ុន ស្រុកនឹងអត់ដោះស្រាយឲ្យ ខ្ញុំ ស្រុក តា យឹម សាន ។

ដានី : យឹម សាន?

ថែម : នែក! យឹម សាន, តា នី, តា កុយ សាវឿន អីនឹង ។ សុទ្ធតែគ្នាឯង ។

ដានី : គាត់អត់ដោះស្រាយឲ្យ?

ថែម : អត់ កាលនឹង ព្រំ សាម៉េន ឲ្យទៅមើលស្រែ មើលអីខ្ញុំដោះស្រាយឲ្យស្រួលអី គេយក នឹង ប៉ុនគេមកនៅហ៎យ អត់ឲ្យរុះផ្ទះចេញទេ ឲ្យគេនៅចុះ ។ ដល់នេះ ខ្ញុំខ្ជិល គេអត់នៅ មើលដោះស្រាយអី ខ្ញុំមកនេះ ខ្ញុំកាប់ឆ្ការព្រៃនេះ ព្រៃមីន ។ ភូមិខ្ញុំដល់ អ្នកនៅនោះ ចេះឆ្ងល់ ខ្មែរក្រហមចុះពីលើភ្នំ អត់ដែលឈប់ទិញអីៗហូបអន្លង់វែង តែចុះមកបាត់ៗ ចុះគេនៅចឹងនោះ ។

ដានី : ចុះអ៊ំពេលមួយទៀត ពេលដែល តា ម៉ុក ពេលចុះមក តា ម៉ក គាត់កសាងតាមកន្លែង ផ្សេងៗនឹង កាលនឹងអ៊ំបានឃើញគាត់កសាងកន្លែងអីខ្លះទៅ ពេលដែលយើងចុះមកពីភ្នំ ដំបូង ពេលអ៊ំនៅមកធ្វើផ្ទះនៅកន្លែងជិតអូរជីកនឹង កាលនឹងឃើញ តា ម៉ុក គាត់កសាង បានស្នាដៃ បានសមិទ្ធិផលអីខ្លះទៅ?

ប៉ែម ៖ គាត់កសាង ទី១ គាត់រៀបចំទិញរោងចក្រអារឈើមួយដោះស្រាយឲ្យប្រពន្ធទាហាន និង ប្រជាជន។ ហើយគាត់ទិញគោយន្ត គាត់ទិញអាត្រាក់ទ័រភ្ជួរដីឲ្យនឹងគាត់ដោះស្រាយឲ្យប្រជាជនយើងដែលមក។ ដល់រួចហើយ ទី២គាត់ចាប់ផ្តើមធ្វើ............។

ដានី ៖ គាត់កសាងរោងចក្រៗនៅកន្លែងណា?

ប៉ែម ៖ នៅស្រះឈូក កន្លែងវត្ត។

ដានី ៖ កន្លែងវត្តនឹង?

ប៉ែម ៖ ដល់យើងរត់ឡើងភ្នំគេយកអស់។

ដានី ៖ ចឹងសមិត្តិផលទី១ រោងចក្រៗនឹងគាត់កសាងឆ្នាំណា អ៊ំមានចាំ?

ប៉ែម ៖ ឆ្នាំ២០០០ ៩៩ចាប់ផ្តើម។

ដានី ៖ ៩៩សមាហរណកម្មហើយនឹង?

ប៉ែម ៖ ដល់២០០០បានសមាហរណកម្ម។

ដានី ៖ ចឹងរោងចក្រនឹងគេកសាងតាំងពីអន្លង់វែងមក?

ប៉ែម ៖ តាំងពីខ្ញុំចុះមកលើកទី២ ។

ដានី ៖ រោងចក្រអារឈើនឹង?

ប៉ែម ៖ ហ្នឹង។

ដានី ៖ ចុះក្រៅពីរោងចក្រអារឈើ គាត់?

ប៉ែម ៖ គាត់ចាប់ផ្តើមទប់ទំនប់អូរជីក។ ទំនប់អូរជីកនេះ គាត់ទប់ម៉ាសារចឹងហើយគាត់មិនទុកចិត្តខ្លាចបាក់ គាត់ទៅយកដាងពីថៃៗយកមកទប់ជាប់។ គ្រាន់មៃខ្វ២ ហើយឡានដឹកជញ្ជូនដីថ្មយកមកចាក់៤ ហើយអាឈើជំទល់នោះ ខ្ញុំអីពូកខ្ញុំភូមិខ្ញុំអ្នកកាប់ អាជំទល់គាត់ដែលធ្វើស្ពាននឹង ម៉ាភូមិម្តង៥០០ៗ ១០០០-២៥០០ដើមគ្រាន់ជំទល់។

ដានី ៖ គាត់ធ្វើទំនប់អូរជីកនឹង?

ប៉ែម ៖ ចា៎! គាត់ធ្វើទំនប់អូរជីកនឹង។ ហើយដែនការគាត់ៗថាយកទន្លេមេគង្គយកមកដាក់នៅលង្វែក។

ដានី ៖ យកទន្លេមេគង្គម៉េច?

ប៉ែម ៖ គាត់ធ្វើដូចភ្នំពេញចឹង។

ដានី ៖ អូ! ធ្វើទំនប់នឹង?

ប៉ែម ៖ ចា៎! គាត់ចាប់ផ្តើមទប់ទំនប់នឹងផង ហើយនឹងធ្វើសាលារៀនៗមន្ទីរពេទ្យជាមួយគ្នា សុទ្ធតែយកដាងពីថៃមកទាំងអស់។

ដានី : ធ្វើសាលារៀន ធ្វើមន្ទីរពេទ្យ ហើយធ្វើអីទៀត?

ថែម : ទំនប់ថ្មីៗ

ដានី : ទំនប់ថ្មី នៅភូមិទំនប់ថ្មីនឹង?

ថែម : ចាំ! នឹងគាត់ធ្វើដែរ មានមៃខូ២គ្រឿង ហើយឡាននឹង៤គ្រឿងដែរនៅឈរនឹង ទប់ៗ ហើយគាត់ជីក មានអាទប់ៗទៅ អាណាជីកប្រឡាយទៅចឹងទៅព័ទ្ធមក ប៉ុនជីកបានមួយកំណាត់ ព័ទ្ធទៅជើងភ្នំចឹងទៅ មកធ្លាក់ស្រះឈូក ដែនការគាត់ មកទល់ផ្លូវធំឡើងមកភ្នំ

ដានី : គាត់ប្រុងជីកប្រឡាយ?

ថែម : ហ្នឹង គាត់ជីកប្រឡាយ អាភូមិថ្មីនឹង សួរថាប្រឡាយត្រង់ណា ដែលកាល តា ម៉ុក ទប់ទំនប់ព្រែកជីកនឹងគេប្រាប់ហើយ ។

ដានី : ជកៗបានអត់ មានទឹកហូរ?

ថែម : ជីកបានមានមួយកំណាត់ៗពីទំនប់មកដល់ភូមិថ្មីហើយ ដល់ទៅក៏ចឹងទៅៗ ប្រឡាយនឹងធំ ហើយជ្រៅមហាជ្រៅ ដល់ដែនការគាត់នឹងជីកព័ទ្ធចឹង ធ្លាក់មកឲ្យទឹកនឹងធ្លាក់មកអូរជីក នេះដដែល គាត់ចង់បញ្ជូទឹកនឹងចឹងៗ ចឹងអាកណ្ដាលនេះទៅជាទីក្រុងៗ

ដានី : គាត់ប្រុងជីកប្រឡាយព័ទ្ធជុំវិញ នៅភូមិស្រុក?

ថែម : ព័ទ្ធជុំវិញៗ ហើយទឹកនឹងវាចែកគ្រប់ឃុំទាំងអស់នៅក្នុងស្រុកអន្លង់វែង?

ដានី : ក្រៅពីទំនប់ ក្រៅពីសាលារៀន ក្រៅពីមន្ទីរពេទ្យ ស្ពាន រោងចក្រ គាត់មានកសាងអីទៀត?

ថែម : ឃើញគាត់ខំលេចផ្ទោរប៉ុននឹងរបស់គាត់ៗ ហើយគាត់ផ្ទះគាត់ រាល់ថ្ងៃនេះ អត់មានអ្នកណារុះបាន ព្រោះគាត់ធ្វើផ្ទះគាត់ ប្រក់ក្បឿងឈើ ក្បឿងលើនឹងយកអាឈើដើមៗ ភ្លេចឈ្មោះដើលឈើនឹងហើយ ។

ដានី : ដើមសំរោង?

ថែម : ហ្នឹងដើមសំរោង បន្ទះប៉ុនៗនឹងៗ

ដានី : ហើយគាត់ធ្វើផ្ទះគាត់នឹងសុទ្ធតែមនុស្សលើកតិចណាស់ សុទ្ធតែមៃខូលើៗ

ថែម : សុទ្ធតែមៃខូលើកម៉ង?

ដានី : ចាំ! ព្រោះសសរអោបអត់ជុំ ហើយដាក់ទាំងសំបក អត់មានកោស មានរុះអី ហើយ ឈើកាលនឹងនៅកំណោតកំណាត់ម៉ាល្វែងៗ តទាំងអស់ៗ ចឹងគ្មានអ្នកគេចង់បានឃើញផ្ទះ គាត់នៅណានៅនឹងរបស់គាត់ អត់រុះទេៗ

ប៉ែម ៖ អានឹងសមិទ្ធិផលដែលគាត់កសាង អ៊ីអត់ចាំឆ្នាំពីពេលអ៊ីចុះមកលើកទី១នឹង ពេលអ៊ុនគាត់នឹង ហើយក៏ក្រោយមកទៀត?

ដានី ៖ ក្រោយមកទៀត?

ប៉ែម ៖ ហ្នឹង ។

ដានី ៖ ក្រោយមកទៀតឆ្នាំណា ដែលអ៊ីចាំ?

ប៉ែម ៖ ឆ្នាំ គាត់កសាងផ្ទះគាត់នឹង ឆ្នាំ៩៩នឹងដែរ ។

ដានី ៖ ៩៩នឹងដែរ?

ប៉ែម ៖ ចាំ!

ដានី ៖ ចុះអ៊ីដែលអ៊ីចុះមកក្រោយ ដែលអ៊ីឈប់ អន្ទង់វែងដែលគេយកផ្ទះអ៊ីៗមកនៅនេះឆ្នាំណាទៅ?

ប៉ែម ៖ ខ្ញុំមកនៅនេះឆ្នាំ២០០០ កាល៩៩ខ្ញុំនៅនោះ ៩៨ ៩៩ ។

ដានី ៖ ៩៨ ៩៩ អ៊ីនៅណា?

ប៉ែម ៖ នៅមុខ ។

ដានី ៖ នៅមុខនេះ?

ប៉ែម ៖ ចាំ!

ដានី ៖ ឆ្នាំ២០០០អ៊ីមកនៅនេះ?

ប៉ែម ៖ ចាំ!

ដានី ៖ អ៊ីមកនៅនេះ ភូមិនេះអ៊ីជាអ្នកបង្កើត ជាភូមិ កសាងភូមិថ្មី ឬក៏មានភូមិចាស់?

ប៉ែម ៖ ភូមិថ្មីសុទ្ធ បន្ទាយទាហាននៅកន្លែងសាលារៀន ។

ដានី ៖ សាលារៀន?

ប៉ែម ៖ ចាំ! កាលយួនចូលមកធ្វើបន្ទាយធំការពារអន្ទង់វែងនឹង ។ ហើយ តា គាត់ប្រាប់ឲ្យខ្ញុំមកនៅនឹង ខ្ញុំមកនៅនឹងទៅ ។

ដានី ៖ ពេលអ៊ីមកនៅដំបូងប្រជាជនអត់មានទេ?

ប៉ែម ៖ អត់ ព្រៃសុទ្ធ ព្រៃខ្លា ព្រៃដំរី ។

ដានី ៖ ដល់ពេលអ៊ីមកនៅចឹង មានអ្នកគេមកនៅតាមច្រើនអត់?

ប៉ែម ៖ នៅ៧/៨គ្រួ(សារ) ។

ដានី ៖ ៧/៨មកនៅជាមួយអ៊ី?

ថែម : ចា៎! មកជាមួយខ្ញុំនឹង ៗ ដល់ឆ្នាំ២០០០ យើងសមាហរណកម្មហើយ ប្រជាជនពីក្នុងពីតាមខេត្តតាមអីគ្រប់កន្លែងទាំងអស់ចេះតែមកហើយ ។

ដានី : ចុះអ៊ំពេលដែលអ៊ំមកនៅដំបូងកន្លែងនឹង ឈ្មោះភូមិឈ្មោះអី អ៊ំអ្នកបង្កើត ក៏មានឈ្មោះគេពីមុនមក?

ថែម : ឈ្មោះកងទ័ពនៅអូរអង្រែ នៅអូរជ្រៅធំនឹង កន្លែងកងទ័ពគាត់បុកស្រូវ បុកអង្ករនឹងដល់ហើយគាត់ដាក់ឈ្មោះអូរអង្រែៗ ដល់ខ្ញុំមកនៅនេះ វាចំតួអូរអង្រែដែរ ។

ដានី : ដល់ចឹងអ៊ំហៅអូរអង្រែៗទៅ?

ថែម : ចា៎! ហៅអូរអង្រែ ។

ដានី : ដល់ពេលកើតភូមិដំបូងគេចឹង មាន៧៨គ្រួសារនឹង កាលនឹងពីណាធ្វើប្រធានភូមិ?

ថែម : ខ្ញុំ ព្រោះអីប្រជាជនគ្រាន់គេរៀបចំ មុនដំបូងនៅចុះពីលើភ្នំមកនៅភូមិអភិវឌ្ឍន៍ ឯមុខនោះណា ដល់គេបើកអង្ករឲ្យពួកខ្ញុំអត់គ្រប់ គេក្រៅពីនឹង ភូមិគេផ្សេងៗម្នាក់បាន៨គីឡូ ដល់ភូមិខ្ញុំទាំងអស់គ្នានឹងបានតែ១គីឡូកន្លះ ។

ដានី : ម៉េចចឹង?

ថែម : គេអត់ឲ្យគ្រប់ គេយកអង្ករទៅលក់ ។

ដានី : ពីណាគេយកអង្ករទៅលក់?

ថែម : អ្នកបើកនឹង ដូច២ផ្នែក អ្នកបើកនឹងនៅខាងស្រុក ប៉ុនឲ្យមិត្ត ឡៃ នៅក្រុមប្រឹក្សាស្រុកដល់ក៏នាំគ្នាឡើងទៅដូចបាតុកម្ម ទៅសាលាស្រុកគេអត់មាត់រក ទៅអង្គុយពេញ អត់មានអ្នកណានៅមួយគេចេញអស់ អ្នកធ្វើការ នាំគ្នាទៅផ្ទះ តា ពឹមៗឲ្យ៤០០បាត ឲ្យខ្ញុំចេញមកដល់ផ្សារទិញប្រហុកម្នាក់៥០០ៗ ចែកគ្នាអស់ត្រឹមនឹង យួរមកផ្ទះ ។ មកដល់ទាមទារអង្ករ ចុះអង្ករមួយគីឡូកន្លះ ។ ដល់ហើយបានប៉ុន្មានខែ លោក ហ៊ុន សែន មកហើយៗ ក្រោយមកបានអង្ករអង្គការពិភពលោកនឹង រួចពីប៉ៃលិនមកដាក់អន្លង់វែង ខ្ញុំមានគម្រោងធ្វើផ្លូវនឹង ។

ដានី : ផ្លូវនេះគម្រោងអ៊ំអ្នកធ្វើទេ?

ថែម : ចា៎! សុទ្ធនារីសុទ្ធ ដល់ខ្ញុំរៀបចំនារីមួយក្រុម៦នាក់ ដល់នេះខ្ញុំយកគម្រោងនឹងយកឲ្យខ្លួនឯង ។

ដានី : យកឲ្យពីណា?

ថែម : យកឲ្យពូរុន ប្រធានអង្គរនឹង ។ យកទៅ កាលនឹងគាត់នៅទៅលំទង មកជួបសួរមកអីមីងខ្ញុំថាយកគម្រោងមកធ្វើផ្លូវមកឲ្យពូឯង ចេះទៅបើយើងវាទាល់ហើយ បើស្រុកគេអត់

ទទួលស្គាល់ផង ៗ ដល់ហើយ គាត់ថាមើលគម្រោង គាត់យកហើយគាត់ថាអត់អីទេចាំខ្ញុំទៅមើល ហើយមីងឯងចេះវាស់ចេះអីទេ ថាវាស់ ៗ ថាចេះ ៗ ដល់ខ្ញុំមកវាស់៣សារគ្រាន់វាស់ផ្លូវនឹង ដោតដើងទេ គេចេះដោត ពូៗប្រុសៗគេមើលឆាយនារី គេដកចោលទៅ ដកចោលដាំទៀតៗ ។

ដានី : ប្រុសៗនៅណាអ្នកដកចោល?

ថែម : នៅនឹងភូមិនឹង ប៉ុនវាខូចនឹង ។

ដានី : គេអត់ចង់ឲ្យធ្វើ?

ថែម : ហ្នឹង គេអត់ចង់ឲ្យធ្វើ ឃើញនារីៗធ្វើ ។ ដល់ភូមិនឹងតែមួយតើ ទាំងអស់នឹង ទាំងទួលប្រាសាទ ទាំងអូរអង្រែនឹង ។

ដានី : កាលនឹងអត់មានទួលប្រាសាទទេ មានតែអូរអង្រែមួយទេ?

ថែម : មានតែអូរអង្រែមួយគត់ ហើយខ្ញុំធ្វើប្រធានចាប់ពីមុខសាលារៀនមក ខ្ញុំវាស់ពីនឹងមកណា ទៅនោះ តា ធៀប គេធ្វើ ។ វាស់ពីនឹងមកដល់នេះថែក ។

ដានី : ចុះភូមិស្លែងពណ៌ ពីមុនមកឈ្មោះភូមិស្លែងពណ៌ចឹងដែរ អត់ទេ?

ថែម : ពីមុនមកអត់ទេ ដល់ក្រោយមកបានភូមិស្លែងពណ៌ ។

ដានី : ពីមុនភូមិអី?

ថែម : គេហៅភូមិ យាយ វ៉ាន់ៗ ។

ដានី : អូ! យាយ?

ថែម : យាយមួយរៀនទាប គាត់ធ្វើប្រធានភូមិ តា រ៉េត ទើបនឹងក្រោយ ។

ដានី : ចឹងយាយវ៉ាន់ គាត់នៅណាដែរ យាយ វ៉ាន់?

ថែម : នៅបៀតផ្ទះកាកបាទក្រហម ។

ដានី : កាកបាទក្រហមនៅជិតផ្ទះប្រធានភូមិ ជិតផ្ទះពូរ៉េតដែរ?

ថែម : ផ្ទះគាត់មួយម្នាក់ឯងនៅជាប់របងខាងលិច ។

ដានី : គេហៅភូមិ យាយ វ៉ាន់ កាលនឹង?

ថែម : ចា៎! ហៅភូមិ យាយ វ៉ាន់ ដល់ស្រែខ្ញុំម៉ុំនឹង ខ្ញុំទៅធ្វើ គេហៅស្រែស្លែងពណ៌ៗ ក៏ដាក់ឈ្មោះភូមិនឹងស្លែងពណ៌ ។ ស្រែស្លែងពណ៌ ស្រែទំពាទេៗ ។

ដានី : ចុះអ៊ំចាប់ផ្តើមឈរជាឃុំនឹង ចាប់ពីឆ្នាំណាមក?

ថែម : អណត្តិទី១គេរំលាយដល់បែកពេញទឹកពេញដី ខាងស្រុកគេចុះមកដោះស្រាយៗ គេបំបែកភូមិខ្ញុំនឹងផង គេរៀបចំឃុំត្រពាំងគាវ គេបំបែកពីឃុំអភិវឌ្ឍន៍ ។ ដល់ខ្ញុំក៏ទទួលដែរ

ប្រជាជនទាំងអស់លើកដៃថា បែកក៏បែក ព្រោះអីទឹងគេអត់ឲ្យអង្ករ ។ ដល់នេះមាន តាដេវ ត្រពាំងចាស់ ហើយនឹងតាដេវ នឹង ជាមួយគ្នា ហើយនឹងភូមិនេះ មានពាភូមិនឹង តែប៉ុននឹង ។ ដល់ក្រោយមកកើតភូមិអូរសំរោងនេះមួយទៀត ។ ដល់ពីអូរសំរោងមក បាន អូរសំម៉ៃនេះ ប្រជាជននៅថ្មី ដល់ទួលស្វាយ នៅជ្រៅនោះគេចេញមកធ្វើផ្លូវនេះ ហើយ ។ ផ្លូវនេះ ខ្ញុំអ្នកនាំមុខហើយ ។

ដានី : អាផ្លូវទៅសំរោង?

ថែម : ចា៎! ផ្លូវទៅសំរោងនឹង ។

ដានី : អ៊ំអ្នកនាំគេធ្វើ?

ហ្នឹង ខ្ញុំអ្នកដើរមុខម៉ង ខ្ញុំទៅកាន់ការ ពួកខ្ញុំនឹង ។ ហើយដល់នេះ ក៏កងវិស្វកម្មនឹង គាត់ ដើរវាស់ផ្លូវ គាត់រកជូនគាត់ដើរមើលទៅ នាំគាត់ដើររហូតទៅដល់ហួសអូរសំម៉ៃចេះទៅ ម៉ាថ្ងៃវាស់ល្ងាច ។

ថែម :

ដានី : ចុះអ៊ំដោយសារ អ៊ំដូចថាអ៊ំធ្លាប់បានរស់នៅឆ្លងកាត់ច្រើនចឹង ដូចថាសម័យពាឆ្នាំអីផ្លាស់ ប្តូរ អ៊ំទៅធ្វើការកន្លែងពិបាកៗចឹង ។ តើសម័យពាឆ្នាំនឹង វាប៉ះពាល់អីខ្លះដល់ជីវិត ប្រចាំថ្ងៃអ៊ំនឹង?

ថែម : កាលនោះ វាមានប៉ះពាល់អី ប៉ះពាល់ត្រង់យើងលំបាកណាស់ចិញ្ចឹមកូនចៅតូចផង អាកូនតូច ហើយមួយទៀត លំបាកដើរដោះស្រាយ ។ ដោះស្រាយដូចថាវាឆ្អែតវាឆ្អល់ ហើយ ថ្ងៃណាក៏ទៅចោលកូនដែរ ។ កូនខ្ញុំស្លាប់៣-៤នាក់នឹង ខ្ញុំអត់បាននៅទាន់ដង្ហើម ទេ ។

ដានី : ស្លាប់ឆ្នាំណាខ្លះ?

ថែម : កាលឆ្នាំ៧៦ ៧៥ កូនខ្ញុំស្លាប់១ ។ ដល់មកនៅលើភ្នំនេះស្លាប់អស់២ រវល់ដើរធ្វើការ ចឹង យប់ៗ មកកូនលែងដឹងខ្លួនអស់ ។

ដានី : អានឹងជំនាន់ពាឆ្នាំនឹង វាប៉ះពាល់ដល់ជីវិតរបស់ក្រុមគ្រួសារអ៊ំ?

ថែម : ចា៎! ហើយនឹងឃើញថា លំបាកស្មុគស្មាញផ្ទាល់ខ្លួន ចុះកូនវាធំបំផុតហើយ ។ ហើយដល់ ចិញ្ចឹមកូនវាមិនបានគង់វង់រវល់តែដើរធ្វើការ ។ ធ្វើការស្មោះត្រង់មហា ស្មោះត្រង់ថា ខំ តស៊ូ ។

ដានី : ចុះមួយទៀតដូចថារបបពាឆ្នាំនឹង វាប៉ះពាល់អីគេខ្លះដល់ជីវិត អកស្រុកអ្នកភូមិអ៊ំ សហគមន៍អ៊ំសព្វថ្ងៃនឹង មានប៉ះពាល់អីអត់ កាលពីសម័យពាឆ្នាំមក?

ថែម : ឥឡូវនេះ?

ដានី : បាទ! វាប៉ះពាល់ពីនឹងមក មានប៉ះពាល់អីដែរ?

ថែម : អត់ ព្រោះអីប្រជាជននៅសម័យនេះចំរុះ ចឹងអត់ដឹងថា អ្នកដែលធ្លាប់រស់នៅជាមួយខ្ញុំកាលពីជំនាន់នោះ នៅបែកគ្នាអស់ហើយ ។

ដានី : ចុះទំនាក់ទំនងក្រុមគ្រួសារអ៊ំម៉េចដែរ ល្អដែរ ក៏យ៉ាងម៉េច ដូចថាការប្រាស្រ័យទាក់ទងគ្នាក្នុងក្រុមគ្រួសារ ឪពុកម្ដាយ បងប្អូន កូនចៅអី?

ថែម : អត់អី ល្អ ។

ដានី : ចុះកាលពីមុន?

ថែម : ពីមុនមកក៏ ។

ដានី : ពីមុនសង្គ្រាម?

ថែម : ពីមុនសង្គ្រាមក៏អត់អី ព្រោះអី ខ្ញុំយល់ថា ម៉ែឪជាអ្នកមានគុណចឹង ហើយបងប្អូនវិញក៏ចឹងដែរ មានអីចែកចាយគ្នា កុំឲ្យមានពាក្យគេថា អឺ! បានធ្វើការប៉ុននឹងភ្លេចម៉ែភ្លេចឪបងប្អូន ខ្ញុំអត់ទេ ។

ដានី : ចុះជំនាន់៣ឆ្នាំ ការទំនាក់ទំនងក្រុមគ្រួសារម៉េចដែរ?

ថែម : អត់អី ។

ដានី : កាលនឹងអ៊ំ ក្រុមគ្រួសារអ៊ំ បងប្អូន ឪពុកម្ដាយ នៅជាមួយ នៅជិតគ្នា?

ថែម : នៅដូចខ្ញុំចឹង ឲ្យគាត់នៅជុំវិញក្រុមផ្សេង ប៉ុនដល់៧៩មក បានខ្ញុំយកមកនៅជាមួយផ្ទាល់ហើយមួយទៀត ដូចរាល់ថ្ងៃនឹង ក្មួយឯងមើលចរិតខ្ញុំរាល់ថ្ងៃម៉េច ខ្ញុំអត់មានផ្លាស់ប្ដូរពីនឹង ។

ដានី : ចុះសព្វថ្ងៃនេះ ការទំនាក់ទំនង ការរាប់អានក្រុមគ្រួសារអ៊ំនៅតែស្និលស្នាល នៅជិតស្និតស្អិតរមួតជាមួយគ្នា ឬក៏ម៉េច ព្រោះមានការ?

ថែម : នៅដូចពីដើមចឹង ។

ដានី : នៅតែដូចពីដើម?

ថែម : ចា៎! គាត់ធ្វើការអីក៏ធ្វើទៅ ខ្ញុំធ្វើអីក៏ធ្វើទៅធម្មតាចឹង ។

ដានី : ចឹងការទំនាក់ទំនងគ្នា អត់មានផ្លាស់ប្ដូរទេ តាំងពីមុនសង្គ្រាម ជំនាន់៣ឆ្នាំ ហើយក្រោយមក ក៏នៅ?

ថែម : ចា៎! អត់ទេ ព្រោះអីខ្ញុំបានតាំងចិត្តខ្លួនឯងថា បានជាប្ដីប្រពន្ធម៉ែឪទុកដាក់ ម៉ាជីវិតរៀងខ្លួន ។

ដានី : ចុះកូនចៅក៏ចឹងដែរ?

ថែម : ចា៎! កូនចៅខ្ញុំក៏ចឹង ។

ដានី : ចុះអ៊ំមានឧស្សាហ៍និយាយរឿងរ៉ាវពីប្រវត្តិ អ៊ំរត់លួន អ៊ំមករស់នៅអន្លង់វែងនេះ ប្រាប់ដល់សមាជិកក្រុមគ្រួសារ ជួនណាប្រាប់កូនដែលកើតក្រោយៗ ចៅៗ ឬសមាជិកក្រុមគ្រួសារដែលនៅឆ្ងាយៗអី មានដែលនិយាយប្រវត្តិអ៊ំមករស់នៅអន្លង់វែងនេះ ប្រាប់?

ថែម : និយាយដែរ ប៉ុនមិនសូវនិយាយ ដូចថាក្មួយៗបងប្អូនមកពីស្រុកចឹងក៏និយាយខ្លះ ថាអ្នកនៅនេះ ខ្ញុំអត់ដែលនិយាយ អ្នកដែលធ្លាប់រស់នៅជាមួយគ្នាអត់ ។

ដានី : អ្នកធ្លាប់រស់នៅជាមួយគ្នាអត់ដែលនិយាយទេ?

ថែម : ចា៎! អត់និយាយទេ ។

ដានី : ប៉ុន្តែអ្នកមកពីស្រុកអ៊ំធ្លាប់និយាយ?

ថែម : ធ្លាប់និយាយ ។

ដានី : ឧស្សាហ៍និយាយ ក៏មិនសូវទេ?

ថែម : មិនសូវដែរ ប៉ុនគ្រាន់និយាយថាតស៊ូវាលំបាក ឥឡូវនឹងដល់អស់ការងាររចឹង និយាយៗប្រាប់ក្មេងជំនាន់ក្រោយ ហើយនឹងអ្នកទទួលការងារពីជំនាន់ខ្ញុំមុន នឹងខ្ញុំនិយាយៗត្រង់ឧស្សាហ៍និយាយដែរ នឹងឥឡូវ ។

ដានី : និយាយថាម៉េចខ្លះ?

ថែម : និយាយថា ឲ្យយល់ពីការងារ បើមិនបានប្រហែលខ្ញុំ មើលខ្ញុំតាំងពីខ្ញុំធ្វើពីណាមក តាំងពីកូន២ ឥឡូវមកដល់អាយុ៧០ហើយនេះ ខ្ញុំធ្វើបានដោយសារអី ការតស៊ូពាក្យសម្តីការតស៊ូនឹងការងារ ការតស៊ូនឹងអ្នកធ្វើការជាមួយគ្នា ចេះសាមគ្គីគ្នាបានល្អ សាមគ្គីជាមួយប្រជាជន ហើយមួយទៀត ពាក្យថាទទួលខុសទទួលត្រូវ ខ្ញុំមិនដែលអាណាមកថ្កោលទោសខ្ញុំ មើល៎ទៅ ។

ដានី : ចុះអ៊ំដូចថាក្នុងក្រុមគ្រួសារអីអ៊ំច្រើន ពេលយើងទំនេរ យើងជួបគ្នា យើងច្រើននិយាយរឿងអីទៅ?

ថែម : និយាយរឿង ពីជំនាន់មុនមកជំនាន់ឥឡូវ ច្រើននិយាយតាមពុទ្ធទំនាយ ។

ដានី : ច្រើននិយាយតាមពុទ្ធទំនាយ?

ថែម : ចា៎! ហើយនឹងតាមប្រវត្តិសាស្ត្រយើងឃើញជាក់ស្តែង ហើយនឹងយើងចាំខ្លះការធ្វើការងារនឹង យកមកប្រៀបធៀបឲ្យវាដឹងវាយល់ដែរ ។

ដានី : អ៊ំនិយាយនឹង និយាយប្រាប់ពីណាគេ?

ថែម : និយាយប្រាប់កូនចៅអីក្មួយៗអី ។

ដានី ៖ ចុះកូនចៅក្មួយៗថាម៉េច ពេលអ៊ំនិយាយប្រាប់រឿងប្រវត្តិពុទ្ធទំនាយអីចឹង?

ថែម ៖ អត់វាស្តាប់ ប៉ុនបើថាយើងមើលបើមិនទុកចិត្តក៏អត់និយាយដែរ ។

ដានី ៖ ចុះក្នុងចិត្តអ៊ំៗមានរឿងអីដែលមិនចង់និយាយ ឬក៏ពិបាកនិយាយប្រាប់ទៅកូនចៅ ប្រាប់ទៅអ្នកជិតខាង ញាតិមិត្តអី មានរឿងដែរអ៊ំគិតថា លាក់ក្នុងចិត្តថា អ៊ំមិនចង់និយាយពិបាកនិយាយប្រាប់គេអត់ដែរ?

ថែម ៖ មាន ។

ដានី ៖ មានដែរ?

ថែម ៖ ចា៎!

ដានី ៖ ពីរឿងអីទៅ ដែលអ៊ំគិតថាពិបាកនយាយប្រាប់គេ?

ថែម ៖ ពិបាកនិយាយដូចជារឿងបច្ចុប្បន្ន ពូជំនាន់មុនដូចថាមួយជំនាន់ពីរជំនាន់បីជំនាន់ហើយណាឥឡូវទំនាស់ស្អីរាល់ថ្ងៃនេះ ។ ទំនាស់រឿងដីធ្លីៗ ចឹងយើងគ្រាន់បានគិត និងយល់ថាសម័យនេះ សង្គមនេះ វាអាចលំបាកខាងដីធ្លីនេះហើយចេញមុខជាងគេ ។ ចឹងមិននិយាយបានទេ ព្រោះរឿងនេះ បើសិនណានិយាយវាប៉ះ ។ ប៉ះយ៉ាងម៉េច?ដូចគេឲ្យប្រជាជនផ្តិតមេដៃអីចឹង សញ្ញាផ្តិតមេដៃឲ្យគេក្រុមហ៊ុន ខ្ញុំថាកុំទីងនឹងភូមិ-ឃុំ ព្រោះអីយើងមិនធ្វើតាមគេក៏អត់បានដែរ ។ ហើយយើងមើលទាំងអស់នេះ អភិវឌ្ឍន៍រីកចំរើននឹងស្អីខ្លះ តើរបស់នេះយកពីណា អានេះហើយដែលនឹងការព្រួយបារម្ភ ក៏ដូចជាការគិតហើយមិននិយាយបាន ។ គិតក្រែងលរ ក្នុងជំនាន់នេះ ប្រជាជនវាក្លាយជាខ្ញុំគេទាំងអស់ទៅ គំនិតខ្ញុំគិតត្រង់នឹង ដែលបារម្ភ ។

ដានី ៖ ចុះអ៊ំនៅក្នុងសាលារៀនយើង នៅក្នុងអន្លង់វែងសព្វថ្ងៃ អ៊ំគិតថា យើងគួរតែមានប្រវត្តិសាស្ត្រ ពីអន្លង់វែងនឹង បង្រៀននៅក្នុងសាលាអន្លង់វែងដែរអត់ ឬក៏យើងអញ្ជើញចាស់ទុំដូចអ៊ំទៅនយាយប្រវត្តិប្រាប់ក្មេងៗដែរអត់ បើតាមចិត្តអ៊ំ?

ថែម ៖ បើរឿងរៀនសូត្រអី ដូចកាលមករៀនលើកមុន ពូគាត់ឲ្យខ្ញុំឡើងអាន ឡើងអីចឹង ខ្ញុំថាឲ្យនិយាយចេញខ្លួនឯង ខ្ញុំអត់ហ៊ាន ។

ដានី ៖ អត់ទេ?

ថែម ៖ អឺ! ព្រោះអីកុំឲ្យគេថាយើងផុសផុល ចលនាប្រឆាំងអី ត្រង់នឹង ។

ដានី ៖ ប៉ុន្តែបើតាមចិត្តអ៊ំៗគិតថា គួរតែមានប្រវត្តិសាស្ត្រនិយាយ ប្រវត្តិសាស្ត្រពីប្រវត្តិអន្លង់វែង ប្រវត្តិអីនឹង បានទៅដល់កូនសិស្ស ដែលគ្នាទៅរៀនសូត្រនៅតាមសាលាសព្វថ្ងៃនេះ ដែរអត់?

ថែម ៖ ខ្ញុំមាន ពេលគេវ៉ៃកង ឬចូលកងអី អញ្ជើញទៅចូលរួមអី ខ្ញុំនិយាយ ។

ដានី ៖ ចុះអ៊ំបើសិនជាមានភ្ញៀវទេសចរណ៍ជាតិ អន្តរជាតអីគេមកនៅអន្លង់វែងយើងៗគួរតែនិយាយរឿងអីប្រាប់ទៅពួកគេ?

ថែម ៖ និយាយតាមប្រវត្តិនៅអន្លង់វែង ពីអត់មនុស្សមកមានមនុស្សអានឹងបាន ។

ដានី ៖ ពីអត់មនុស្ស មានមនុស្ស?

ថែម ៖ ចា៎! ពីមុនអត់មានមនុស្ស មានតែទាហាន ។

ដានី ៖ ឥឡូវមានមនុស្ស?

ថែម ៖ ឥឡូវមនុស្សពេញ ហើយសម័យនេះ ជំនាន់នេះមានផ្សារមានក្រុងអី នឹងរីកចំរើនហើយ ប៉ុន្តែសុំឲ្យជួយដោះស្រាយមួយ ដែលឲ្យប្រជាជននឹងកុំឲ្យមានការព្រួយបារម្ភពីរឿងដីជាប់ពេក ។

ដានី ៖ កុំឲ្យគាត់ចេះតែព្រួយ គិតពីព្រួយរឿងដី?

ថែម ៖ ព្រួយខ្លាចបាត់ដីគាត់ ចែកកូនចែកចៅគាត់ ។

ដានី ៖ កុំឲ្យគាត់ព្រួយពេក?

ថែម ៖ ហ្នឹងហើយកុំឲ្យគាត់ព្រួយពេក ។ ចឹងខ្ញុំកន្លងមកខ្ញុំចេះតែទប់ៗស្កាត វាមិនបានទាំងស្រុក ប៉ុន្តែគ្រាន់វាបានយូរ ខិតទៅមុខយូរអន្លែងដែរ ។

ដានី ៖ ចុះអ៊ំ ដូចថាទំនាក់ទំនងអ៊ំ អ្នកជិតខាង ឬក៏នេះមានបញ្ហាលួកកករ អីក៏ស្និតស្នាលអីដែរ? ដូចថាអ៊ំ ដូចថាជាមួយអ្នកជិតខាងនៅក្នុងស្រុកភូមិយើង មានបញ្ហាអីក៏អត់មានទេ?

ថែម ៖ បើមានគេប្រាប់ឲ្យទៅជួយដោះស្រាយអីក៏ទៅជួយដោះគេចឹង ។

ដានី ៖ អ្នកស្រុកអ្នកភូមិគាត់ច្រើនមានបញ្ហាអីដែរ ជាមួយគ្នាឈ្លោះគ្នា?

ថែម ៖ ឥឡូវគាត់បន្ថយអស់ច្រើន ។

ដានី ៖ កាលមុនមានបញ្ហាអីទៅ?

ថែម ៖ មានឈ្លោះគ្នាក្នុងគ្រួសារ ប្រើអំពើហិង្សាអី រឿងស្រា រឿងអីឥឡូវអត់ទេ ។

ដានី ៖ ឥឡូវអត់ទេ?

ថែម ៖ ចា៎ៗ ។

ដានី ៖ ចុះអ៊ំបើតាមអ៊ំដូចថាអ៊ំជាចាស់ទុំធ្លាប់បានឆ្លងកាត់ច្រើនសង្គមច្រើនជំនាន់ ចំពោះច្បាប់ទម្លាប់វិញ អ៊ំប្រៀបធៀបមើល កាលពីជំនាន់សង្គមរាស្ត្រនិយម ច្បាប់ទម្លាប់អីយ៉ាងម៉េចដែរ?

ថែម ៖ ច្បាប់ទម្លាប់កាលនោះ ដូចថាមិនសូវបានផ្សព្វផ្សាយអីញឹកញាប់ដូចឥឡូវ កាលពីជំនាន់សង្គមចាស់ រាស្ត្រនិយម ។ យើងទៅតាមវត្តតាមអីចឹង គេប្រកាសផ្សាយ ហើយយើងយកមកអនុវត្តទៅ ។ ឯសម័យនេះ បានរៀនសូត្រញឹកញាប់ ហើយក៏ប្រជាជនគាត់ចេះយល់ចេះតែស្តាប់បានចឹងទៅ អានឹងហើយការកាត់បន្ថយនូវអំពើ ដែលគេហៅអំពើពុករលួយ ។

ដានី ៖ ចុះអ៊ំមួយទៀត កាលពីជំនាន់៣ឆ្នាំ ច្បាប់ទម្លាប់គេយ៉ាងម៉េចដែរ?

ថែម ៖ ៣ឆ្នាំ ច្បាប់ទម្លាប់វា ម៉ឺនមាត់ ។

ដានី ៖ ម៉ឺនមាត?

ថែម ៖ ចាំ! គឹងតែង ប៉ុនតែល្អ ។

ដានី ៖ គឹងតែង តែល្អ?

ថែម ៖ ហ្នឹង!

ដានី ៖ ចុះអ៊ំមួយទៀត កាលជំនាន់៣ឆ្នាំនឹង វាមានជះឥទ្ធិពលច្បាប់ទម្លាប់ស្អីខ្លះ មកដល់អន្លង់វែងយើងសព្វថ្ងៃ?

ថែម ៖ កាលពីសម័យ៣ឆ្នាំ?

ដានី ៖ បាទ!

ថែម ៖ មានឥទ្ធិពលមួយ ដែលយើងមកទំហែកដីធ្វើស្រែធ្វើចំការ ដោះស្រាយប្រជាជនបានគ្រប់បែបយ៉ាង ម្យ៉ាងទៀតក៏រដ្ឋាភិបាលបានចូលគ្នាចឹងទៅ បានជាមួយគ្នាចឹងទៅ ក៏អត់មានកើតទុក្ខអីរឿងសង្គ្រាមទៀតទេ គិតតែរកស៊ី ។

ដានី ៖ ចុះអ៊ំមាននៅចាំ ដូចថាព្រឹត្តិការណ៍ស្អីដែល ដូចថាអ៊ំនៅចាំនៅអន្លង់វែងយើង កាលពីសម័យសង្គ្រាម អ៊ំធ្លាប់ឃើញដូចថាសង្គ្រាមយ៉ាងម៉េចខ្លះដែរ កាលនៅតំបន់អន្លង់វែងកាលពីជំនាន់សង្គ្រាម?

ថែម ៖ ជំនាន់សង្គ្រាម ស្រុកអន្លង់វែងវាពិបាកដែរ អ្នកនៅនេះមិនស្រួលប៉ុន្មាន រវល់តែរុះរើផ្ទះចុះឡើងៗ ហើយម្យ៉ាងរៀនសូត្រស្អី គាត់តើក រៀនក្រោមផ្ទះ ម្លប់ឈើអីចេះតែរៀនហើយ ។

ដានី ៖ កាលជំនាន់ឈ្លោះគ្នា វ៉ៃគ្នានឹង ភាគីខាងណាខ្លះដែលចូលរួមវ៉ៃគ្នាកាលនឹង?

ថែម ៖ វាខ្ទប់នៅក្នុងនឹង ដូចមាន តា ប៉ុល ពត, តា ម៉ុក, មេចឹង ស្រាប់តែទ័ពម្ខាងម្នាក់ចឹងមកវ៉ៃម្ខាងចឹងទៅ ។

ដានី ៖ កាលនឹងមានផ្ទុះ ដូចទ័ព តា ប៉ុល ពត, ហើយនឹង តា ម៉ុក, គាត់ឈ្មោះគ្នា វ៉ៃគ្នាឯង ដែរ?

ថែម ៖ ចា៎! វ៉ៃគ្នាឯង ។

ដានី ៖ ចុះខាងកាលពីសង្គ្រាមលើកមុនមានខាងណាខ្លះវ៉ៃគ្នា អន្លង់វែងនឹង?

ថែម ៖ មានទ័ពខាងសម្តេចនាយក ហ៊ុន សែន និង តា ប៉ុល ពត ។

ដានី ៖ តា ប៉ុល ពត ខាងខ្មែរក្រហម?

ថែម ៖ ចា៎! ខាងខ្មែរក្រហម មានពីរ ។

ដានី ៖ មានពីរ ចុះខាងកងទ័ពវៀតណាមមានដែរអត់ កាលនឹង?

ថែម ៖ អត់ ។ អូ!មានៗចូលជាមួយទាហានយើងខាងក្នុង ។

ដានី ៖ ខាងក្នុងវ៉ៃជាមួយខ្មែរក្រហម?

ថែម ៖ ចា៎!

ដានី ៖ ចុះអ៊ំៗដូចថា អ៊ំស្គាល់ស្និតស្នាល ជិតស្និតជាមួយ តា ម៉ុក បើសិនជាកូនចៅ ឬក៏សួរ អ៊ំឲ្យអ៊ំរៀបរាប់ថា តា ម៉ុក គាត់ជាមនុស្សយ៉ាងម៉េច គាត់មានលក្ខណៈយ៉ាងម៉េច អ៊ំ ពន្យល់ប្រាប់ក្មេងៗថា ម៉េចទៅ?

ថែម ៖ ថា តា ម៉ុក គាត់បានចិញ្ចឹមម៉ែឪយើងគ្រប់គ្នាបានរស់មក ហើយបង្កើតជាសាលារៀន មន្ទីរពេទ្យ ទំនប់ទឹកអីគ្រប់បែបយ៉ាងនៅស្រុកអន្លង់វែង ជាស្នាដៃរបស់គាត់ ក្នុងប្រវត្តិ សាស្ត្រដែលគាត់កាន់កាប់ជំនាន់នោះ ។

ដានី ៖ ចុះតា សុន សេន អ៊ំស្គាល់គាត់ទេ?

ថែម ៖ ស្គាល់ដែរ ។

ដានី ៖ គាត់យ៉ាងមេចដែរ តា សុន សេន?

ថែម ៖ អត់អី ។

ដានី ៖ ចុះ តា ប៉ុល ពត?

ថែម ៖ ហ្នឹងក៏គាត់មនមែនអ្នកឃោរឃៅអី ។

ដានី ៖ ចុះតា ខៀវ សំផន?

ថែម ៖ តា ខៀវ សំផន ដូចថា គាត់អនុធនមែន ប៉ុនគាត់ឈរខាងប្រជាជនដែរ និយាយរួមនៅ ក្នុងអ្នកធំៗទាំងអស់នឹង ទើបតែឆ្នាំដែលឈ្មោះគ្នានឹង កាលពីមុនត្រូវគ្នាមិនបាច់ទេ ។

ដានី ៖ ចុះ តា នួន ជា អី?

ថែម ៖ ហ្នឹង តា នួន ជា ក៏ចឹង ។

ដានី ៖ ចុះអ៊ំទាក់ទងពីនយោបាយ បញ្ហានៅនយោបាយនៅអន្លង់វែងនេះយ៉ាងម៉េចដែរ មានបញ្ហានយោបាយអី ដែលស្មុគស្មាញអីដែរអត់នៅអន្លង់វែងយើង?

ប៉ែម ៖ អត់ មានដូចថា ដែលខ្ញុំនិយាយថា គ្រាន់ទប់ទល់ ហើយតវ៉ា អ្នកយកដីគេ ឲ្យផ្តិតមេដៃឲ្យអីប្រគល់ដី ព្រោះឃើញគម្រោងក្រុមហ៊ុននឹង ខ្ញុំមើលគេយកមកឲ្យមើលតាមភូមិយកមកឲ្យមើល ព្រះរាជាណាចក្រកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ ក្រុមហ៊ុនស្អីទេពាក្យអង់គ្លេស ស៊ីវើលម៉េចទេ ហើយសុំដីសម្បទានសង្គមកិច្ច ក្រឡានតាមលេខរៀងមក គេឲ្យប្រជាជនផ្តិតមេដៃ ។

ដានី ៖ ចឹងនៅអន្លង់វែងនេះ យើងមានបញ្ហាដីធ្លីនោះ?

ប៉ែម ៖ហ្នឹង ។

ដានី ៖ បញ្ហាដីធ្លី រវាងប្រជាជនហើយនឹងក្រុមហ៊ុន?

ប៉ែម ៖ ក្រុមហ៊ុន ហ្នឹង ។

ដានី ៖ ក្រៅពីបញ្ហាដីធ្លី មានបញ្ហាអីទៀត?

ប៉ែម ៖ ដូចអត់មាន ។

ដានី ៖ ចុះនៅអន្លង់វែងយើងនេះ គណបក្សណាដែលជាគណបក្សសំខាន់ជាងគេ នៅក្នុងអន្លង់វែង?

ប៉ែម ៖ មានគណបក្សប្រជាជន ។

ដានី ៖ មានតែគណបក្សប្រជាជន?

ប៉ែម ៖ ចា៎!

ដានី ៖ ហេតុអីបានគណបក្សប្រជាជនសំខាន់ជាងគេនៅអន្លង់វែង?

ប៉ែម ៖ ព្រោះអីភាគច្រើន ហើយពួកខ្ញុំដែលធ្វើខ្មែរក្រហមទាំងអស់គ្នា ចូលជាមួយគណបក្សប្រជាជន ។

ដានី ៖ បាទៗ អ៊ំខ្ញុំសល់សំនួរមួយពីរទៀតចុងក្រោយ ។ ចុះអ៊ំបើសិនជាអ៊ំជាអ្នកសរសេរប្រវត្តិសាស្ត្រនៅស្រុកអន្លង់វែងវិញ អ៊ំយល់ថា អ៊ំគួរតែបញ្ចូលចំនុចស្អីខ្លះនៅក្នុងសៀវភៅដែលអ៊ំត្រូវសរសេរ អានេះឧបមាថាអជាអ្នកសរសេរ?

ប៉ែម ៖ (សើច) ដូចខ្ញុំនិយាយចឹង ព្រោះប្រជាជនទាំងអស់ចំរុះដែលមកគ្រប់ខេត្តគ្រប់ស្រុកទាំងអស់ ដែលមករស់នៅឃុំត្រពាំងតាវ គឺទី១ រឿងដីធ្លី មករកដីមករកធ្លីដើម្បីចិញ្ចឹមកូនចៅដោះស្រាយជីវិតរបស់ខ្លួន ។ ឯទី២ដែលរដ្ឋាភិបាលរៀបចំនេះពេញចិត្តហើយ ។ ប៉ុន្តែនៅព្រួយបារម្ភរឿងដីធ្លីនេះ ក្រែងលរទៅមុខទៀតទៅវាៗទៅជាម៉េចទៀត ។

ដានី ៖ បើសិនជាអ៊ំជាអ្នកសរសេរ អ៊ំគិតពីរឿងដីធ្លី រឿងអ្នកស្រុកអ្នកភូមិអីចូលមករស់នៅក្នុងនឹង ហើយមានបញ្ហាដីធ្លីអីនឹង?

ថែម ៖ ចាំ!

ដានី ៖ អានឹងជាការព្រួយបារម្ភអ៊ំនេះដាងគេ?

ថែម ៖ ហ្នឹង ព្រោះខ្ញុំឡើងតវ៉ាជាមួយលោក សុ ផាណា មៅព្រៃ២-៣ហើយនៅសាលាស្រុក ។

ដានី ៖ ចុះអ៊ំបើសិនជាអ៊ំជាអ្នកសរសេរប្រវត្តិសាស្ត្រអន្លង់វែងនឹងដែរ ចុះព្រឹត្តិការណ៍សំខាន់ៗ ស្អីខ្លះដែលអ៊ីគួរតែបញ្ចូលក្នុងសៀវភៅ ដែលអ៊ំត្រូវសរសេរ ព្រឹត្តិការណ៍ដែលអ៊ំធ្លាប់ជួបប្រទះ ដែលអ៊ំគិតថាសំខាន់គួរតែសរសេរទុក សម្រាប់ឲ្យក្មេងៗជំនាន់ក្រោយដឹង?

ថែម ៖ អានេះ និយាយដូចនយាយមិនទាន់បានក្រែងចាំមើលតិចទៀត ។

ដានី ៖ ឥឡូវអ៊ំនឹកមិនទាន់ឃើញ?

ថែម ៖ ដល់កាលណានិយាយរឿងនឹង ក្រែងលរប៉ះគេ ។

ដានី ៖ អ៊ំអត់ហ៊ាននិយាយ?

ថែម ៖ ខ្លាច ក្រែងលរយើងម្នាក់ឯង ហើយគេគ្នាច្រើន គេមិនពេញចិត្ត ។

ដានី ៖ អត់អីទេ បើអ៊ំមិនចង់និយាយ ក៏អត់អីដែរ ។ ចុះអ៊ំដូចថា តាំងពីអ៊ំរស់នៅដំបូងមកដល់សព្វថ្ងៃនេះ មានការប្រែប្រួល មានការផ្លាស់ប្តូរ មានការអភិវឌ្ឍន៍ល្អ អភិវឌ្ឍន៍មិនល្អអីខ្លះ តាំងពីអ៊ំចាប់ផ្តើមរស់នៅនេះ?

ថែម ៖ មាន ។

ដានី ៖ មានអីខ្លះទៅ?

ថែម ៖ មានល្អត្រង់ខាងរដ្ឋាភិបាល ខាងគណបក្សប្រជាជន គាត់ដោះស្រាយប្រជាជនបានទទួលផលប្រយោជន៍ខាងនឹងច្រើនណាស់ ដូចថាសមិទ្ធិផលទាំងប៉ុន្មានគឺប្រជាជនពេញចិត្ត ដល់ចឹងយើងដឹកនាំក្រោមៗនឹងក៏ស្រួលដែរ ។

ដានី ៖ ចុះអ៊ំម៉ាសំនួរចុងក្រោយទៀត ចំពោះដូចថាសៀវភៅដែលយើងសរសេរពីប្រវត្តិសាស្ត្រនៅអន្លង់វែងនឹង អ៊ំសង្ឃឹមយ៉ាងម៉េចជាលក្ខណៈបុគ្គល ឬក៏ជារួម ជាសហគមន៍ អ៊ំសង្ឃឹមថា សៀវភៅនឹងយ៉ាងម៉េច ផ្តល់ផលប្រយោជន៍យ៉ាងម៉េចខ្លះដល់អ៊ំជាបុគ្គលឬជាសហគមន៍?

ថែម ៖ បើសរសេរតាមប្រវត្តិសាស្ត្រ នៅកម្ពុជាយើង ហើយនឹងពិសេសស្រុកអន្លង់វែង ផ្តល់ផលប្រយោជន៍ឲ្យប្រជាជនយើងតាមជាក់ស្តែង ដូចជាឥឡូវសរសេរពីរឿងទំនាស់ដីធ្លីមួយ ប្រជាជនដែលកំពុងតែរស់នៅដោយមានសុវត្ថិភាពខាងសន្តិសុខ មិនគិតគូរដល់ខ្លាច

សង្គ្រាមទៀតទេ។ អានឹងវាដូចថាឲ្យអារម្មណ៍របស់ប្រជាជននឹងមានស្ថិរភាព រាល់ថ្ងៃរីករាយ ។

ដានី ៖ ចឹងអ៊ំខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំអ៊ំទៀតហើយ ចឹងអ៊ំមានអីចង់បន្ថែម ឬក៏សំណូមពរអី?

ថៃម ៖ ខ្ញុំសំណូមពរ ព្រោះក្មួយមកឲ្យខ្ញុំនិយាយតាមប្រវត្តិនេះ យកទៅសរសេរសៀវភៅហើយត្រង់ណា ដែលមិនគួរដាក់ អានឹងយើងក៏មិនបាច់នេះ។ ប៉ុន្តែត្រង់ណាដែលយើងគួរដាក់យើងមើលដែរ មើលសភាពការណ៍ជុំវិញ តើអំណោយផលឲ្យយើងដាក់បានយកទៅផ្សព្វផ្សាយ អានឹងចាំដាក់ អានឹងសំណូមពរទី១របស់ខ្ញុំ។ ហើយទី២ខ្ញុំនិយាយទាំងអស់នេះលើកឡើងខ្ញុំមិនបន្ទោសបន្ទាប់ពីគណបក្ស ឬក៏រដ្ឋាភិបាលអីទេ ពីព្រោះដំណាក់កាលនេះ តាំងពីសមាហរណកម្មមក គណបក្សប្រជាជនយើងបានដោះស្រាយ ឲ្យផលប្រយោជន៍ ដែលប្រជាជនត្រូវទទួលច្រើនណាស់រាប់មិនអស់។ ហើយប្រជាជនវិញ ក៏ឃើញជាក់ស្តែងថា សមិទ្ធិផលទាំងអស់ខ្លួនបានទទួល ត្រង់នេះហើយដែលបោះឆ្នោតឲ្យគណបក្សប្រជាជនជារៀងរហូត។

ដានី ៖ បាទ! ចឹងខ្ញុំអរគុណអ៊ំច្រើនដែលចំណាយពេលផ្តល់បទសម្ភាសន៍ជាមួយខ្ញុំជាង២ម៉ោង ខ្ញុំអរគុណអ៊ំច្រើនមែនទែន។ ខាតបាយខាតទឹក។

ថៃម ៖ ចាំ!

«ចប់»